ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត




◆ ស្វែងរកការពិតដើម្បីការចងចាំរបស់ជាតិ

◆ លទ្ធភាពក្នុងការប្រឡិកសាច់រឿងនៅមន្ទីរស-២១

រូបថត : ពេជ្រ ជីវិន

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៦២ ខែមិថុនា ឆ្នាំ២០១៣

# ស្វែងរកការពិត

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៦២ ខែមិថុនា ឆ្នាំ២០១៣

## មាតិកា

◆ ស្វែងរកការពិតដើម្បីការចងចាំរបស់ជាតិ ........................................១
◆ ពេញដោយក្ដីសង្ឃឹមជាមួយ អ៊ុនតាក់ ..............................................៣
◆ ដំណើរវិលត្រឡប់នៃរូបចម្លាក់ "បនទេវៈ" ........................................៥

### ផ្នែកឯកសារ

◆ សារទូរលេខ ៖ គោរពជូនអង្គការ ៨៧០ ............................................៨
◆ ចម្លើយសារភាព ម៉ែន ជុន ហៅ ហឹង្ស លេខាតំបន់៥ ........................១០
◆ បញ្ជីឈ្មោះ និងរូបថតអ្នកទោសមន្ទីរស-២១ ..................................១៦

### ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ

◆ សំណាងក្នុងចំណោមអ្នកទោសមួយពាន់នាក់....................................២២
◆ អតីតឈ្លបខ្មែរក្រហម មកជាឆ្មាំរក្សាប្រាសាទ.................................២៥

### ផ្នែកច្បាប់

◆ កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌល ..........................................២៧
◆ សេចក្ដីសម្រេចបំបែកសំណុំរឿង០០២........................................៣១
◆ សេចក្ដីសម្រេចពីសិទ្ធិរបស់ជនសង្ស័យ ..........................................៣៦
◆ ច្បាប់ស្ដីពីការបដិសេធមិនទទួលស្គាល់ ...........................................៤០

### វេទិកាពិភាក្សាសាធារណៈ

◆ ការពិតអាចយកឈ្នះលើការមិនទទួលស្គាល់ ....................................៤៣
◆ លទ្ធភាពក្នុងការប្រឌិតសាច់រឿងនៅមន្ទីរស-២១ ............................៤៧
◆ ទស្សនៈផ្ទុះបញ្ចាំងស្ដីពីសុខភាពផ្លូវចិត្ត ...........................................៥០

### ទំព័រស្រាវជ្រាវរកក្រួសារ

◆ ទណ្ឌិតផ្ដៃល្ពៅ .........................................................................៥៤




អ្នកទោស អ៊ីង ប៉ិច ពេលជាប់ឃុំឃាំងនៅមន្ទីរស-២១ ។ អ៊ីង ប៉ិច បានរួចរស់ជីវិតពីមន្ទីរនេះក្រោយពេលទ័ពវៀតណាមចូលដល់ទីក្រុងភ្នំពេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ ក្រោយមក អ៊ីង ប៉ិច ជាមួយនិងអ្នកជំនាញការវៀតណាមឈ្មោះ ម៉ៃ ឡាំ បានប្រែក្លាយមន្ទីរស-២១ទៅជាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេហលេខនេះ ៖** ស៊ីរិ សាវីណា, មីន សាណាស់, វ៉េនឌុល ជីហ្វាល់កូ, អាន ហាញឌុល, គ្រីស ឌៀរីង, ដេវីដ ឆេនដល័រ, ខេត ឡេងហ្វត, គីម យ៉ុងហ៊ី, ឆាយ ស៊ូឆាត្រ
**អ្នកនិពន្ធនិងស្រាវជ្រាវ ៖** ទាវ សារៈមុនិន្ទ, ស៊ិន សុធីតា **អ្នកបកប្រែ ៖** នង ច័ន្ទមល្លិកា និង ភួង ច័ន្ទប្រណិត **និពន្ធនាយកទូទៅ ៖** ឆាំង យុ និង ញាណ សុជាតិ
**ជំនួយការនិពន្ធនាយក ៖** សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ ៖** សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ ៖** ឆេង រ៉េង Email: dccam@online.com.kh,
Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ស្វែងរកការពិតដើម្បីការចងចាំរបស់ជាតិ

មជ្ឈមណ្ឌលឯកសារកម្ពុជាសូមអំពាវនាវដោយក្ដីគោរព ឲ្យផ្ញើអំណោយឯកសារទាក់ទងនឹងខ្មែរក្រហម និងសម័យក្រោមការគ្រប់គ្រងរបស់អាជ្ញាធ័របណ្ដោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (អ៊ុនតាក់) ។

មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាអង្គការក្រៅរដ្ឋាភិបាលកម្ពុជាឯករាជ្យ ដែលបង្កើតឡើងដំបូងដោយអ្នកស្រាវជ្រាវជាន់ខ្ពស់របស់សាកលវិទ្យាល័យយែល ដោយអនុលោមតាមច្បាប់យុត្តិធម៌លើអំពើប្រល័យពូជសាសន៍នៅកម្ពុជាដែលបានតាក់តែងឡើងក្នុងឆ្នាំ១៩៩៤ ។ អង្គការនេះ ប្ដេជ្ញាធានាឲ្យមានការចងចាំ និងយុត្តិធម៌នៅកម្ពុជា ដែលទាក់ទិននឹងការរំលោភបំពានផ្សេងៗនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដ៏អសោច ។ មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាអ្នកផ្ដល់ភ័ស្ដុតាងដ៏ច្រើនលើសលប់ដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងជាតួអង្គដ៏សំខាន់ក្នុងការផ្សះផ្សាក្រោយជម្លោះនៅកម្ពុជា និងកិច្ចខិតខំប្រឹងប្រែងស្ដារឡើងវិញ ។ ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងទាំងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាគាំទ្រគម្រោងផ្សេងគ្នាជាច្រើន ដែលរួមចំណែកដល់ការសិក្សាស្រាវជ្រាវ ការអប់រំ និងការលើកកម្ពស់សិល្បៈ ។ តាមរយៈកិច្ចខិតខំប្រឹងប្រែងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានទទួលស្គាល់ថាជាភ្នាក់ងារដ៏ចម្បងសម្រាប់កម្មវិធីអប់រំអំពីប្រល័យពូជសាសន៍នៅក្នុងប្រព័ន្ធសិក្សាសាធារណៈនៅកម្ពុជា ។

ក៏ប៉ុន្ដែ ការអប់រំគឺគ្រាន់តែជាផ្នែកមួយនៃការពុះពាររបស់កម្ពុជាតែប៉ុណ្ណោះ ។ សេវាបណ្ណាល័យខ្សោយ និងការយល់ដឹង និងការប្រើប្រាស់របស់សាធារណជនចំពោះឯកសារ និងបណ្ណសារឯកសារនៅបន្ដជាឧបសគ្គក្នុងការពុះពាររបស់ប្រទេស




ម៉ាស៊ីនថតរូបម៉ាក ***Rolleiflex*** ផលិតនៅប្រទេសអាល្លឺម៉ង់ក្នុងទសវត្សរ៍៤០ ដែលធ្លាប់បានប្រើប្រាស់ដើម្បីថតរូបអ្នកទោសនៅមន្ទីរស-២១ ត្រូវបានប្រគល់ជូនមកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ថតរូបដោយ ៖ ហេង ជីវ័ន្ត

ដើម្បីធ្វើឲ្យមរតកវប្បធម៌ និងប្រវត្តិសាស្ត្ររស់ឡើងវិញ ។ តាមពិតកម្ពុជាបានទទួលរងគ្រោះដោយសង្គ្រាម អំពើឃោរឃៅ និងចលាចលក្នុងសង្គមរាប់ទសវត្សរ៍ ដែលញាំញីដល់ការសិក្សាជាន់ខ្ពស់ ការស្រាវជ្រាវ និងមរតកវប្បធម៌របស់ប្រទេសមួយនេះ ។ សូម្បីតែរហូតមកដល់សព្វថ្ងៃនេះហើយ ឯកសារចំនួនដ៏ច្រើន រូបថត កុនឯកសារ និងខ្សែអាត់សំឡេង កំពុងនៅរាយប៉ាយនិងស្ថិតក្នុងដៃបុគ្គលនិងស្ថាបន័ផ្សេងៗជុំវិញពិភពលោកនៅឡើយ ។ ក្នុងគោលបំណងស្តារឡើងវិញនូវការប្រើប្រាស់ឯកសារទាំងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាសូមអំពាវនាវឲ្យមានការផ្ញើអំណោយពីសំណាក់បុគ្គល និងស្ថាបន័ទាំងអស់ ។ ជាការពិតណាស់ បុគ្គល និងស្ថាបន័អាចមានការព្រួយបារម្ភអំពីការការពារការសម្ងាត់នៃប្រភពមួយចំនួន ។ មជ្ឈមណ្ឌលឯកសារកម្ពុជាយល់ច្បាស់ពីក្តីបារម្ភនេះ ហើយជឿជាក់ថា ដំណោះស្រាយដែលអាចសម្រេចទៅបាន នឹងអាចមានសម្រាប់ក្តីបារម្ភទាំងនោះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជា ជាស្ថាប័ននាំមុខក្នុងកិច្ចខិតខំប្រឹងប្រែងក្នុងការប្រមូល ចងក្រង និងផ្សព្វផ្សាយឯកសារទាំងអស់ដែលទាក់ទងនឹងសម័យខ្មែរក្រហម និងជាអ្នកឈានមុខគេដែលមានការទទួលស្គាល់ ក្នុងការពុះពារដើម្បីធានានូវការពិតការទទួលខុសត្រូវ និងយុត្តិធម៌នៅក្នុងបញ្ហាការរំលោភបំពានទ្រង់ទ្រាយធំ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា សូមអំពាវនាវឲ្យមានការផ្ញើអំណោយឯកសារដែលជាផ្នែកមួយនៃបេសកកម្មរបស់ខ្លួនក្នុងការផ្តល់ជូនកម្ពុជានូវការប្រើប្រាស់យ៉ាងទូលំទូលាយនូវប្រវត្តិសាស្ត្ររបស់ខ្លួនតាមរយៈការទុកដាក់ឯកសារដែលប្រមូលបាននៅក្នុងអគាររបស់ខ្លួន ។ **ឆាំង យុ**



លោក ឆាំង យុ កំពុងកាន់ម៉ាស៊ីនថតរូបម៉ាក *Rolleiflex* នៅក្នុងការិយាល័យរបស់លោកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលម៉ាស៊ីនថតរូបនេះត្រូវបានកម្មាភិបាលខ្មែរក្រហមប្រើដើម្បីថតរូបអ្នកទោសនៅមន្ទីរស-២១កាលពីរបបកម្ពុជាប្រជាធិបតេយ្យ មុនអ្នកទោសទាំងនោះត្រូវបានយកទៅធ្វើទារុណកម្ម និងសម្លាប់ ។ កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣ កន្លងទៅ ម៉ាស៊ីនថតរូបនេះ រួមទាំងរូបថត និងឯកសារជាច្រើនសន្លឹកត្រូវបានផ្តល់ជូនមកមជ្ឈមណ្ឌលឯកសារកម្ពុជាដោយលោក អ៊ឹង រ៉េងអៀង ដែលជាកូនប្រុសបង្កើតរបស់អតីតអ្នកទោស និងអ្នករួចរស់ជីវិតម្នាក់ពីមន្ទីរស-២១ ឈ្មោះ អ៊ឹង ប៉ិច ។ អ៊ឹង ប៉ិច គឺជាអ្នករៀបចំ និងចាត់ចែងប្រែក្លាយមន្ទីរស-២១ទៅជាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងក្នុងឆ្នាំ១៩៧៩ ។ ក្នុងទសវត្សរ៍៨០ អ៊ឹង ប៉ិច បានប្រើមាស៊ីនថតរូបមួយនេះដើម្បីថតរូបទិដ្ឋភាពឧក្រិដ្ឋកម្មទាំងឡាយដែលបានកើតឡើងក្នុងរបបខ្មែរក្រហម និងបានថតរូបរណ្តៅសាកសពជាច្រើនទូទាំងប្រទេស ។ អ៊ឹង រ៉េងអៀង បានប្រគល់ម៉ាស៊ីនថតរូប រូបថត វីដេអូ និងឯកសារមកមជ្ឈមណ្ឌលឯកសារកម្ពុជានេះ ដោយសារតែលោកមិនសប្បាយចិត្តព្រោះពេលថ្មីៗនេះមានការបកស្រាយខុសទាក់ទងទៅនឹងប្រវត្តិសាស្ត្រពិតនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។ អ៊ឹង រ៉េងអៀង ដែលមានឪពុកធ្លាប់ជាប់ឃុំឃាំងនៅមន្ទីរស-២១ បានអះអាងថា ឪពុករបស់គាត់បានឆ្លងកាត់អំពើទារុណកម្ម និងការឈឺចាប់ឥតគណនាយ៉ាងពិតប្រាកដនៅមន្ទីរស-២១កាលពីរបបកម្ពុជាប្រជាធិបតេយ្យ ហើយអំពើឃោរឃៅដែលបានកើតឡើងនៅមន្ទីរស-២១ គឺកើតមានយ៉ាងពិតប្រាកដ មិនមែនជារឿងប្រឌិតទេ ។ អ៊ឹង រ៉េងអៀង បានបញ្ជាក់ទៀតថា មាស៊ីនថតរូបមួយនេះអាចផ្តល់ជាភ័ស្តុតាងបន្ថែមទៀតទាក់ទងនឹងការពិតដែលបានកើតឡើងនៅមន្ទីរស-២១ ។ **ញាណ សុជាតិ**

# ពេញដោយក្តីសង្ឃឹមជាមួយអ៊ុនតាក់

តាមរយៈសេចក្តីអញ្ជើញពីសាស្ត្រាចារ្យ វីលៀម ម៉ាលី នាយកមហាវិទ្យាល័យការទូតនៃអាស៊ីប៉ាស៊ីហ្វិករបស់សាកលវិទ្យាល័យជាតិអូស្ត្រាលី ខ្ញុំបានធ្វើដំណើរទស្សនកិច្ចទៅកាន់ទីក្រុងមែលបន និងរដ្ឋធានីកង់បេរ៉ាកាលពីចុងខែខែសភាកន្លងទៅដើម្បីចូលរួមខួបលើកទី២០នៃការបោះឆ្នោតនៅប្រទេសកម្ពុជាដែលរៀបចំឡើងដោយអាជ្ញាធ័របណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជា ហៅកាត់ថា អ៊ុនតាក់។ ពេលដែលខ្ញុំកំពុងតែត្រៀមកិច្ចការមួយចំនួនសម្រាប់ខួបលើកទី២០នេះ ខ្ញុំបានបើកមើលរូបថតចាស់ៗមួយចំនួន រួមទាំងរូបថតមួយសន្លឹកនៅក្នុងអត្ថបទនេះផង។ តាមរយៈរូបថតនេះ អ្នករាល់គ្នាអាចយល់បានថា កាលនោះខ្ញុំគឺជាយុវជនខ្មែរ-អាមេរិកាំងវ័យក្មេងម្នាក់ក្នុងសម្លៀកបំពាក់ ពាក់កណ្តាលយោធានិងពាក់កណ្តាលស៊ីវិល។ តាមរយៈកាយវិការដែលខ្ញុំថត និងតាមរយៈអាវការពារគ្រាប់កាំភ្លើងដែលខ្ញុំពាក់ អ្នករាល់គ្នាអាចនឹងគិតថាខ្ញុំមានសុវត្ថិភាព និងសុខស្រួលចំពោះហេតុការណ៍ទាំងឡាយនៅជុំវិញខ្លួនខ្ញុំ។ ខ្ញុំថែមទាំងញញឹមតិចៗដាក់ម៉ាស៊ីនថតទៀតផង។ ប៉ុន្តែតាមអ្វីដែលអ្នករាល់គ្នាអាចឃើញនេះគឺគ្រាន់តែជាការបំភាន់តែប៉ុណ្ណោះ។

ខ្ញុំត្រូវបានចាត់តាំងឲ្យទៅប្រចាំការនៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺក្នុងនាមជាបុគ្គលិកអន្តរជាតិរបស់អ៊ុនតាក់ ដើម្បីគាំទ្រ



លោក ឆាំង យុ ក្នុងខែកញ្ញា ឆ្នាំ១៩៩៣ ក្នុងស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ក្នុងអំឡុងពេលលោកបម្រើការជាមួយអ៊ុនតាក់។

កិច្ចការបោះឆ្នោតក្នុងអំឡុងពីឆ្នាំ១៩៩២ ដល់ឆ្នាំ១៩៩៣ ។ ក្នុងអំឡុងពេលបោះឆ្នោតដែលបានរៀបចំឡើងដោយអ៊ុនតាក់ មានស្ថានីយបោះឆ្នោតចំនួន១០១កន្លែង ហើយទីតាំងដែលខ្ញុំប្រចាំការមានអ្នកបោះឆ្នោតចំនួន២៥០.០០០នាក់ ។ កាលនោះ ពាក់កណ្តាលនៃផ្ទៃដីខេត្តកំពង់ស្ពឺទាំងមូលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងកម្លាំងខ្មែរក្រហម ហើយក្នុងនាមជាជនជាតិខ្មែរម្នាក់ ខ្ញុំគឺជាគោលដៅគំរាមកំហែងរបស់ខ្មែរក្រហមដែលរារាំងមិនឲ្យមានការបោះឆ្នោត ។ ខ្ញុំអាចទាក់ទងជាមួយម្ចាស់ឆ្នោត និងស្តាប់វិទ្យុទាក់ទងខ្មែរក្រហមបានតាមរយៈអាយកូមរបស់ខ្ញុំ ។ តាមរយៈឧបករណ៍នេះ ខ្ញុំមានអារម្មណ៍ស្រួលចិត្ត និងមានភាពស្ទាត់ជំនាញក្នុងការបត់បែនតាមបែបផែន និងជីវភាពរស់នៅរបស់អ្នកស្រុក ហើយអ្នកភូមិនៅមូលដ្ឋានរាប់អាននិងចាត់ទុកខ្ញុំជាអ្នកភូមិម្នាក់នៅក្នុងស្រុកភូមិដែរ ។ កាលនោះលេខកូដអាយកូមរបស់ខ្ញុំគឺអេកូ ១៥ *throat fish* (បំពង់កត្រី) ។

ស្រុកភ្នំស្រួចគឺជាតំបន់ដ៏តានតឹងក្នុងឆ្នាំ១៩៩៣ ដែលកាលនោះ តំបន់នោះស្ថិតក្នុងទឹកដីគ្រប់គ្រងដោយខ្មែរក្រហម ។ តំបន់នោះពោរពេញទៅដោយគ្រាប់មីន ។ កន្លែងនោះគឺជាទីតាំងដ៏គ្រោះថ្នាក់ និងគួរឲ្យស្ញើប ។ ខ្ញុំទទួលនូវការគំរាមកំហែងជាច្រើនលើកច្រើនសាពីសំណាក់ខ្មែរក្រហម ។

ម្តងនោះ មុននឹងខ្ញុំទៅដល់ការិយាល័យរបស់ ខ្ញុំខ្មែរក្រហមបានចូលមកបង្កប់គ្រាប់មីនតាមផ្លូវពីបន្ទប់ទឹកទៅការិយាល័យរបស់ខ្ញុំដែលជាបន្ទប់មានរាងដូចឃ្លាំងផ្ទុកទំនិញ ។ ជាអកុសលសមាជិកក្រុមរបស់ខ្ញុំម្នាក់បានដើរជាន់មីននោះធ្វើឲ្យគាត់ទទួលរងរបួសធ្ងន់ធ្ងរនិងពិការជើង ។ កាលនោះ រថយន្តរបស់ខ្ញុំខូចមួយថ្ងៃពេញនៅក្នុងព្រៃមុនហេតុការណ៍នោះកើតឡើង ហើយខ្ញុំមិនចេះជួសជុលរថយន្តទេ ។

តាមការពិត នេះជាកំហុសរបស់ខ្ញុំ ។ ខ្ញុំមិនចេះពីវិធីដូរប្រេងម៉ាស៊ីនរថយន្តទេពេលនោះ ។ ខ្ញុំចេះតែបើករថយន្តទៅមុខរហូតទាល់តែថ្ងៃមួយរថយន្តនោះផ្ទុះផ្សែងចេញមកក្រៅទើបខ្ញុំដឹងថារថយន្តនោះខូច ។ ដោយឃើញមានផ្សែងចេញពីម៉ាស៊ីន ខ្ញុំក៏ប្រើវិទ្យុទាក់ទងទៅមន្ត្រីអង្គការសហប្រជាជាតិដើម្បីសុំជំនួយ ។ ទាល់តែមួយថ្ងៃក្រោយមកទើបមន្ត្រីអង្គការសហប្រជាជាតិម្នាក់មកដល់ ។ រថយន្តរបស់ខ្ញុំបានខូចក្រោយកងទ័ពខ្មែរក្រហមដើរល្បាតឆ្លងកាត់តំបន់នោះបានបន្តិច ។ បើសិនជារថយន្តរបស់ខ្ញុំខូចមុននោះតែបន្តិច ម៉្លេះខ្ញុំត្រូវខ្មែរក្រហមចាប់ និងសម្លាប់បាត់ទៅហើយ ។

ពេលខ្ញុំប្រាប់ពីដំណឹងនេះ អង្គការសហប្រជាជាតិមានក្តីបារម្ភពីសុវត្ថិភាពរបស់ក្រុមយើងជាខ្លាំង ហើយក៏ប្រគល់អាវក្រោះតូចមួយដូចនៅក្នុងរូបថតនេះ ។ អាវក្រោះការពារគ្រាប់កាំភ្លើងនេះគឺជាអាវសេរីចាស់យកមកពីកងយោធារបស់ប្រទេសប៊ុលការី ។ ពេលនោះ អាកាសធាតុក្តៅណាស់ ធ្វើឲ្យខ្ញុំមិនអាចពាក់អាវនោះឲ្យបានជាប់លាប់ទេ ។ ខ្ញុំមិនដឹងថាអាវនេះអាចជួយជីវិតខ្ញុំបានប៉ុណ្ណាទេ តែអាវនោះស្អាត ហើយខ្ញុំពាក់អាវនេះដោយសារតែវាមានរាងសមនឹងខ្ញុំ ។ នៅកន្លែងដែលខ្ញុំប្រចាំការកាលពីជំនាន់អ៊ុនតាក់ កងយោធាប៊ុលការីមាននាទីរក្សាសន្តិសុខ ចំណែកឯកងយោធារបស់អូស្ត្រាលីមាននាទីទំនាក់ទំនងបណ្តាញយោធា ។ សញ្ញាណហៅចូលគឺ *FCU* កំពង់ស្ពឺ *SPOE* បន្ទាន់ ។

ពេលសម្លឹងទៅមើលអតីតកាល ខ្ញុំអាចនិយាយបានថាកាលនោះស្ថានភាពមានភាពគ្រោះថ្នាក់ និងផ្សងព្រេងជាខ្លាំងតែជាមួយគ្នានេះដែរ កិច្ចខិតខំប្រឹងប្រែងរបស់យើងពិតជាមានសារសំខាន់ណាស់សម្រាប់អនាគតប្រទេសកម្ពុជា ។

ពេលនោះ ខ្មែរក្រហមបានធ្វើការគំរាមកំហែងយ៉ាងពិតប្រាកដ ។ ខ្មែរក្រហមបានបំភិតបំភ័យ និងសម្លាប់ប្រជាពលរដ្ឋដោយកំហឹង ។ តែបើយើងក្រឡេកមកមើលពេលបច្ចុប្បន្នវិញខ្មែរក្រហមស្ទើរតែទាំងអស់បានផ្តាច់ខ្លួន និងបានចុះចូលជាមួយរដ្ឋាភិបាល ហើយនៅខណៈនេះ មេដឹកនាំរបស់ខ្លួនកំពុងតែទទួលរងនូវការកាត់ទោសក្រោមបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

នេះគឺជាការតស៊ូដ៏ស្វិតស្វាញ និងវែងឆ្ងាយមួយ ហើយកាលនោះដែរ ខ្ញុំគឺជាយុវជនវ័យក្មេង ក្រអឺតក្រទម និងលេលាម្នាក់ ប៉ុន្តែពេលខ្លះពិភពលោកចង់បានភាពលេលារបស់យុវជនបែបនេះ ។

**ឆាំង យុ**

# ដំណើរវិលត្រឡប់នៃរូបចម្លាក់ "បនទេវៈ"

បន្ទាប់ពីចាកចេញពីមាតុភូមិកំណើតអស់រយៈពេលជាង ៤០ឆ្នាំ រូបចម្លាក់ «បនទេវៈលុតជង្គង់» ដែលបានសង់ឡើងក្នុងសតវត្សរ៍ទី១០ ត្រូវបានសារមន្ទីរសិល្បៈមេត្រូប៉ូលីតែនប្រគល់មកប្រទេសកម្ពុជាវិញនៅល្ងាចថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣ ។

រូបចម្លាក់នោះ ត្រូវបាននាំយកទៅដួលដុលនៅសារមន្ទីរជាតិ រួចបញ្ជូនទៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី ជាទីដែលត្រូវបានដាក់តាំងបង្ហាញដល់កិច្ចប្រជុំគណកម្មាធិការបេតិកភណ្ឌពិភពលោក ។ ការប្រគល់រូបចម្លាក់នេះ គឺជាព្រឹត្តិការណ៍ដ៏សំខាន់ ហើយប្រទេសកម្ពុជាគួរតែចាប់យកអត្ថប្រយោជន៍តាមរយៈដំណើរវិលត្រឡប់មកនេះ ។ ប៉ុន្តែទន្ទឹមពេលដែលវាមានសារសំខាន់ដែលប្រទេសកម្ពុជាបង្ហាញអំពីភាពជោគជ័យនៃការវិលត្រឡប់នៃរូបចម្លាក់ទាំងពីរនេះ វាក៏មានសារសំខាន់ដែលយើងសម្រេចបាននូវដំណើរវិលត្រឡប់នេះ ។ ការបញ្ជូនរូបចម្លាក់នេះត្រឡប់ទៅកន្លែងដើមវិញ នឹងក្លាយជានិមិត្តរូបដ៏សំខាន់នៃភាពជោគជ័យរបស់ប្រទេសកម្ពុជាក្នុងការស្តារអតីតកាលរបស់ខ្លួន ។ ពិតប្រាកដណាស់ ដំណើរវិលត្រឡប់នៃរូបចម្លាក់ទាំងពីរនេះ នឹងនាំយកនូវអត្ថន័យជានិមិត្តរូបដ៏អស្ចារ្យ ដែលប្រជាជនកម្ពុជាបានតស៊ូដ៏យូរអង្វែងក្នុងការស្វែងយល់ និងដោះស្រាយនូវអតីតកាលរបស់ខ្លួន ។

ប្រវត្តិសាស្ត្រកម្ពុជា ត្រូវបានកំណត់ដោយព្រឹត្តិការណ៍ពីរដាច់ដោយឡែកពីគ្នា ដូចជា សម័យកាលអង្គរដ៏រុងរឿង និងសម័យកាលជាច្រើនឆ្នាំនៃអំពើប្រល័យពូជសាសន៍ ។ ប្រទេសកម្ពុជា បានទទួលរងគ្រោះពីសង្គ្រាមជាច្រើនទសវត្សរ៍ និងអំពើយង់ឃ្នងជាច្រើន ដែលផ្ទុយទៅនឹងអតីតកាលក្នុងសម័យអង្គរដ៏ស្រស់ផូរផង់របស់ខ្លួន ។ ព្រឹត្តិការណ៍ទាំងនេះ បានបំផ្លាញដល់



រូប «បនទេវៈលុតជង្គង់» បានដាក់តាំងនៅសារមន្ទីរសិល្បៈម៉េត្រូប៉ូលីតែន ចាប់ពីឆ្នាំ១៩៩៤ ដល់ខែមិថុនា ឆ្នាំ២០១៣ ។ រូបថត ៖ សារមន្ទីរសិល្បៈម៉េត្រូប៉ូលីតែន

សរសៃឈាមសង្គមកម្ពុជា ក្រៅពីបណ្តាលឲ្យមានការបាត់បង់ជីវិតមនុស្ស ។ ទន្ទឹមពេលដែលការលួចប្លន់ខុសច្បាប់ និងការជួញដូរសម្បត្តិវប្បធម៌មួយផ្នែកជាលទ្ធផលនៃព្រឹត្តិការណ៍នេះ ការលួចប្លន់ខុសច្បាប់ និងការជួញដូរសម្បត្តិវប្បធម៌នោះបានគំរាមកំហែងដល់អត្តសញ្ញាណវប្បធម៌ ។ សូម្បីតែសព្វថ្ងៃ វត្ថុបុរាណរបស់ប្រទេសកម្ពុជា នៅតែបន្តប្រឈមនឹងហានិភ័យនៃការលួចប្លន់ និងការលក់នៅទីផ្សារខុសច្បាប់ ។

បច្ចុប្បន្ន ប្រទេសកម្ពុជាកំពុងតែងើបឡើងចេញពីភាពភ័យខ្លាចនៃអតីតកាលរបស់ខ្លួន តាមរយៈកិច្ចខិតខំប្រឹងប្រែង និងយន្តការផ្សេងៗ ។ ការផ្តន្ទាទោសឧក្រិដ្ឋកម្មខ្មែរក្រហមត្រូវបានប្រព្រឹត្តឡើងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយកម្មវិធីអប់រំអំពើប្រល័យពូជសាសន៍បានធ្វើឡើងដំណាលគ្នានៅតាមជនបទ ។ ដោយអនុលោមតាមច្បាប់អន្តរជាតិ និងច្បាប់ប្រទេសកម្ពុជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងតែខិតខំនាំយកយុត្តិធម៌ដល់ជនរងគ្រោះនៃរបបខ្មែរក្រហម ។ ក្រៅពីនេះ កម្មវិធីអប់រំអំពើប្រល័យពូជសាសន៍ បង្រៀនយុវជនជំនាន់ក្រោយអំពីប្រវត្តិសាស្រ្តនៃសម័យកាលដ៏គួរឲ្យសោកសៅនេះ ។ ដោយមានចំណាប់អារម្មណ៍លើការពិភាក្សា ការផ្សះផ្សា និងការយល់ដឹងរបស់សាធារណជន ក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈមណ្ឌលឯកសារកម្ពុជា នឹងខិតខំកសាងមូលដ្ឋានស្វែងរកការពិត និងការចងចាំ ។ ដូចគ្នានេះដែរ ការស្តារបេតិកភណ្ឌវប្បធម៌របស់ប្រទេសកម្ពុជា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយព្យាបាលស្នាមរបួសអតីតកាលរបស់ប្រជាជនកម្ពុជា និងការសម្រេចបានការផ្សះផ្សា ។ ការផ្សះផ្សា គឺស្តីពីការប្រមូលផ្តុំមនុស្ស ការស្តារទំនាក់ទំនង និងការកសាងសង្គមកាន់តែប្រសើរ ។ ការការពារ និងការស្តារបេតិកភណ្ឌវប្បធម៌របស់ប្រទេសកម្ពុជា បានរួមចំណែកដល់ដំណើរការនេះតាមរយៈការផ្សារភ្ជាប់ប្រជាជនកម្ពុជាទៅនឹងអតីតកាលដ៏អស្ចារ្យរបស់ខ្លួន ។

ក្នុងន័យនេះ ការប្រគល់ត្រឡប់មកវិញនៃរូបចម្លាក់បនទេវៈលុតជង្គង់ មានសារសំខាន់ដល់ប្រជាជនកម្ពុជា ។ ការប្រគល់ត្រឡប់មកវិញនេះ បង្ហាញអំពីនិមិត្តរូបដល់ការស្តារអត្តសញ្ញាណសាសនា និងវប្បធម៌របស់ប្រទេសកម្ពុជា ។ ក្រៅពីនេះ ដោយមានការតាំងបង្ហាញសាធារណជន និងការពិភាក្សាអំពីការវិលត្រឡប់មកវិញនៃរូបចម្លាក់ទាំងពីរនេះ ប្រជាជនកម្ពុជានឹងបង្កើតការយល់ដឹងច្រើនជាងមុន អំពីបេតិកភណ្ឌវប្បធម៌របស់ខ្លួន ។ ឥទ្ធិពលនេះបានធ្វើឲ្យការតាំងបង្ហាញដល់សាធារណជនក្លាយជា



រូបចម្លាក់ «បនទេវៈលុតជង្គង់» ពេលមកដល់ព្រលានយន្តហោះអន្តរជាតិភ្នំពេញ កាលពីល្ងាចថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣ តាមជើងហោះហើរ Dragon Air ។



ការដួសដុលរូបចម្លាក់នៅសារមន្ទីរជាតិភ្នំពេញ ដែលការដួសដុលនេះបានបញ្ចប់នៅរសៀលថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ ហើយបានដឹកទៅកាន់វិមានសន្តិភាព

ផ្នែកមួយដ៏សំខាន់នៃការវិលត្រឡប់មកវិញនៃរូបចម្លាក់ទាំងនោះ ។

លើសពីនេះ ការវិលត្រឡប់មកវិញនៃរូបចម្លាក់ទាំងនោះ កើតឡើងចំពេលដែលប្រទេសកម្ពុជាធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំគណៈកម្មាធិការបេតិកភណ្ឌពិភពលោកលើកទី៣៧ ។ ព្រឹត្តិការណ៍នេះ មានសារសំខាន់ដល់ប្រទេសកម្ពុជា និងពិភពលោក ហើយរូបចម្លាក់ទាំងនោះ នឹងបង្កើតចំណែកដ៏សំខាន់នៃព្រឹត្តិការណ៍នេះតាមរយៈការជំរុញឲ្យសហគមន៍អន្តរជាតិទទួលខុសត្រូវកាន់តែខ្លាំងជាងមុន ក្នុងការការពារ និងស្តារបេតិកភណ្ឌវប្បធម៌របស់ប្រទេសដែលរងការលួចប្លន់ ។

ប៉ុន្តែបន្ទាប់ពីបេតិកភណ្ឌទាំងនោះ ត្រូវបានស្តារឡើងវិញ ហើយសារដ៏សំខាន់នេះត្រូវបានប្រជាជនជ្រួលជ្រាបនោះ យើងគួតែបញ្ចប់ដំណើរបញ្ជូនរូបចម្លាក់នោះទៅកន្លែងដើមវិញ ។ ការបញ្ជូនរូបចម្លាក់ត្រឡប់ទៅកន្លែងដើមវិញ នឹងនាំយកមកនូវការបញ្ចប់សម័យកាលដ៏សោកសៅមួយនេះ ហើយវានឹងបង្ហាញជានិមិត្តរូបអំពីដំណាក់កាលដ៏សំខាន់ផ្សេងទៀត ក្នុងការស្តារអតីតកាលរបស់ប្រទេសកម្ពុជា ។ **ស៊ីរ៉ុ សាទីណា**



រូបចម្លាក់ «បនទេវៈលត់ជង្គង់» ដាក់តាំងនៅវិមានសន្តិភាព

# គោរពជូនអង្គការ ៨៧០

២០៧ : ខ្ទង់

សូមរាយការណ៍បន្ថែមពីសភាពការណ៍ថៃ នៅលក្ខ៤៤ ព្រំប្រទល់ខ្មែរថៃ គឺលក្ខ៤៤ នៅជាប់ភូមិថ្មី នៅខាងលិចភូមិយាង ដីយើង ហើយភូមិនេះវាចូលមក ចូលក្នុងដីជម្រៅ២គីឡូជាង កន្លែងនេះយើងវាយហើយកាន់កាប់អត់ថយទេ ហើយទល់មុខភូមិថ្មីថៃនោះតែម្តង ។

បងប្អូនស្នើវាយអាភូមិថ្មីអស់តែម្តង ការនេះខ្ញុំមិនសម្រេចឲ្យវាយទេ ដែលបងប្អូននៅទល់មុខគ្នា ឲ្យថយប្រុងប្រយ័ត្នខ្លាំងវាវាយកម្លាំងយើងបាន ។

ដល់យើងមិនឲ្យវាមកប្រូតស្រូវ តើសភាពប៉ះទង្គិចគ្នាជៀសមិនផុត ដូច្នេះ ស្នើអង្គការមានមតិយ៉ាងណាបញ្ហានេះ សូមតប ។ នៅថ្ងៃ១៦ យន្តហោះថៃបានបាញ់រះនៅភូមិល្បើកស្វាយ ក្នុងដីយើងជម្រៅ២.៥០០ “ពីពាន់ប្រាំរយ” ម៉ែត្រនៅខាងជើងភូមិយាង ចម្ងាយ៩គីឡូ គ្មានខូចខាតអីទេ ឯវិធានការខ្ញុំបានណែនាំហើយឲ្យប្រយ័ត្នខបាយកល វាធ្វើសកម្មភាពនេះរួចវាវាយកន្លែងផ្សេងឲ្យខ្លាំង ត្រូវប្រយ័ត្នគ្រប់សញ្ញាទាំងអស់ ។

ដោយភាតរភាពបដិវត្តន៍យ៉ាងកក់ក្តៅបំផុត ។

ញឹម

ថ្ងៃ១៧-២-៧៨

ទទួលថ្ងៃ១៨-២-៧៨ ម៉ោង១០:៣០នាទី

ចម្លងជូន: អ៊ំ, អ៊ំនួន, បងវ៉ាន់, បងវន, មន្ទីរ, ឯកសារ **(ឯកសារទូរលេខ J០២០៥០)**

---

# គោរពជូនគណៈ ៨៧០ ជាទីស្នេហា និងរព្វក

ទូរលេខ : ៥២

៨៧៤ : ខ្ទង់

សូមរាយការណ៍អំពីសភាពការណ៍មួយចំនួនដូចខាងក្រោម :

១) អំពីសភាពការណ៍ខ្មាំង : ខ្មាំងតាមព្រំដែនថៃ នៅថ្ងៃ១០-៨ ម៉ោង៩ព្រឹក វាបាញ់កាំភ្លើង៦០មីលីម៉ែត្រចំនួន៣គ្រាប់ និងអ៊ឹម៧៩ ចំនួន១គ្រាប់ចូលដីយើង ព្រមទាំងមានយន្តហោះដើងស្តោក១គ្រឿង លើកទីមួយ វាហោះចូលដីយើងចំនួនមួយគីឡូម៉ែត្រ លើកទី២ វាហោះពីរគ្រឿងធុនដដែល វាបាញ់អស់រយៈពេល១៥នាទីទើបឈប់ ពេលនោះយើងបាញ់តបតជាមួយវាវិញ វាក៏ហោះត្រឡប់ទៅដីវាវិញ ។

១-ក្នុងរយៈកន្លងទៅនេះ ខ្មាំងនៅតាមព្រំដែនវាមានការប្រុងប្រយ័ត្នជាប់ វាបានមកត្រៀមចាំយើងចម្ងាយពីព្រំដែន ៥០០ម៉ែត្រ គ្នាវាចំនួន១កងអនុសេនាធំជារៀងរាល់ថ្ងៃ ។

សភាពការណ៍ព្រំដែនថៃ និងយើងក្នុងពេលប៉ុន្មានថ្ងៃនេះពួកប្រតិកិរិយាថៃមានរៀបចំកម្លាំង កងទ័ពវាមកធ្វើសកម្មភាពតាមព្រំដែន មានយករថក្រោះមកលាក់នៅភូមិដាន ៧គ្រឿង និងភូមិតាទុំ ៥គ្រឿង ខាងកើតភូមិតាទុំមានរថក្រោះទៀត តែក្តាប់ចំនួន

*មិនបាន ចំណែកពួកទាហាន កន្លែងដែលមិនទាន់ធ្លាប់នៅភូមិក៏មានទាហានដែរ ។ តែវាគ្មានចូលដីយើងទេ នៅតែក្នុងដីវាប៉ុណ្ណោះ ។*

*២-ថ្ងៃ១៩-៨ មុខសញ្ញាហាលៀម យើងពិនិត្យព្រំដែន ជួបថៃបីនាក់នៅព្រំដែន ដែលពេលនោះយើងចាប់យកមកពាក់កណ្ដាលផ្លូវ វាដកកាំបិតបម្រុងចាក់យើង យើងក៏បាញ់ចោលទាំងបីនាក់ទៅ ។*

*៣-ថ្ងៃ២០-៨ យន្តហោះធុនម៉ិច៣គ្រឿង ហោះលើភូមិរំដួល លើកទីមួយ ចំនួន២គ្រឿង លើកទីពី ចំនួន១គ្រឿង ។*

*៤-ថ្ងៃ២១-៨ យន្តហោះធុនម៉ិច១គ្រឿងហោះលើភូមិបុសទៀត ។ នៅមុខសញ្ញាខាងជើងភូមិទន្សាយអារាក់ តាមព្រំដែនយើងទេ យើងឡើងទៅធ្វើការជួបទាហានថៃនៅព្រំដែន បាញ់វារបួស៦នាក់ យើងឃើញវាសែងរត់ទៅ ។*

*វិធានការយើងបន្តបោសសម្អាត និងចាក់ចម្រូងថែម និងប្រុងប្រយ័ត្នត្រៀមប្រយុទ្ធការពារព្រំដែនជាប់ជានិច្ច ។*

*ខ្មាំងខាងក្នុង ៖ ក្នុងរយៈប៉ុន្មានថ្ងៃនេះ យើងបានរកឃើញខ្មាំងបង្កប់ក្នុងជួរ និងក្នុងប្រជាជនជាបន្តបន្ទាប់ ហើយចាប់អាខ្មាំងទាំងនោះបានជាបន្តបន្ទាប់ យើងម្ចាស់ការលើខ្មាំង ហើយមានវិធានការទាន់ពេលវេលា គ្មានបណ្ដោយឲ្យប្រែប្រួលអ្វីទេនៅធម្មតា ។*

*១-វិធានការ យើងបន្តបោសសម្អាត និងប្រុងប្រយ័ត្នខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងទាំងនោះជាបន្តបន្ទាប់ទៀត ។*

*២-សភាពការណ៍ប្រជាជន ៖ ក្នុងរយៈកន្លងទៅគ្មានអ្វីប្រែប្រួលទេ ។ ទាំងនយោបាយសតិអារម្មណ៍ចាត់តាំង មានសន្ទុះវាយសម្រុក បង្កបង្កើនផល បានជាបន្តបន្ទាប់ ។*

*ខាងជីវភាពស្បៀងបានដោះស្រាយធូរស្រាល១កម្រិត មានកម្លាំងបន្តរលួម វាយសម្រុកបាន មិនប៉ះពាល់ដល់ការវាយសម្រុកធំដុំទេ មានប៉ះពាល់បន្តិចបន្តួច ដោយកន្លែងខ្វះកម្លាំងទ្រុឌទ្រោម តែតិចទេ ។*

*៣-សភាពការណ៍បង្កបង្កើនផល ៖ មកដល់ថ្ងៃនេះភ្លៀងធ្លាក់ទូទៅ ទាំងភូមិភាគហើយ ។ សព្វថ្ងៃនេះ កំពុងតែបើកវគ្គធំ ។ ទាំងតំបន់៤៤ ទាំងតំបន់១០៣ តាមស្រុកនីមួយៗ ស្រុកខ្លះធ្លាក់ភ្លៀងមុន ស្រុកខ្លះធ្លាក់ភ្លៀងក្រោយ សរុបលទ្ធផលស្ទូងហើយស្រុកខ្លះស្ទូង បាន១០-១០ភាគរយ ស្រុកខ្លះបាន២០-២០ភាគរយ ស្រុកខ្លះបាន៣០-៣០ភាគរយ ស្រុកខ្លះពី៥០ទៅ៦០-៦០ភាគរយ បើសរុបទូទៅ ក្នុងភូមិភាគទាំងមូលគិតតាមដីស្រែដែលត្រូវស្ទូង យើងស្ទូងហើយ៣០-៣០ ភាគរយហើយ ។ វិធានការ ៖ យោងទៅតាមភ្លៀងទើបនឹងធ្លាក់ ។ ដូច្នេះខែ៨ វាយមិនដាច់ទេ លុះដល់ខែ៩ ទើបវាយដាច់ ។*

*២) ក្នុងការវាយផ្ដាច់នេះបានមានវិធានការទាំងភាគ ទាំងតំបន់ ទាំងស្រុក ត្រូវចុះសមរភូមិប្រយុទ្ធ ដើម្បីណែនាំប្រយុទ្ធផ្ទាល់ ទន្ទឹមនឹងនេះតម្រែតម្រង់ឲ្យបានទាន់ពេលវេលា ។*

*ជូនពរសុខសប្បាយ និងជ័យជម្នះ*

*ភូមិភាគ៨០១ សែ*

*ថ្ងៃ២៣-៨ ទទួលថ្ងៃ២៤-៨-៧៧ ម៉ោង១៦-៤៥នាទី* ***(ឯកសារចូរលេខ D០១៩៦២)***

***បញ្ជាក់*** *៖ ញឹម គឺជាឈ្មោះបដិវត្តន៍របស់ ញឹម រស់ លេខាភូមិភាគពាយ័ព្យក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ "អឺ" គឺសំដៅទៅលើ ប៉ុល ពត ។ "វ៉ាន់" គឺជាឈ្មោះបដិវត្តន៍របស់ អៀង សារី រដ្ឋមន្ត្រីការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ "នួន" គឺឈ្មោះបដិវត្តន៍របស់ នួន ជា ។ "វ៉ន" ឈ្មោះបដិវត្តន៍របស់ វ៉ន វ៉េត រដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច ។ អគ្គការ៨៧០ គឺជាមន្ទីររបស់គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ជាកន្លែងដែលសមាជិកគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាប្រជុំដើម្បីសម្រេចកិច្ចការរបស់បក្ស ។ ទីតាំងរបស់អគ្គការ៨៧០បានផ្លាស់ប្ដូរជាច្រើនកន្លែង ប៉ុន្តែទីតាំងដែលត្រូវបានដឹងជាទូទៅគឺនៅជិតព្រះបរមរាជវាំង ។ អគ្គការ៨៧០ដឹកនាំដោយ ខឿន និង ឈឹម សំអោក ហៅ ប៉ង់ ។ អ្នកទាំងពីរត្រូវបានបញ្ជូនទៅមន្ទីរស-២១ និងស្លាប់នៅទីនោះ ។ សែ គឺជាឈ្មោះបដិវត្តន៍របស់ កង ចាប ។ ភូមិភាគ៨០១ គឺលេខកូដរបស់ភូមិភាគឧត្តរ ដឹកនាំដោយ កង ចាប ហៅ សែ ។*

# ចម្លើយសារភាព ម៉ែន ជុន ហៅ ហឹង្ស លេខាតំបន់៥

ម៉ែន ជុន ហៅ ហឹង្ស អាយុ៣៦ឆ្នាំ លេខាតំបន់៥ ភូមិភាគពាយ័ព្យ ។ ហឹង្ស ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ បន្ទាប់មកបានបញ្ជូនមកឃុំឃាំងនៅមន្ទីរ ស-២១ ។ ហឹង្ស បានឆ្លើយសារភាពចប់នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៧៧ ដោយមានឈ្មោះ ឈិន និងឈ្មោះ វ៉ុន ជាអ្នកសួរចម្លើយ ។

នៅក្នុងចម្លើយសារភាពសម្រាស់ ១០២ទំព័រ ហឹង្ស បានរៀបរាប់ពីសកម្មភាពរបស់ខ្លួនជាច្រើនដែលក្បត់នឹងអង្គការ រួមមាន អប់រំយុវជនឲ្យស្រលាញ់របបសេរី បង្កប់ខ្លួនក្នុងជួរបដិវត្តន៍ដើម្បីកសាងកម្លាំងក្បត់ បម្រើសេអ៊ីអា ទាក់ទងជាមួយ អ៊ុន តាំ ដើម្បីវាយរំលំបដិវត្តន៍ ។ ប៉ុន្តែទោះបីយ៉ាងណា យើងមិនដឹងថាចម្លើយទាំងអស់នេះពិត ឬយ៉ាងណានោះទេ ព្រោះគាត់ត្រូវឆ្លងកាត់ការធ្វើទារុណមុននឹងយកទៅសម្លាប់ ។ ខាងក្រោមនេះ គឺជាការដកស្រង់ចម្លើយសារភាពរបស់សាម៉ីខ្លួនផ្ទាល់ៈ

ខ្ញុំមានស្រុកកំណើតនៅភូមិកំពង់ចិន ឃុំកំពង់ចិន ស្រុកស្ទោង ខេត្តកំពង់ធំ ។ នៅឆ្នាំ១៩៤៨ ខ្ញុំបានចូលរៀនថ្នាក់កុមារដ្ឋាននៅសាលាបឋមសិក្សាស្ទោង ។ មួយឆ្នាំក្រោយមក ឪពុកម្តាយខ្ញុំបានមកផ្លាស់មករស់នៅភូមិថ្មគរ ឃុំកោះរះ ស្រុកល្វាឯម ខេត្តកណ្តាល ។ ខ្ញុំស្នាក់នៅភូមិកោះរះបានមួយឆ្នាំ ទើបឪពុករបស់ខ្ញុំបាននាំក្រុមគ្រួសារមករស់បឹងកេងកង ក្រុងភ្នំពេញ ដោយគាត់ប្រកបរបរធ្វើជាងមាស ចំណែកខ្ញុំបានចូលរៀនបន្តនៅសាលាបឹងកេងកង ។

លុះដល់ឆ្នាំ១៩៥៦ ខ្ញុំបានចូលរៀននៅសាលាកម្ពុជបុត្រ ដោយពេលនោះ ខ្ញុំបានទទួលការអប់រំពីឈ្មោះ ទាន់ សុវណ្ណ មានបងថ្លៃធ្វើប្រជាចលនារត់ទៅថៃ ។ នៅឆ្នាំ១៩៥៧ ខ្ញុំបានចូលរៀននៅថ្នាក់ទី៦ នៅសាលាឧប្បសម្ព័ន្ធវិទ្យាល័យព្រះស៊ីសុវត្ថិ ហើយខ្ញុំបានចូលក្រុមកីឡាបាល់ទះ ដែលមាន គង់ សុផល ហៅ គី (អនុលេខាភូមិភាគពាយ័ព្យ) ជាអ្នកបង្ហាត់ ។

ដើមឆ្នាំ១៩៦៤ ដាំ ដេង បានណែនាំខ្ញុំ, ពុត ជា និង ថាច់ ញឹង ឲ្យធ្វើបាតុកម្ម ។ ក្រោយធ្វើបាតុកម្មចប់ លន់ នល់, គូ រុន និង កុយ ស៊ីអ៊ី បានហៅយើងទាំងបីនាក់ រួមទាំង ថាច់ គឹមសឹង (នៅសាលាគរុកោសល្យ) យកទៅសម្ភុតនៅសេនាធិការ និងបានឲ្យគិញតាមដានខ្ញុំជាប់ ។ ដោយសារមូលហេតុនេះ បក្សបានសម្រេចឲ្យខ្ញុំឈប់រៀន ហើយឲ្យចូលធ្វើការសម្ងាត់តាមរយៈឈ្មោះ គៀត ។

នៅខែកក្កដា ឆ្នាំ១៩៦៥ ខ្ញុំបានចូលធ្វើការនៅគណទានជាតិ ។ ក្រោយមក វ៉ាន់ ពីនី ជាមន្ត្រីទូត បានអូសទាញខ្ញុំឲ្យស្រឡាញ់របបមូលធន ។ មកដល់ខែសីហា ឆ្នាំ១៩៦៥ វ៉ាន់ ពីនី និង កន (គិញពិសេសនៅភ្នំពេញ) បានរៀបចំ ខទ្ទេសនាមខ្ញុំឲ្យចូលសេអ៊ីអា ដែលមាន វ៉ាន់ សរ (មេក្រសួងគិញពិសេស) ជាគណអធិបតី ។

បន្ទាប់មក វ៉ាន់ ពីនី បានណែនាំខ្ញុំឲ្យទាក់ទង ម៉ៃ សាខន, ឈុន សុខឆ្លួន, ទួន សុខផល្លា, ឆ្លួន ឃៀង និង ម៉ែន សិទ្ធី ។ ចំណែកនៅគណទានជាតិ ខ្ញុំបានទាក់ទងជាមួយ យ៉ង់ ហ៊ិន សិស្សថ្នាក់ទី១ វិទ្យាល័យព្រះស៊ីសុវត្ថិ ។

នៅខែកញ្ញា ដល់ខែវិច្ឆិកា ឆ្នាំ១៩៦៥ ប្រធានធនាគារបានផ្លាស់ខ្ញុំឲ្យទៅសាខាខេត្តកំពង់ធំ ដែលនៅទីនោះ ខ្ញុំបានទាក់ទង ព្រំ ពុយ ម្ចាស់ហាងឱសថនៅផ្សារកំពង់ធំ, អេង និង ព្រំ ធន ជាគ្រូបង្រៀន ដើម្បីបំផុសវប្បធម៌អាមេរិក និងវប្បធម៌ពុករលួយ ។ បន្ទាប់មក នៅចុងឆ្នាំ១៩៦៥ ខ្ញុំបាននាំមនុស្សទាំងបីនាក់នេះ ទៅភ្នំពេញដើម្បីខទ្ទេសនាមឲ្យ វ៉ាន់ ពីនី ហើយ វ៉ាន់ ពីនី បានដាក់ផែនការឲ្យខ្ញុំកសាងកម្លាំង សេអ៊ីអា ក្នុងចំណោមអ្នកធ្វើការជាមួយគ្នា និងសិស្សទៀត ។

នៅខែធ្នូ ឆ្នាំ១៩៦៥ បក្សបានសម្រេចឲ្យខ្ញុំចេញទៅជនបទតាមរយៈ កន ដោយពេលនោះខ្ញុំបានរាយការណ៍ប្រាប់ វ៉ាន់ ពីនី ហើយ វ៉ាន់ ពីនី បានខទ្ទេសនាមខ្ញុំឲ្យស្គាល់ សៀន លេខាផ្ទាល់

របស់ ញ៉ឹម ។

នៅខែមករា ឆ្នាំ១៩៦៦ ខ្ញុំបានចេញពីភ្នំពេញទៅបាត់ដំបង ដោយនៅទីនោះបានជួប ទាត់ លេខាតំបន់១ (ស្លាប់) ។ ទាត់ បានខ្ទេសនាមខ្ញុំឲ្យស្គាល់ ញ៉ឹម នៅជិតភូមិកង្កែត ស្រុកសង្កែ ។ បន្ទាប់មក ខ្ញុំបានជួប សៀន ហើយ សៀន បានខ្ទេសនាមខ្ញុំបន្តឲ្យស្គាល់ សាយ សមាជិកភូមិភាគពាយ័ព្យ និង ស៊ុយ ជំនួយការភូមិភាគពាយ័ព្យ ទទួលអនុលេខាតំប់៤ ។

នៅទីនោះ ញ៉ឹម និង កន បានឲ្យខ្ញុំទៅធ្វើជាកូនចិញ្ចឹមរបស់ តាក្តុល ជាគណៈអចិន្ត្រៃយ៍របស់ភាគ ។ តាក្តុល បានចាត់តាំងខ្ញុំឲ្យទៅនៅសាខាមួយមាន គឹម ជាលេខា ដោយពេលនោះ ខ្ញុំមាននាទីខ្ទេសនាមឯកសារដើម្បីអប់រំសមាជិកក្នុងសាខា ។ លើសពីនេះ ខ្ញុំបានអប់រំ គឹម ឲ្យឃោសនាប្រជាជនកុំឲ្យចូលរួមជាមួយបដិវត្តន៍ដែលរៃអង្គាសប្រាក់ គេណ្ឌប្រជាជន និងដោះដូរកសិផលជាមួយប្រជាជនគិតជារបស់របរ រហូតធ្វើឲ្យប្រជាជនមានទំនាស់ជាមួយបដិវត្តន៍ ។ ក្រោយមក តាក្តុល បានចាត់តាំងខ្ញុំឲ្យទៅនៅក្នុងក្រុមសម្ព័ន្ធយុវកបភូមិចារ ដែលមាន សួម ជាប្រធាន ហើយខ្ញុំក៏បានអប់រំ សួម ឲ្យទប់ស្កាត់ចលនាតស៊ូរបស់បដិវត្តន៍នេះទៀត ។


ទួន សុខផល្លា (រូបខាងស្តាំ) មុនពេលចាប់ខ្លួនបញ្ជូនទៅមន្ទីរស-២១ ។

ពាក់កណ្តាលឆ្នាំ១៩៦៦ ខ្ញុំបានឡើងទៅធ្វើការនៅសំឡូត បានរយៈពេលកន្លះខែក៏ឈឺគ្រុនចាញ់ ទើបខ្ញុំត្រឡប់មកព្យាបាលនៅភូមិស្រែខ្មែរវិញ ដោយមាន សាយ និង ស៊ុយ ជាអ្នកថែទាំ ។ ក្រោយមក សាយ បានហៅខ្ញុំ និង ស៊ុយ ទៅប្រជុំនៅផ្ទះគាត់ស្ថិតនៅភូមិកណ្តាល សង្កាត់កំពង់គុល ដោយគាត់បានណែនាំពីការកសាងកម្លាំងនៅក្នុងភូមិ ។ ឆ្លៀតឱកាសនោះ ខ្ញុំបានរាយការណ៍ឲ្យ សាយ ទទួលស្គាល់ឈ្មោះ គឹម និង សួម ដែលទើបអប់រំបាន ។

ក្រោយពីជាសះស្បើយពីជំងឺ ខ្ញុំបានទៅធ្វើការនៅសំឡូតទៀត ដោយពេលនោះ ខ្ញុំបានទាក់ទងជាមួយ លឿម ជំនួយការផ្ទាល់របស់ តាក្តុល និងជាអតីតអ្នករកស៊ីត្បូង ។ ខ្ញុំបានឲ្យ លឿម បំផុសយុវជនក្នុងភូមិទៅរកស៊ីជីកត្បូងនៅប៉ៃលិន ដើម្បីទទួលយកឥទ្ធិពលពុករលួយ អាវ៉ាសែ ។

នៅខែកុម្ភៈ ឆ្នាំ១៩៦៧ កន បានបើកវគ្គអប់រំនៅជិតភូមិសំរាំង ដោយមាន សាយ, ស៊ុយ, វ៉ាញ, កំបារ និងខ្ញុំមករៀន ។ លុះពេលរៀនចប់ សាយ ឆ្លៀតឱកាសប្រជុំ ដែលមាន ស៊ុយ, វ៉ាញ និងខ្ញុំដើម្បីជំរុញនិងកសាងកម្លាំងថែមទៀត ។ ប៉ុន្តែ ចាប់ពីខែឧសភាដល់ខែធ្នូ ឆ្នាំ១៩៦៧ ខ្ញុំមិនបានធ្វើសកម្មភាពទេ ដោយសារខ្ញុំមានជំងឺគ្រុនចាញ់ជាទម្ងន់ ។

បន្ទាប់ពីផ្ទុះអាវុធ នៅបាត់ដំបងបានរយៈពេលបីខែ គឺនៅខែកុម្ភៈ ឆ្នាំ១៩៦៨ ខ្ញុំទទួលការណែនាំពី សាយ និង ស៊ុយ ឲ្យចាំទាក់ទងឈ្មោះ សាន អតីតសាស្ត្រាចារ្យ និង ស៊ូ នៅក្រសួងការបរទេស ហើយបានណែនាំឲ្យធ្វើសកម្មភាពតាមភារកិច្ចចំហរដែលអង្គការ

បក្សប្រគល់ឲ្យ ។

នៅឆ្នាំ១៩៦៨ ទាំងកងឈ្លប និងប្រជាជនរាប់ពាន់គ្រួសាររត់ចូលព្រៃ និងរងការអត់ឃ្លានយ៉ាងខ្លាំង ។ ប៉ុន្តែ ខ្ញុំ និង សាន មិនបានដោះស្រាយទេ បែរជាចលនាប្រជាជនឲ្យរត់ចូលតំបន់ខ្លាំងវិញ ។ ខ្ញុំទុកឲ្យខ្មាំងបាញ់សម្លាប់ប្រជាជនជាបន្តបន្ទាប់ ហើយមួយចំនួនទៀតបានស្លាប់ដោយជំងឺ ។

ខណៈនោះ ខ្ញុំកសាងបានកម្លាំងស្នូលបន្ថែមទៀតគឺ ១) ចៅ ប្រធានមន្ទីរតំបន់ ២) វង់ រកស៊ីត្បូងនៅប៉ៃលិន ៣) ឡៃ រកស៊ីត្បូង ៤) វ៉ាន់ នៅភូមិអំពុង ៥) សា មេជីវពល ៦) សារ៉ូ ប្រជាជននៅសហករណ៍ ៧) ដូ លេខាស្រុកសំឡូត និង ៨) លុយ រកស៊ីចងការប្រាក់ ។ ក្រៅពីនោះ ខ្ញុំបានទាក់ទង ខូយ សព្វថ្ងៃសមាជិកមន្ទីរសេនាធិការយោធាភូមិភាគពាយ័ព្យ ។

នៅឆ្នាំ១៩៦៨ ខ្ញុំបានរាយការណ៍ទៅស័ក្តិ៤ អ៊ូច នៅបន្ទាយត្រែងអំពីមូលដ្ឋានរបស់បដិវត្តន៍នៅព្រៃឡាមួន, ព្រៃស្វេរ, អូបេង ដើម្បីឲ្យខ្មាំងទៅវាយកម្ទេច ។

នៅឆ្នាំ១៩៦៩ ស៊ុយ ទទួលការណែនាំពី សាយ ឲ្យទៅចាត់តាំងគណៈកម្មាធិការក្បត់មួយនៅមូលដ្ឋានក្រញូង ដើម្បីរឹបយកអំណាចពីបក្សពេលដែល ញឹម និង តាក្តុល មិននៅ ។ ក្នុងការចាត់តាំងគណៈកម្មាធិការថ្មីនេះមានសមាសភាព ៖

១) ស៊ុយ ជាប្រធានទទួកបន្ទុកដឹកនាំរួម

២) ខ្ញុំមានភារកិច្ចនៅអែប តាតុំ ទទួលភារកិច្ចជំនួស ញឹម និងក្តាប់យោធាពីរក្រុម

៣) ហៀង បច្ចុប្បន្នជាលេខាតំបន់៤ ទទួលភារកិច្ចក្តាប់ប្រជាជន

៤) ជេត បច្ចុប្បន្នជាលេខាតំបន់៣ ទទួលភារកិច្ចក្តាប់ជនជាតិព័រ

ក្រៅពីគណៈកម្មាធិការ គឺមាន ស៊ូ, រិទ្ធិ ប្រធានកសិដ្ឋានកប្បាសរបស់ភូមិភាគ នៅស្តៅ និង សាន ។

នៅខែមករា ឆ្នាំ១៩៧១ ញឹម បានចាត់តាំងខ្ញុំឲ្យទទួលភារកិច្ចជាអនុប្រធានបណ្តុះបណ្តាលយុវជនភូមិភាគពាយ័ព្យ ។ ស្របពេលនោះ ខ្ញុំបានអប់រំយុវជន និងយុវនារីជាច្រើនមានដូចជា ១) ឈឿត ជំនួយការស្រុកគាស់ក្រឡ ២) រូ ជំនួយការសង្កាត់ស្រែអណ្តូង ៣) ព្រាំ ជំនួយការតំបន់១ ៤) ថុល ជំនួយការតំបន់២ ៥) ឡេង សមាជិកស្រុកគាស់ក្រឡ ៦) សុង ទទួលសន្តិសុខភូមិភាគពាយ័ព្យ ៧) ប៉ូច ប្រធានរោងម៉ាស៊ីនកិនស្រូវនៅមង្គលបូរី តំបន់៣ ៨) ហុង ប្រធានក្រុមសិល្បៈ ភូមិភាគពាយ័ព្យ និងជាជំនួយការតំបន់៥ ។

ខែកក្កដា ឆ្នាំ១៩៧១ អង្គការភាគបានសម្រេចធ្វើសន្និបាតយុវជននៅភូមិចំឡងរមាំង សង្កាត់ក្រញូង ស្រុកសំឡូត តំបន់១ ដោយចាត់តាំង សាយ ធ្វើជាតំណាងរបស់ភាគ ។ តែមុននឹងធ្វើសន្និបាត សាយ ណែនាំខ្ញុំអំពីផែនការសន្និបាតដែលដឹកនាំឲ្យខុសពីទិសដៅរបស់អង្គការ ដូចជា អប់រំ និងចាត់តាំងយុវជននារីអំពីរឿងសប្បាយ ស៊ីចុក ធ្វើការងារតាមរបបមូលធន បើកសិទ្ធិឲ្យស្រឡាញ់គ្នាតាមចិត្ត ។ សន្និបាតនេះបានប្រព្រឹត្តទៅរយៈពេលមួយអាទិត្យ ដោយពេលព្រឹករៀន ល្ងាចកម្សាន្ត និងពេលយប់មានសម្តែងសិល្បៈ ។

លុះដល់ខែតុលា ឆ្នាំ១៩៧០ អង្គការភូមិភាគបានសម្រេចដកខ្ញុំទៅតំបន់៥ តែមុននឹងទៅ ខ្ញុំបានទៅជួប សាយ ។ សាយ បានប្រាប់ខ្ញុំឲ្យទាក់ទង គ្រូសារ៉ង ចៅអធិការវត្តភ្នំស្រុក, ម៉ៃ ស័ក្តិ៥ខាង លន់ នល់, ណៃ លេខាតំបន់៥, រ៉េន អនុលេខាស្រុកមង្គលបូរី តំបន់៣ ។ ឆ្លៀតឱកាសនោះ ខ្ញុំក៏បានរាយការណ៍ពីឈ្មោះ ម៉ោង ពីមុននៅក្នុងកងទ័ពតំបន់១ និងបច្ចុប្បន្ន ជាលេខាស្រុកព្រះនេត្រព្រះ តំបន់៥ ។

ក្រោយពីជួប សាយ ហើយ ខ្ញុំបានឆ្លងទៅតំបន់៤ ទៅជួប ស៊ុយ ទៀត ហើយ ស៊ុយ ក៏បានខទ្មេសនាមខ្ញុំឲ្យស្គាល់ខ្សែរបស់គាត់ដែលបានបញ្ជូនទៅតាមតំបន់រួចហើយ មានឈ្មោះដូចជា ១) ហាត់ លេខាស្រុកភ្នំស្រុក ២) ដេង អនុលេខាស្រុកភ្នំស្រុក ៣) សុត អនុលេខាស្រុកសិរីសោភ័ណ្ឌ ៤) ទុយ លេខាវរសេនាតូច៤២៥ ប្រចាំនៅស្រុកថ្មពួក ៥) រស់ ប្រធានត្រាក់ទ័រ នៅមង្គលបូរី ៦) សំអាត ជាអនុលេខាស្រុកព្រះនេត្រព្រះ ៧) ខូ សមាជិកស្រុកព្រះនេត្រព្រះ ៨) រិម ប្រធានរោងម៉ាស៊ីនកិនស្រូវតំបន់៥ ៩) ចយ ប្រធានរោងជាងជួលជុលត្រាក់ទ័រតំបន់៥ និង ១០) នារិន ប្រធានមន្ទីរពេទ្យស្រុកព្រះនេត្រព្រះ ។

នៅខែកុម្ភៈ ឆ្នាំ១៩៧២ ខ្ញុំទៅដល់ស្រុកស្រីស្នំ តំបន់៤៤

ជួបនឹងឈ្មោះ ណៃ, ម៉ៃ និង គ្រូសារ៉េង រៀបចំផែនការក្បត់នៅតំបន់៥ ដោយរៀបចំព្រំប្រទល់ស្រុកក្រឡាញ់ ស្រុកព្រះនេត្រព្រះ និងព្រំប្រទល់ស្រុកភ្នំស្រុក និងស្រុកស្រីស្នំ ឲ្យទៅជាមណ្ឌលសន្តិសម្ព័ន្ធ និងទុកឲ្យខាង លន់ នល់ ប្រមូលកម្លាំងទ័ព និងចាប់ប្រជាជនយកមកធ្វើទាហាន ។

នៅខែមេសា ឆ្នាំ១៩៧២ អាចារ្យ ម៉ៃ បានបើកការប្រជុំរួមមាន គ្រូសារ៉េង, ណៃ, រ៉េន, យឺន និង ព្រំ មកពីវៀតណាមខាងជើង ដើម្បីពិនិត្យផែនការដែលអនុវត្ត និងកសាងកម្លាំងនៅក្នុងតំបន់៥ ដើម្បីភ្ជាប់ទៅតំបន់៤ និងតំបន់៣ ។ បន្ទាប់មក ម៉ៃ បានខទ្ទេសនាមខ្ញុំឲ្យទៅជួប សុត លេខាតំបន់ ១០៦ (សព្វថ្ងៃតំបន់៤៤) ដើម្បីទាក់ទងធ្វើសកម្មភាពនៅតាមព្រំប្រទល់តំបន់៥ និងតំបន់១០៦ ។

ខែឧសភា ១៩៧៤ ខ្ញុំមានជំងឺជាទម្ងន់ ហើយលើកទី១ ញឹម បានឲ្យខ្ញុំទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យបូព៌ា ។ នៅទីនោះខ្ញុំបានទាក់ទងជាមួយ ហាក់ សែ ពេទ្យមកពីវៀតណាម ហើយ សែ បានខទ្ទេសនាមខ្ញុំឲ្យ ដា លេខាស្រុកក្រូចឆ្មារ, រឹក លេខាតំបន់២២ និង សំណាង សមាជិកសេដ្ឋកិច្ច ភូមិភាគបូព៌ា ។ លើកទីពីរ នៅខែកក្កដា ខ្ញុំបានទៅសម្រាកព្យាបាលនៅទីនោះម្តងទៀត ហើយបានខុសសីលធម៌ជាមួយនារីពេទ្យឈ្មោះ គី សព្វថ្ងៃពេទ្យឆ្មបតំបន់៥ ។ ក្រៅពីនោះ ខ្ញុំបានទាក់ទងជាមួយ លី ផែន អតីតសាស្ត្រាចារ្យ, ឈូក សមាជិកភាគ, កាវ អនុលេខាស្រុកឆ្លូង និង ឆោម សាវ៉ាត លេខាស្រុកឆ្លូង ដើម្បីលើកឡើងពីសភាពការណ៍នៅតំបន់៥ តំបន់៤ តំបន់៣ និងផែនការធ្វើរដ្ឋប្រហាររបស់ភូមិភាគបូព៌ាកាលពីឆ្នាំ១៩៧៣ ។

នៅខែធ្នូ ឆ្នាំ១៩៧៤ ឈ្មោះ ណៃ បានធ្វើឲ្យបែកការណ៍រឿងសីលធម៌នារី ដឹងដូច្នេះ ខ្ញុំក៏រាយការណ៍ទៅ ញឹម ហើយ ញឹម បានឲ្យខ្ញុំចេញពីមន្ទីរពេទ្យត្រឡប់មករៀបចំតំបន់៥វិញ ។ ដោយខ្លាចបែកការណ៍ ខ្ញុំបានបញ្ជាឲ្យយោធាចាប់ ម៉ៃ មុនគេ បន្ទាប់មកចាប់ឈ្មោះ ណៃ និង គុង យឺន យកទៅកម្ទេចចោល ។

បន្ទាប់ពីរៀបចំកិច្ចការនេះចប់ នៅខែកុម្ភៈ ឆ្នាំ១៩៧៥ ខ្ញុំបានឡើងទៅរាយការណ៍ជូន ញឹម រួចបង្ហួសទៅជួប សាយ នៅភូមិតាសាញ់ ស្រុកសំឡូត ។ សាយ បានណែនាំឲ្យខ្ញុំឲ្យពង្រាយទ័ពជាកងតូចៗ ប៉ុន្តែមិនឲ្យវាយជាមួយខ្មាំងទេ ។

នៅខែមេសា ឆ្នាំ១៩៧៥ ភូមិភាគបានហៅខ្ញុំឡើងទៅប្រជុំនៅភាគ ប៉ុន្តែមិនបានប្រជុំទេ ព្រោះត្រូវវាយសម្រុកនៅភ្នំពេញ ។ ខ្ញុំបានធ្វើដំណើរត្រឡប់មកវិញតាមផ្លូវជាតិលេខ៦ ហើយបានចូលសាលាខេត្តកំពង់ធំ ដើម្បីសួររកផ្លូវធ្វើដំណើរបន្តទៅទៀត ។ ពេលនោះខ្ញុំបានជួប ខឿន សមាជិកមជ្ឈិម និង សុត ។ ខឿន បានណែនាំខ្ញុំពីការរៀបចំផែនការក្បត់នៅពាយ័ព្យ និងស្រាវជ្រាវរកកម្លាំងចាស់ឡើងវិញ ។ បន្ទាប់មកខ្ញុំក៏បានទៅជួប សាយ និងរាយការណ៍ពីផែនការរបស់ ខឿន ។

នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៥ សាយ បានបើកអង្គប្រជុំនៅសាកលវិទ្យាល័យបាត់ដំបង ដោយគាត់ជាប្រធាន ខ្ញុំជាអ្នកខទ្ទេសនាម ហើយ ស៊ុយ, សាន, វ៉ាញ, ស៊ូ និង ម៉ៃ (សព្វថ្ងៃនៅក្រសួងការបរទេស) ជាសមាជិក ។ នៅពេលនោះ ខ្ញុំបានខទ្ទេសពីខ្លឹមសារទាំងអស់ដែល ខឿន បានលើកឡើង ។ ក្រោយពីប្រជុំចប់ សាយ បានបែងចែកផែនការឲ្យខ្ញុំឲ្យធ្វើសកម្មភាពនៅតំបន់ និងទទួលទាក់ទងទៅខាងថៃ ។ ចំណែកអ្នកដឹកនាំរួម មាន ខឿន និងគាត់ ។ បន្ទាប់មក ខ្ញុំបានយកកម្លាំងក្បត់១៦នាក់ ដែល ហឿន (ប្រធានមន្ទីរពេទ្យភូមិភាគបូព៌ា) យកមកប្រគល់ឲ្យខ្ញុំនៅសាលាស្រុកស្វាយស៊ីសុផុន មកដាក់ផែនការឲ្យបំផ្លាញបដិវត្តន៍ និងបានបញ្ជូនទៅបង្កប់នៅតាមមូលដ្ឋានមន្ទីរ និងកសិដ្ឋាននានា ។

ក្រោយមក ខ្ញុំបានយកខ្លឹមសារប្រជុំខាងលើទៅអនុវត្ត និងបែងចែកដូចតទៅ ៖

◆ ខាងមូលដ្ឋាន ៖ មានស្រុកសេរីសោភ័ណ្ឌ មានឈ្មោះ វុធ ទទួលខុសត្រូវរួមស្រុកទាំងមូល និងទាក់ទងមកខ្ញុំ ។ ចំណែកសកម្មភាពគឺបំផុសពីបញ្ហាជីវភាព គ្មានផ្សារ គ្មានលុយចាយ និងត្រូវដកយកសម្ភារខ្វះដែលអង្គការចែកទៅឲ្យប្រជាជន ។

◆ ស្រុកថ្មពួក ៖ មានឈ្មោះ ធន ទទួលខុសត្រូវរួម ចំណែកសកម្មភាពដូចសេរីសោភ័ណ្ឌដែរ ។

◆ ស្រុកភ្នំស្រុក ៖ មានឈ្មោះ មាន ទទួលខុសត្រូវរួម ។ ចំណែកសកម្មភាពគឺបំផ្លាញគោ ដោយធ្វើឲ្យប៉ះពាល់ដល់ការងារភ្ជួរស្រែ និងដកកម្លាំងយុវជន យុវនារី ពីសហករណ៍ដែលនាំឲ្យខ្វះកម្លាំងធ្វើស្រែ ។

◆ ស្រុកព្រះនេត្រព្រះ ៈ មាន លឿម ទទួលខុសត្រូវរួម ។ រីឯសកម្មភាពគឺជម្លៀសប្រជាជនពីភូមិមួយ ទៅភូមិមួយទៀត ធ្វើឲ្យយឺតយ៉ាវក្នុងការបង្កបង្កើនផល និងធ្វើឲ្យប្រជាជនរឹតតែទំនាស់ជាមួយបដិវត្តន៍ ។

◆ ចំណែកខាងផ្នែកយោធា ៈ ខ្ញុំបានរៀបឈ្មោះ ដូចជា គី, សារឿន, វ៉ាល់, ម៉ោង, ទុយ, លឿ, វន, នារីអេត, នារីភ្លឿន, ធួក និង ឆោម ដើម្បីដឹកនាំ ។ ចំណែកសកម្មភាព ខ្ញុំបានណែនាំឲ្យបោសសម្អាតខ្មាំងនៅស្រុកព្រះនេត្រព្រះ ដើម្បីបង្ហាញប្រជាជនឲ្យឃើញថា ខ្មែរក្រហមឃោរឃៅ ។ ក្រោយមក ខ្ញុំបានឲ្យផ្អាកវិញ ដោយសារដំណឹងនេះបានលេចឮទៅដល់អង្គការភូមិភាគ ។

នៅខែកក្កដា ឆ្នាំ១៩៧៥ សុត បានទៅជួបខ្ញុំនៅស៊ីសុផុន ដើម្បីទាក់ទងអំពីស្រូវពូជដែលអង្គការភូមិភាគពាយ័ព្យសម្រេចឲ្យតំបន់៥ ផ្តល់ទៅតំបន់១០៦របស់គាត់ ។ ឆ្លៀតឱកាសនោះ សុត បាននាំឈ្មោះ សៀន សមាជិកតំបន់១០៦ និង ពៅ សមាជិកសេដ្ឋកិច្ច មកខ្ទេសនាមឲ្យខ្ញុំស្គាល់ដើម្បីទាក់ទងការងារក្បត់ ។

លុះដល់ខែសីហា ឆ្នាំ១៩៧៥ សាយ បានហៅខ្ញុំ, វ៉ាញ, សាន, ស៊ុយ, ស៊ូ និង ម៉ៃ ទៅប្រជុំនៅសាកលវិទ្យាល័យបាត់ដំបងម្តងទៀត ដោយខ្លឹមសារប្រជុំមានដូចជា ៖

១) រាយការណ៍អំពីលទ្ធផលនៃការអនុវត្តផែនការណ៍ក្បត់កន្លងមក

២) រៀបចំផែនការថ្មីបន្តទៀត

នៅខែកញ្ញា ឆ្នាំ១៩៧៥ អង្គការជម្លៀសប្រជាជនចំនួនមួយសែនប្រាំម៉ឺននាក់មកតំបន់៥ ។ ខ្ញុំបានចាត់តាំងគណៈកម្មាធិការសេអ៊ីអា មួយចាំទទួលប្រជាជនជម្លៀសដែលមានឈ្មោះ សរ ធ្វើជាប្រធាន ក្នុងគោលបំណង ទី១) ស្រាវជ្រាវរកកម្លាំងចាស់នៅភ្នំពេញ និងទី២) ប្រមូលមេទាហាន, វេជ្ជបណ្ឌិត, សាស្ត្រាចារ្យ, វិស្វករ, និស្សិត, អ្នករដ្ឋការចាស់ ដើម្បីប្រឆាំងនឹងបដិវត្តន៍ ។

ក្នុងកិច្ចការនេះយើងប្រមូលកម្លាំងបាន ៈ

◆ វិស្វករ៣០នាក់

◆ វេជ្ជបណ្ឌិត៤០នាក់

◆ មេទាហាន៤០

◆ សាស្ត្រាចារ្យ និងគ្រូបង្រៀន១១០នាក់

◆ និស្សិតមហាវិទ្យាល័យច្បាប់៣២នាក់

◆ រដ្ឋការចាស់៧៥នាក់

អ្នកទាំងនេះ សរ និង ម៉ោង បានរៀបចំឲ្យស្នាក់នៅផ្សារព្រះនេត្រព្រះ ។

ខែតុលា ឆ្នាំ១៩៧៥ ខ្ញុំបានទៅរៀននៅសាលាបក្សដែលអង្គការបើកនៅស្ពានអូរឡាំពិក ភ្នំពេញ ។ ឆ្លៀតឱកាសនោះខ្ញុំបានសុំច្បាប់គណៈសាលា ទៅមន្ទីរពេទ្យ១៧ មេសា ដើម្បីឲ្យពេទ្យថតក្រពះ ។ ពេលទៅដល់បន្ទប់ថត ខ្ញុំបានជួប សុត និង ហង្ស លេខាតំបន់១០៣ ចាំចូលទៅថតដែរ ។ សុត បានហៅយើងទៅបន្ទប់ស្ងាត់ រួចខ្ទេសនាមខ្ញុំឲ្យស្គាល់ ហង្ស ដែលជាខ្សែរបស់ ឡឿន ។ នៅខែធ្នូឆ្នាំដដែល ហង្ស បានទៅជួបខ្ញុំនៅស្វាយស៊ីសុផុន ហើយខ្ញុំក៏នាំគាត់ទៅជួប សាយ នៅផ្សារស្ទោ ។ ហង្ស បានលើកឡើងពីការទាក់ទងគ្នារវាងតំបន់នៅជាប់ព្រំដែនថៃ ដើម្បីធ្វើជាមូលដ្ឋានបង្អែក ។

ក្រោយមក សាន បានមកប្រាប់ខ្ញុំអំពីការធ្លាយរឿងរ៉ាវប្រមូលអ្នកមានសញ្ញាបត្រធំៗឲ្យធ្វើការតាមចំណេះវិជ្ជា នៅតំបន់៥ ។ ក្រោយទទួលដំណឹងនេះ ខ្ញុំបានទៅជួប សាយ ដើម្បីឲ្យជួយមតិ ។ យើងបានរកវិធី ដោយហៅអ្នកទាំងនោះមកចូលរួមវគ្គរៀនសូត្រ និងអប់រំ និងធ្វើការបែងចែកថាតើអ្នកណាត្រូវទុក និងត្រូវបោសសម្អាត ។ ស្របពេលនោះ មានកម្មាភិបាលតំណាងក្រសួងសន្តិសុខរបស់អង្គការ៨៧០ម្នាក់ បានមករកខ្ញុំនៅស្វាយស៊ីសុផុន ដើម្បីឲ្យខ្ញុំរកសេអ៊ីអា ។ ខ្ញុំបានរាយការណ៍ពីសភាពការណ៍នៅដុប និងឲ្យគាត់ពិនិត្យមើលប្រវត្តិរូបអ្នកដែលមានសញ្ញាបត្រ ហើយខ្ញុំក៏បានបញ្ជូនមេទាហាន វិស្វករ វេជ្ជបណ្ឌិត និស្សិតមហាវិទ្យាល័យច្បាប់មួយចំនួនតាមរយៈសន្តិសុខរបស់ភាគឲ្យគាត់ ។ ដើម្បីលាក់បាំងរឿងនេះ ខ្ញុំឲ្យ សាន នាំយកមេទាហានមួយចំនួនទៅបំពាក់អាវុធ និងឲ្យបង្កប់នៅតាមសហករណ៍ ។ ចំណែកកម្លាំង៣០នាក់ ខ្ញុំឲ្យ ព្រំ នាំរត់ទៅថៃតាមច្រកយាង ហើយនៅសេសសល់ខ្ញុំឲ្យ វន បោសសម្អាត ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៦ សាយ បានហៅខ្ញុំមកប្រជុំផ្សាយពីផែនការវាយបក្សក្នុងឱកាសបុណ្យខួបថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៦ តាមការណែនាំពី ឡឿន ។ ក្នុងនោះ ពីរកងពលដែល



សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ក្នុងទសវត្សរ៍៨០

ដឹកនាំដោយ សាន និង ខ្វៃន ត្រូវវាយយកភូមិភាគពាយ័ព្យទាំងមូល ដើម្បីភ្ជាប់ទៅតំបន់១០៦ គ្រប់គ្រងដោយ សុត, តំបន់១០៣ គ្រប់គ្រងដោយ ហង្ស, ភូមិភាគឧត្តរគ្រប់គ្រងដោយ ស្រេង និង ឡូសាន គ្រប់គ្រងដោយ យ៉ា ដែលមានថៃជាខ្នងបង្អែក ។

នៅពាក់កណ្តាលខែមិថុនា ឆ្នាំ១៩៧៦ សាយ, ខ្ញុំ, សាន, វ៉ាញ, ស៊ូ, ម៉ៃ និង នៅ បានទៅជួប វិលីយ៉ាំ ហ្វុសស៊័រ ទូតអាមេរិកប្រចាំនៅថៃ, វិច័យ ប្រសឹត ចៅហ្វាយខេត្តអារញ្ញ, អ៊ិន តាំ, សេក សំអៀត រួមនឹងអ្នកបកប្រែភាសាថៃម្នាក់នៅផ្ទះមួយដែលមានចម្ងាយជាង៥គីឡូម៉ែត្រ តាមផ្លូវទៅខេត្តអារញ្ញ ។ ក្នុងកិច្ចប្រជុំនោះ សាយ លើកឡើងពីផែនការវាយបក្សដែលត្រូវបែកការណ៍ និងសុំកម្លាំងកងទ័ពថៃ និងសុំជំនួយកម្លាំងជើងអាកាសអាមេរិក ដើម្បីអន្តរាគមន៍ ។

នៅខែតុលាឆ្នាំ១៩៧៦ ខ្ញុំបានជួប ឡឿន នៅពេលមកចូលរួមប្រជុំគណកម្មាធិការមជ្ឈិម ។ ពេលនោះ ឡឿន បានប្រាប់ខ្ញុំថា អង្គការបានចាប់ ឈូក និងចាប់ យ៉ា ហើយ ប៉ុន្តែគាត់បានណែនាំខ្ញុំឲ្យខិតខំអប់រំដល់កម្លាំង សេរីអា បន្ថែមទៀត ។

រហូតដល់ខែធ្នូ ឆ្នាំ១៩៧៦ សាយ បានហៅខ្ញុំមកប្រជុំផ្សព្វផ្សាយពីផែនការវាយបក្សលើកទីពីក្នុងឱកាសបុណ្យខួបកំណើតកងទ័ពថ្ងៃទី២០ ខែមករា ឆ្នាំ១៩៧៧ ហើយក្រោយមកបានរៀបចំផែនការលើកទីបីទៀត ។ ប៉ុន្តែផែនការទាំងនេះត្រូវបែកការណ៍ នៅពេលអង្គការចាប់ ឡឿន នៅខែកុម្ភៈ ឆ្នាំ១៩៧៧ ។

ដល់ដើមខែមីនា ឆ្នាំ១៩៧៧ សាយ បានហៅខ្ញុំ និងកម្លាំងទាំងអស់មកចូលរួម ដោយលើកពីផែនការវាយបក្សដែលត្រូវបែកការណ៍ ដែលធ្វើឲ្យអ្នកចូលរួមមានការព្រួយបារម្ភយ៉ាងខ្លាំង ។

ប៉ុន្តែ ទោះយ៉ាងណា សាយ ឲ្យខិតខំផ្សព្វផ្សាយផែនការតទៅទៀតដើម្បីកុំឲ្យខាងក្រោមអស់សង្ឃឹម និងបានដាក់ផែនការឲ្យអនុវត្តតទៅទៀត ដោយក្នុងនោះ ខ្ញុំមានភារកិច្ចទៅទាក់ទងជាមួយ លីន នៅភូមិភាគបូព៌ាដោយសម្ងាត់ ។ ដំបូង ខ្ញុំបានទៅជួប រឹក និង សំណាង ដើម្បីប្រាប់ពីគោលបំណងក្បត់ និងបានស្នើជួប លីន ទៀតដើម្បីរៀបចំផែនការ ។

ក្រោយពីជួបជាមួយ លីន ហើយ លីនក៏ណែនាំខ្ញុំឲ្យស្គាល់ឈ្មោះ ចាន់, យី លេខាតំបន់១០៥, ឌឹម លេខាតំបន់២០ ។ នៅពេលត្រឡប់ដល់មកកន្លែងវិញ ខ្ញុំបានរាយការណ៍ពីលទ្ធផលការជួបប្រជុំទៅឲ្យ សាយ ។

នៅខែមេសា ឆ្នាំ១៩៧៧ អង្គការបានណែនាំខ្ញុំឲ្យប្រមូលសាស្ត្រាចារ្យ និងគ្រូបង្រៀនដាក់មួយកន្លែង ។ ស្របពេលនោះ សាយ ក៏បានណែនាំខ្ញុំឲ្យប្រុងប្រយ័ត្ន ព្រោះខ្សែខាងតំបន់៤ត្រូវបែកការណ៍ហើយ ។

នៅខែឧសភា ឆ្នាំ១៩៧៧ អង្គការបានដកខ្ញុំមកធ្វើការនៅក្រសួងការបរទេសរយៈពេលកន្លះខែ បន្ទាប់មកនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំដែលអង្គការចាប់ខ្លួនខ្ញុំតែម្តង ។

**សោម ប៊ុនថន**

# បញ្ជីឈ្មោះនិងរូបថតអ្នកទោសមន្ទីរស-២១ដែល ទទួលបាននៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១២

**អ្នកកត់ត្រា ៖ ឆាំង យុ, ញាណ សុជាតិ និង ស៊ីរ៉ិ សាវីណា**

**(តពីលេខមុន)**

| លរ | ឈ្មោះ | ភេទ | លេខរូបថត | រឿងរ៉ាវទាក់ទងនឹងប្រវត្តិរូបសង្ខេប |
|---|---|---|---|---|
| ៧៧៧ | ហ៊ាន ហ៊ីង | ប្រុស | ៥០៤ | ២១.៦.៧៨ |
| ៧៧៨ | រ៉ ទឹមលន់ | ប្រុស | ៤៥ | ១.៤.៧៨ |
| ៧៧៩ | កុយ សារូ | ប្រុស | ៤៤ | ១.៤.៧៨ |
| ៧៨០ | គុល យ៉ាន់ខ | ប្រុស | ៤៣ | ១.៤.៧៨ |
| ៧៨១ | យូ ចាន់ | ប្រុស | ៤២ | ១.៤.៧៨ |
| ៧៨២ | ទេព យាប | ប្រុស | ៥៣៩ | ២៣.៦.៧៨ |
| ៧៨៣ | ចាន់ ស៊ឹម | ប្រុស | ៤១០ | ២១.៦.៧៨ |
| ៧៨៤ | ទេម ជាម | ប្រុស | ២៧៣ | ១៣.៦.៧៨ |
| ៧៨៥ | ជឿង ចាន់ | ប្រុស | ៣៩២ | ២១.៣.៧៨ |
| ៧៨៦ | គីម ភួង | ប្រុស | ១១ | ៣.៣.៧៨ |
| ៧៨៧ | ឡុង ថង | ប្រុស | ? | ១៣.៣.៧៨ |
| ៧៨៨ | ចៅង ផន | ប្រុស | ៣៤៦ | ១៩.៦.៧៨ |
| ៧៨៩ | ប៊ុន បូរ | ប្រុស | ៣៨០ | ២១.៦.៧៨ |
| ៧៩០ | អ៊ុន ផន | ប្រុស | ៣៧១ | ២១.៦.៧៨ |
| ៧៩១ | យាយ សំ | ស្រី | ៥២៥ | ២៨.៣.៧៨ (ស្ត្រីចំណាស់ជាងគេនៅក្នុងចំណោមរូបថតទាំងអស់) |
| ៧៩២ | សាម ឡឿ | ប្រុស | ៣២៩ | ១៩.៦.៧៨ |
| ៧៩៣ | លី អួន | ស្រី | ៥៣០ | ២៨.៣.៧៨ |
| ៧៩៤ | គយ ឡូម | ស្រី | ៥២៤ | ២៨.៣.៧៨ |
| ៧៩៥ | ប៊ុន ធឿន | ប្រុស | ១៥ | ២៧.៩.៧៨ |
| ៧៩៦ | ឡេង ប្រិល | ប្រុស | ១៤ | ២៥.៩.៧៨ |
| ៧៩៧ | ទឹម រីម | ប្រុស | ៥៦៥ | ៣០.៣.៧៨ |
| ៧៩៨ | ឡាំង មាន | ប្រុស | ៥៦៦ | ៣០.៣.៧៨ |
| ៧៩៩ | អ៊ូ ទៀង | ប្រុស | ៨ | ១.៤.៧៨ |
| ៨០០ | អៀង កុល | ប្រុស | ៥៥៩ | ២៣.៦.៧៨ |

| | | | | |
|---|---|---|---|---|
| ៨០១ | ព្រុំ ដុន | ប្រុស | ៨០៥ | ២៧.៤.៧៨ |
| ៨០២ | ចាន់ សាវុន | ប្រុស | ៣៨៧ | ២១.៦.៧៨ |
| ៨០៣ | យូថ្វាង សារិន | ប្រុស | ២ | ១.៦.៧៨ |
| ៨០៤ | អ៊ីង មេងហុង | ប្រុស | ៤០០ | ២១.៣.៧៨ |
| ៨០៥ | ម៉ាញស៊ិន-សាន | ប្រុស | ១៦ | ២.៦.៧៨ |
| ៨០៦ | សេក សារិម | ប្រុស | ១៨ | ២.៦.៧៨ |
| ៨០៧ | លឿង ហុងលី-មុំ | ប្រុស | ២០ | ២.៦.៧៨ |
| ៨០៨ | សុក ចាន់ថន | ប្រុស | ២១ | ២.៦.៧៨ |
| ៨០៩ | ប៉ែន ឌុល | ប្រុស | ២២ | ២.៦.៧៨ |
| ៨១០ | គង់ សំអាន | ប្រុស | ២៣ | ២.៦.៧៨ |
| ៨១១ | ពុត សាម៉ន | ប្រុស | ៤៧៩ | ២១.៦.៧៨ |
| ៨១២ | អែម ឃាម-លី | ប្រុស | ៥៦១ | ៣០.៣.៧៨ |
| ៨១៣ | ប៊ុន អ៊ុត | ប្រុស | ៧៨១ | ២០.៤.៧៨ |
| ៨១៤ | មាឃ កន | ប្រុស | ៧៨០ | ២០.៤.៧៨ |
| ៨១៥ | ញ៉ូ គុល | ប្រុស | ៧០៤ | ២៩.៦.៧៨ |
| ៨១៦ | យន យ៉ាន | ប្រុស | ៣៦៤ | ២១.៦.៧៨ |
| ៨១៧ | នៅ ប៉ុម | ប្រុស | ៣៦៣ | ២១.៦.៧៨ |
| ៨១៨ | ភិសាមិ ជិត | ប្រុស | ៥៦៤ | ៣០.៣.៧៨ (ថៃ?) |
| ៨១៩ | មាស ឡាន | ប្រុស | ២០៩ | ១០.៦.៧៨ |
| ៨២០ | ឡាច ហោ | ប្រុស | ២០៦ | ១០.៦.៧៨ |
| ៨២១ | ម៉ៅនិ-រី | ស្រី | ៧៥ | ៨.៣.៧៨ |
| ៨២២ | ញឹម យូឡុង | ប្រុស | ៥២៦ | ២៨.៣.៧៨ |
| ៨២៣ | សួន សៀង-សូត្រ | ប្រុស | ៥២៧ | ២៨.៣.៧៨ |
| ៨២៤ | ឈឹង ឈឿន | ប្រុស | ៣៦៥ | ២.៣.៧៨ |
| ៨២៥ | ពៅ សារី | ប្រុស | ៧៧៧ | ២០.៤.៧៨ |
| ៨២៦ | កែ យ៉ែម | ប្រុស | ៣៧៦ | ២១.៣.៧៨ |
| ៨២៧ | ខៀវ សំឡូត | ប្រុស | ៣៨៨ | ២១.៦.៧៨ |
| ៨២៨ | ម៉ៅ ផល | ប្រុស | ៦៦៦ | ២៨.៦.៧៨ |
| ៨២៩ | ចឹង គីមឃុង | ប្រុស | ៣៩៥ | ២១.៣.៧៨ |
| ៨៣០ | ខាងសួន-សំអួន | ប្រុស | ៦០៣ | ៣១.៣.៧៨ |
| ៨៣១ | វែន ភាន់ | ប្រុស | ៣៣៤ | ១៩.៦.៧៨ |
| ៨៣២ | ងួន ហៃ | ប្រុស | ៥៨៤ | ២៣.៦.៧៨ |

| | | | | |
|---|---|---|---|---|
| ៨៣៣ | សូ ខេន | ប្រុស | ៥៨៣ | ២៣.៦.៧៨ |
| ៨៣៤ | ដុំ សុខ | ប្រុស | ៥៨២ | ២៣.៦.៧៨ |
| ៨៣៥ | មាស ភន | ប្រុស | ៥៨០ | ២៣.៦.៧៨ |
| ៨៣៦ | ហោក អែល | ប្រុស | ៥៧៩ | ២៣.៦.៧៨ |
| ៨៣៧ | ហ៊ិន សុខជាង | ប្រុស | ៥៧៨ | ២៣.៦.៧៨ |
| ៨៣៨ | ខន ខុម-នី | ប្រុស | ៩៥ | ១១.៧.៧៨ |
| ៨៣៩ | ឈៀក លាងស្រេង | ប្រុស | ៩៣ | ១១.៧.៧៨ |
| ៨៤០ | ស្តើង ដេនរុម | ប្រុស | ៥ | ២.៦.៧៨ |
| ៨៤២ | ហ៊ុង យឿន | ស្រី | ៥២៩ | ២៨.៣.៧៨ |
| ៨៤៣ | លី អួន | ស្រី | ៥៣០ | ២៨.៣.៧៨ |
| ៨៤៤ | សាត ឌឹម | ប្រុស | ៥៣១ | ២៨.៣.៧៨ |
| ៨៤៥ | ពៅ អុន | ប្រុស | ៥៣២ | ២៨.៣.៧៨ |
| ៨៤៦ | ព្រំ អៀង | ប្រុស | ៥៣៣ | ២៨.៣.៧៨ |
| ៨៤៧ | អន យុន | ប្រុស | ៥៣៤ | ២៨.៣.៧៨ |
| ៨៤៨ | ពត ម៉យ | ប្រុស | ៥៣៥ | ២៨.៣.៧៨ |
| ៨៤៩ | ប្រែង អោក | ប្រុស | ៥៣៦ | ២៨.៣.៧៨ |
| ៨៥០ | ទន់ សាណាន | ប្រុស | ៥៣៧ | ២៨.៣.៧៨ |
| ៨៥១ | ហួត សារិ | ប្រុស | ៥៣៨ | ២៨.៣.៧៨ |
| ៨៥២ | ឆឹង សុន | ប្រុស | ៥៣៩ | ២៨.៣.៧៨ |
| ៨៥៣ | សួស សារណ្ណ | ស្រី | ៥៤០ | ២៨.៣.៧៨ |
| ៨៥៤ | ប៉ោ សូ | ប្រុស | ១១៨ | ៦.៦.៧៨ (ប៉ោ សូ) |
| ៨៥៥ | ធុន បាវ | ប្រុស | ១១៧ | ៦.៦.៧៨ |
| ៨៥៦ | ហោ សឿន | ប្រុស | ១១៦ | ៦.៦.៧៨ |
| ៨៥៧ | ញ៉ិ ជីនគ្រី | ប្រុស | ១១៥ | ៦.៦.៧៨ |
| ៨៥៨ | ឌុច ឡេង | ប្រុស | ១១៣ | ៦.៦.៧៨ |
| ៨៥៩ | ខៀវ សូត្រ | ប្រុស | ១១៤ | ៦.៦.៧៨ |
| ៨៦០ | សេង សាត | ប្រុស | ១១២ | ៦.៦.៧៨ |
| ៨៦១ | សុក សំអុន | ប្រុស | ៥៦២ | ២៣.៦.៧៨ |
| ៨៦២ | ពុត ឆៃ | ប្រុស | ៥៦១ | ២៣.៦.៧៨ |
| ៨៦៣ | សៅ មាន | ប្រុស | ៥៦៥ | ២៣.៦.៧៨ |
| ៨៦៤ | ជៀប ដាត | ប្រុស | ៥៧១ | ២៣.៦.៧៨ |
| ៨៦៥ | សុក អាត | ប្រុស | ៥៧០ | ២៣.៦.៧៨ |

| | | | | |
|---|---|---|---|---|
| ៨៦៦ | ឡឹក ភាង | ប្រុស | ៥០២ | ២១.៦.៧៨ |
| ៨៦៧ | កុច សារឿន | ប្រុស | ៥៨៦ | ៣០.៣.៧៨ |
| ៨៦៨ | កែ ជឿន | ប្រុស | ១៣០ | ៧.៦.៧៨ |
| ៨៦៩ | អុក វ៉ាត | ស្រី | ១១៨ | ៨.៨.៧៨ |
| ៨៧០ | នួន សាមាន | ប្រុស | ៥៧៦ | ៣០.៣.៧៨ |
| ៨៧១ | ទឹម សន | ប្រុស | ៥៦៨ | ២៣.៦.៧៨ |
| ៨៧២ | ចន សារឿន | ប្រុស | ៥៤១ | ២៨.៣.៧៨ |
| ៨៧៣ | នៅ សាលីន | ប្រុស | ៥៤២ | ២៨.៣.៧៨ |
| ៨៧៤ | សុក យុន | ប្រុស | ៥៤៣ | ២៨.៣.៧៨ |
| ៨៧៥ | ម៉ៅ ប៊ិន | ប្រុស | ៥៤៤ | ២៨.៣.៧៨ |
| ៨៧៦ | ប៉ែន រ៉ែន | ស្រី | ៥៤៥ | ២៨.៣.៧៨ |
| ៨៧៧ | អ៊ិម ជន-ស្រួយ | ប្រុស | ២០៥ | ១០.៦.៧៨ |
| ៨៧៨ | សុក ឈឿត | ប្រុស | ២៦៦ | ១២.៦.៧៨ |
| ៨៧៩ | ចាន់ សារ៉ុន | ប្រុស | ៣៨៧ | ២១.៦.៧៨ |
| ៨៨០ | ហួត លន់ | ប្រុស | ៣៩៤ | ២១.៦.៧៨ |
| ៨៨១ | ថោង ជន | ប្រុស | ៣៨៦ | ១៩.៦.៧៨ |
| ៨៨២ | ឡូត សុផុន | ប្រុស | ២៦២ | ១២.៦.៧៨ |
| ៨៨៣ | សេង ប៉ាវ | ប្រុស | ៩២ | ១១.៧.៧៨ |
| ៨៨៤ | ឈិន សាន | ប្រុស | ៥៦៣ | ៣០.៣.៧៨ |
| ៨៨៥ | ភ្លោក ឈិន | ប្រុស | ៥៦២ | ៣០.៣.៧៨ |
| ៨៨៦ | ថុង គីម | ប្រុស | ៥៥២ | ២៨.៣.៧៨ |
| ៨៨៧ | អ៊ឹង ដួន- ផល | ប្រុស | ៥៥១ | ២៨.៣.៧៨ |
| ៨៨៨ | លឹម គីមឡេង | ប្រុស | ៥៤៩ | ២៨.៣.៧៨ |
| ៨៨៩ | ជា លីម៉េង | ប្រុស | ៥៤៨ | ២៨.៣.៧៨ |
| ៨៩០ | អ៊ី ឌុនហាប | ប្រុស | ៥៤៧ | ២៨.៣.៧៨ |
| ៨៩១ | ឈៀម សារាម | ប្រុស | ៥៤៦ | ២៨.៣.៧៨ |
| ៨៩២ | ទាំ រ៉ិតសុណា | ប្រុស | ៧ | ២.៦.៧៨ |
| ៨៩៣ | គង់ លាស សំអាង | ប្រុស | ៨ | ២.៦.៧៨ |
| ៨៩៤ | ដាក់ សាឡាត | ប្រុស | ៩ | ២.៦.៧៨ |
| ៨៩៥ | មាស ហ៊ាងមុំ | ប្រុស | ១០ | ២.៦.៧៨ |
| ៨៩៦ | ស្តើង ដេនរ៉ុម | ប្រុស | ៥ | ២.៦.៧៨ |
| ៨៩៧ | ចាន់ សុងវ៉ា | ប្រុស | ៦ | ២.៦.៧៨ |

| | | | | |
|---|---|---|---|---|
| ៨៩៨ | យន់យ៉េន មៅឌី | ប្រុស | ១១ | ២.៦.៧៨ថៃ (?) |
| ៨៩៩ | ឡុង ឡាច -សាវុន | ប្រុស | ១២ | ២.៦.៧៨ |
| ៩០០ | ហង់ ស្រ៊ន-ភេង | ប្រុស | ១៣ | ២.៦.៧៨ |
| ៩០១ | ចាន់ ស្រ៊ុម-សុខន | ប្រុស | ១៤ | ២.៦.៧៨ |
| ៩០២ | យង់ អ៊ុវណ្ណៈ | ប្រុស | ១៥ | ២.៦.៧៨ |
| ៩០៣ | ម៉ាញ ស៊ុន-ស៊ាន | ប្រុស | ១៦ | ២.៦.៧៨ |
| ៩០៤ | ថោង ស៊ុ | ស្រី | ៥២០ | ១២.៨.៧៨ |
| ៩០៥ | ថោង យន | ស្រី | ៥១៩ | ២១.៦.៧៨ |
| ៩០៦ | ដេង ហឿម | ប្រុស | ៥១៨ | ២១.៦.៧៨ |
| ៩០៧ | ទូច តុន | ប្រុស | ៥១៧ | ២១.៦.៧៨ |
| ៩០៨ | រស់ ស្រ៊ាន | ស្រី | ៥១៨ | ២១.៦.៧៨ |
| ៩០៩ | អ៊ុន សំអាង | ប្រុស | ៧២០ | ៣០.៦.៧៨ |
| ៩១០ | ដិម ចន | ប្រុស | ៧២១ | ៣០.៦.៧៨ |
| ៩១១ | ប្រាក់ ឃួច | ប្រុស | ៧២២ | ៣០.៦.៧៨ |
| ៩១២ | ស្រី ឆាំ | ប្រុស | ៧២៣ | ៣០.៦.៧៨ |
| ៩១៣ | ម៉ក់ វ៉ៃ | ប្រុស | ៧២៤ | ៣០.៦.៧៨ |
| ៩១៤ | ដា សារឹម | ប្រុស | ៧២៥ | ៣០.៦.៧៨ |
| ៩១៥ | សេម មន | ប្រុស | ៧២៦ | ៣០.៦.៧៨ |
| ៩១៦ | យក់ ហ៊ិត | ប្រុស | ៧១៨ | ៣០.៦.៧៨ |
| ៩១៧ | ឡី ឆួយ | ប្រុស | ៧១៩ | ៣០.៦.៧៨ |
| ៩១៨ | អឿ សំណុំ | ស្រី | ៧៣៣ | ៣០.៦.៧៨ |
| ៩១៩ | គីង ភឿរិន | ប្រុស | ៧៣២ | ៣០.៦.៧៨ |
| ៩២០ | ប៊ួរ សាងហុង | ប្រុស | ៧៣១ | ៣០.៦.៧៨ |
| ៩២១ | ទិត សៃ | ប្រុស | ៧៣០ | ៣០.៦.៧៨ |
| ៩២២ | ឈឹម សូជឿន | ប្រុស | ៧២៩ | ៣០.៦.៧៨ |
| ៩២៣ | ប៊ួ ប៊ុន | ប្រុស | ៧២៨ | ៣០.៦.៧៨ |
| ៩២៤ | ទួត សាន | ប្រុស | ៧២៧ | ៣០.៦.៧៨ |
| ៩២៥ | ឈី ហ៊-ដាន | ប្រុស | ៥៨៥ | ៣០.៣.៧៨ |
| ៩២៦ | ប៉ែន សុដាន់ | ប្រុស | ២០៨ | ១០.៦.៧៨ |
| ៩២៧ | មាស តម | ប្រុស | ៧៨០ | ២០.៤.៧៨ |
| ៩២៨ | អម ដា | ប្រុស | ៧៧៨ | ២០.៤.៧៨ |
| ៩២៩ | ហ៊ុង ហ៊ុម | ប្រុស | ៥៥០ | ២៨.៣.៧៨ |

| | | | | |
|---|---|---|---|---|
| ៩៣០ | ឈៀម សារាម | ប្រុស | ៥៤៦ | ២៨.៣.៧៨ |
| ៩៣១ | ដែង ឈៀច | ប្រុស | ៣៣៥ | ១៩.៦.៧៨ |
| ៩៣២ | មាន មិល-ខៀវ | ប្រុស | ២៦៥ | ១២.៦.៧៨ |
| ៩៣៣ | -- កង? | ប្រុស | ៣៦៣ | ២១.៣.៧៨ |
| ៩៣៤ | យ៉ែម | ប្រុស | ២៣៦ | ១១.៦.៧៨ |
| ៩៣៥ | ឈឿ អ៊ឹម | ប្រុស | ៣៧០ | ២១.៦.៧៨ |
| ៩៣៦ | -- អ៊ិន | ប្រុស | ២០៧ | ១០.៦.៧៨ |
| ៩៣៧ | ប៉ែន សុផាត | ប្រុស | ២០៨ | ១០.៦.៧៨ |
| ៩៣៨ | មឿ ដី-នី | ប្រុស | ១៣៩ | ១៤.៣.៧៨ |
| ៩៣៩ | សី ភាន | ប្រុស | ១៩ | ២.៦.៧៨ |
| ៩៤០ | ធីវ ឈន់ | ប្រុស | ៦២៣ | ២៦.៦.៧៨ |
| ៩៤១ | អ៊ុំង យុង | ប្រុស | ១៧ | ២.៦.៧៨ |
| ៩៤២ | សៅ យ៉យ | ប្រុស | ៥៧២ | ២៣.៦.៧៨ |
| ៩៤៣ | ខែក ឆុន | ប្រុស | ២១៨ | ២០.៧.៧៨ |
| ៩៤៤ | តៀម ហឿន | ស្រី | ២១៧ | ២០.៧.៧៨ |
| ៩៤៥ | ម៉ៅ ពូល-ថន | ប្រុស | ? | ១៣.៩.៧៨ |
| ៩៤៦ | ស៊ុម ឆន-គង់ | ប្រុស | ២១៦ | ២០.៧.៧៨ |
| ៩៤៧ | តេង ចាន់ថា | ប្រុស | ២២០ | ២០.៧.៧៨ |
| ៩៤៨ | លឹម ណាន | ប្រុស | ១៩ | ២០.៧.៧៨ |
| ៩៤៩ | សួន ទឹម | ប្រុស | ៩៧ | ១១.៧.៧៨ |
| ៩៥០ | ញ៉ែម ដៃ | ប្រុស | ៩៨ | ១១.៧.៧៨ |
| ៩៥១ | អ៊ុក ព្រុំ-សិត | ប្រុស | ៩៩ | ១២.៧.៧៨ |
| ៩៥២ | សូ ស៊ុន | ប្រុស | ១០០ | ១២.៧.៧៨ |
| ៩៥៣ | មោក សួ | ប្រុស | ១០១ | ១២.៧.៧៨ |
| ៩៥៤ | កង រ៉ែន | ប្រុស | ១០២ | ១២.៧.៧៨ |
| ៩៥៥ | ទូច ពីវ | ប្រុស | ១១ | ២២.៩.៧៨ |
| ៩៥៦ | ជា ណា | ប្រុស | ១០ | ១០.៩.៧៨ |
| ៩៥៧ | ចាន់ មុត | ប្រុស | ១៣ | ២៤.៩.៧៨ |
| ៩៥៨ | ប៉ុញ ចាន់ | ប្រុស | ១២ | ២៤.៩.៧៨ |
| ៩៥៩ | គីម សៀ | ប្រុស | ២៨៤ | ១៥.៦.៧៨ |
| ៩៦០ | ង៉ោ សេង | ស្រី | ២៨៣ | ១៣.៦.៧៨ |
| ៩៦១ | ឈាង ប្រាំង | ប្រុស | ២៨២ | ១៥.៦.៧៨ **(នៅមានត)** |

# សំណាងក្នុងចំណោមអ្នកទោសមួយពាន់នាក់

ថៃ ស៊ីណា អាយុ៥៣ឆ្នាំ សព្វថ្ងៃរស់នៅស្រុកចុងកាល ខេត្តឧត្តរមានជ័យ គឺជាអតីតអ្នកទោសរបស់ខ្មែរក្រហមម្នាក់ ដែលរួចជីវិតក្នុងចំណោមអ្នកទោសមួយពាន់នាក់ដែលបានវាយសម្លាប់នៅក្នុងរណ្តៅសាកសពរួម ។



ថៃ ស៊ីណា ពេលផ្តល់បទសម្ភាសន៍នៅបរិវេណសាលាក្តីខ្មែរក្រហមក្នុងខែមេសា

ស៊ីណា បានរៀបរាប់ថា គាត់មានស្រុកកំណើតនៅភូមិសំបួរ ឃុំសំបួរ ស្រុកមង្គលបូរី ខេត្តបាត់ដំបង (បច្ចុប្បន្នខេត្តបន្ទាយមានជ័យ) ។ គាត់ជាកូនទីពីរក្នុងចំណោមបងប្អូនបួននាក់ ដែលមានម្តាយឈ្មោះ ហង់ ណា ជាមេផ្ទះ និងឪពុកឈ្មោះ ថៃ មិត្ត ។ ឪពុករបស់ ស៊ីណា បានប្រលងជាប់អាហារូបករណ៍ទៅសិក្សានៅប្រទេសបារាំងរយៈពេលប្រាំពីរឆ្នាំ ខាងផ្នែកជំងឺទូទៅ ក្រោយពីរៀបការជាមួយម្តាយគាត់បានរយៈពេលជាងពីរឆ្នាំ ។ ឪពុក ស៊ីណា បានត្រឡប់មកប្រទេសកម្ពុជា និងបានចូលធ្វើការនៅមន្ទីរពេទ្យមង្គលបូរី ឬហៅថា (ពេទ្យជប៉ុន) នៅឆ្នាំ១៩៦៦ ។

នៅសម័យនោះ គ្រួសារ ស៊ីណា មានជីវភាពធូរធា ដោយសារមានឪពុកជាវេជ្ជបណ្ឌិត ។ ស៊ីណា បានចូលរៀននៅសាលាមធ្យមសិក្សាចំណោមរហូតដល់ថ្នាក់ទី៧ (សង្គមចាស់) ទើបគាត់ឈប់រៀនព្រោះកងយោធារំដោះខ្មែរក្រហមដែលមានមូលដ្ឋាននៅស្រែសាម៉ាន ម៉ាឡៃ និង សាស្តា បានចូលមកវាយលុកក្នុងភូមិ ។ ស៊ីណា បានស្នាក់នៅផ្ទះជាមួយឪពុកម្តាយបានរយៈពេលមួយឆ្នាំ ទើបនៅឆ្នាំ១៩៧៥ យោធាខ្មែរក្រហមវាយរំដោះបានស្រុកមង្គលបូរីទាំងមូល ។ ខ្មែរក្រហមបានចោទគ្រួសារ ស៊ីណា ថាជា "ពួកសក្តិភូមិ ជញ្ជក់ឈាមប្រជាជន" (ព្រោះឪពុកគាត់ជាវេជ្ជបណ្ឌិត និងមានជីវភាពធូរធាសម្រាប់ចិញ្ចឹមគ្រួសារ និងបងប្អូន) រួចហើយបញ្ជូនគ្រួសារគាត់ឲ្យទៅនៅភូមិរោងគោកណ្តាល ។ នៅទីនោះ ខ្មែរក្រហមបានបំបែក ស៊ីណា ចេញពីឪពុកម្តាយដោយឲ្យទៅធ្វើការនៅក្នុងកងកុមារ និងបានចាត់តាំងគាត់ឲ្យដើររុះរើផ្ទះប្រជាជនទម្លាក់ទឹកស្រះ និងវាយព្រះវិហារវត្តរោងគោកណ្តាលចោល ។ ប៉ុន្តែដោយសារ ស៊ីណា បដិសេធចំពោះកិច្ចការទាំងនោះ ទើបយោធាដែលប្រចាំការនៅក្នុងភូមិបានចោទគាត់ថា "ប្រឆាំងនឹងអង្គការ រួចហើយតាមរកចាប់ខ្លួនគាត់យកទៅសម្លាប់ចោល" ។ ខណៈនោះ ក្មួយស្រីរបស់ ស៊ីណា ពីរនាក់ឈ្មោះ ឃីម និង ឈៀម ដែលបានចូលបម្រើកងទ័ពរំដោះខ្មែរក្រហមនៅម៉ាឡៃ ហើយដែលត្រូវបានបញ្ជូនឲ្យមកមើលការខុសត្រូវប្រជាជននៅតំបន់ ស៊ីណា រស់នៅ បាននាំ ស៊ីណា គេចខ្លួន និង បញ្ជូនឲ្យទៅរស់នៅជាមួយម្តាយមីងរបស់គាត់ ជាប្រជាជន១៨មេសា (អ្នកមូលដ្ឋាន) នៅវាលស្រែ សាម៉ានវិញ ។

ស៊ីណា រស់នៅជាមួយម្តាយមីងបានរយៈពេលបីខែ ទើបខ្មែរក្រហមចាត់តាំងគាត់ឲ្យចូលធ្វើការនៅក្នុងកងចល័តពិសេស នៅគុតតាសត ក្នុងស្រុកអូរជ្រៅ ដែលមានសមាជិកសរុបទាំងអស់៣៣នាក់ ក្រោមការគ្រប់គ្រងរបស់ឈ្មោះ យិន ជាប្រធានកង ។ ស៊ីណា មានភារកិច្ចលើកដីទប់ទំនប់ ដែលត្រូវទឹកហូរកាត់ដាច់នៅក្នុងតំបន់របស់គាត់ ហើយដែលកងចល័តនៅតាមសហករណ៍មិនអាចធ្វើបាន ។

នៅឆ្នាំ១៩៧៦ អង្គការបានដកកងពិសេសរបស់ ស៊ីណា ឲ្យទៅកាប់ដើមឬស្សីនៅជំទៀងលើ និងប៉ាងរលឹម ស្ថិតនៅប៉ៃលិន ដោយប្រាប់ថា យកទៅផ្តល់ឲ្យកង៣២ នៅបឹងទន្លេសាប ដើម្បីក្រងព្រួលសម្រាប់ដាក់ត្រីយកទៅផ្គត់ផ្គង់កងទ័ព ។ ពេលទៅដល់ដំបូង

តំបន់នោះមានសភាពស្ងប់ស្ងាត់យ៉ាងខ្លាំងព្រោះគ្របដណ្តប់ដោយព្រៃឈើក្រាស់ និងសម្បូរទៅដោយត្បូង និងសត្វព្រៃគ្រប់ប្រភេទដែរ ។ នៅទីនោះ កងរបស់ ស៊ីណា ទទួលបានរបបគ្រប់គ្រាន់ គឺបាយហូបជាមួយនឹងត្រីងៀត ប៉ុន្តែគាត់ក៏ត្រូវធ្វើការងារធ្ងន់ធ្ងរដែរដោយពេលខ្លះអង្គការស្នើឫស្សីចំនួនមួយឡានតុងហ្វឹង (ផលិតនៅប្រទេសចិន) តែប្រធានកងប្រើឲ្យកងពិសេសកាប់រហូតដល់ទៅពីរឡាន ។

ស្របពេលនោះ សមាជិកក្នុងកងរបស់ ស៊ីណា ធ្លាក់ខ្លួនឈឺធ្ងន់ និងខ្លះទៀតបានដេកស្លាប់នៅ ក្នុងអង្រឹងតែម្តងដោយសារជំងឺគ្រុនចាញ់ ដែលមានសមាជិកស្លាប់ទាំងអស់ជាង១០នាក់ ។ ចំណែក ស៊ីណា ក៏មានជំងឺគ្រុនចាញ់ដែរ ប៉ុន្តែគាត់ត្រូវបានគ្រូខ្មែរនៅតំបន់នោះអុជលើដងខ្លួន ទើបគាត់បានជាសះស្បើយរហូតមកដល់សព្វថ្ងៃនេះ ។

នៅចុងឆ្នាំ១៩៧៧ យោធាខ្មែរក្រហមមកពីភូមិភាគនិរតីបានទៅប្រមូលកាំភ្លើងទាំងអស់ពីកងចល័តពិសេសរបស់ ស៊ីណា ដោយកុហកថា "អង្គការនឹងមានការងារថ្មីឲ្យធ្វើ" ។ តាមពិតយោធាទាំងនោះ បានដឹកកងរបស់ ស៊ីណា យកទៅដាក់នៅគុកកកោះ ស្ថិតនៅម្តុំស្វាយដូនកែវ ស្រុកបាកាន ខេត្តពោធិ៍សាត់ ដោយចោទថាជាប់ទាក់ទងជាមួយ រស់ ញឹម លេខាភូមិភាគពាយ័ព្យដែលក្បត់នឹងអង្គការ ។

នៅទីនោះ ស៊ីណា ត្រូវបានប្រធានគុកដាក់ទណ្ឌកម្មឲ្យអូសរនាស់ និងនង្គ័លភ្ជួរស្រែជាមួយនឹងអ្នកទោសផ្សេងទៀត ។ មានមិត្តភក្តិរបស់ ស៊ីណា ម្នាក់ឈ្មោះ ណង មិនអាចស៊ូទ្រាំនឹងការងារធ្ងន់ធ្ងរនេះបាន ក៏ត្រូវឈ្មោះ ម៉ែត មកហៅយកទៅនៅវេលាម៉ោង៣រសៀល ។ ភ្លាមនោះៗ ម៉ែតបានហៅកម្មាភិបាល និងអ្នកទោសសរុបទាំងអស់ប្រមាណជិតមួយពាន់នាក់មកប្រជុំ ដោយប្រកាសប្រាប់ថា "ចាប់បានខ្មាំងក្បត់នឹងបដិវត្តន៍ ហើយអង្គការនឹងមិនអត់ឱនឲ្យជាដាច់ខាត" ។ បន្ទាប់មក ស៊ីណា ឃើញឆ្មាំគុកបណ្តើរ ណង ចេញពីរោងវែងមកដាក់នៅខាងមុខអង្គប្រជុំ ។ ខណៈនោះឈ្មោះ ម៉ែត បានយកឫស្សីចុងស្រួចមកដោតទម្លុះដៃទាំងសងខាងរបស់ ណង ទៅនឹងដី រួចហើយយកពូថៅពុះឆ្អឹងខ្នងរបស់ ណង រហូតដល់ស្លាប់ ។ ឃើញដូច្នេះ ស៊ីណា និងអ្នកទោសនៅទីនោះមានការតក់ស្លុត និងរន្ធត់គ្រប់គ្នា ហើយម្នាក់ៗបានខិតខំធ្វើការងារកាន់តែខ្លាំងថែមទៀត ទោះបីជាឈឺគ្រុនខ្លាំងយ៉ាងណាក៏ដោយ ។

ស៊ីណា ជាប់ឃុំឃាំងក្នុងគុកកកោះបានរយៈពេលពីរខែ ទើប ម៉ែត ផ្លាស់ប្តូរគាត់យកទៅដាក់គុក នៅចាហួយ ឬហៅថា (មន្ទីរ៣២) ព្រោះ ម៉ែត ត្រូវផ្លាស់ទៅគ្រប់គ្រងនៅទីនោះដែរ (ក្រោយមក មានឈ្មោះ ឡុញ មកជំនួស ម៉ែត ហើយនៅចុងឆ្នាំ១៩៧៨ មាននារី ឃឹម មកពីនិរតីមកគ្រប់គ្រងជំនួស ឡុញ បន្តទៀត) ។ នៅទីនោះ ស៊ីណា ឃើញឆ្មាំគុកយកទៅអ្នកទោសទៅសម្លាប់រាល់ថ្ងៃ ដោយក្នុងមួយថ្ងៃសម្លាប់ប្រមាណជា១៥នាក់ ដែលដំបូងប្រធានកងនារី បន្ទាប់មកប្រធាន ក្រុម និងប្រធានពួក ។ ចំណែកអ្នកទោសស្រីផ្សេងទៀត ត្រូវបានឆ្មាំគុកនាំគ្នារំលោភមុនពេលយកទៅសម្លាប់ចោល ។

ថ្ងៃមួយ ពេល ម៉ែត បញ្ជា ស៊ីណា ឲ្យទៅអូសនង្គ័ល ស៊ីណា បាននិយាយតបទៅ ម៉ែត វិញថា មិនដែលនរណាបង្ខំឲ្យធ្វើការ ហើយ មិនឲ្យហូបឆ្អែតទេ ។ ក្រោយពីនិយាយរួច ម៉ែត បានចាប់ ស៊ីណា ចងដៃផ្អោបជាប់នឹងដើមទ្រូង រួចឃុំទុករយៈពេលមួយថ្ងៃ ។ នៅវេលាម៉ោង១២យប់ថ្ងៃបន្ទាប់ ឆ្មាំគុកបានបណ្តើរ ស៊ីណា រួមជាមួយអ្នកទោស១០នាក់ផ្សេងទៀតទៅវាលសំសាន្ត ដែលនៅទីនោះមានរណ្តៅបណ្តោយប្រវែង១០០ម៉ែត្រ និងទទឹង៦០ម៉ែត្រ ដែលប្រធានគុកបានបញ្ជាឲ្យកងរបស់ ស៊ីណា ជីកទុករួចជាស្រេច ។ ពេលទៅដល់មាត់រណ្តៅ ឆ្មាំគុកដែលឈរនៅខាងមុខ ស៊ីណា បានបញ្ជាឲ្យ ស៊ីណា លុតជង្គង់រួចហើយយកចបជីកប្រវែងកន្លះម៉ែត្រកាប់កញ្ចឹងកគាត់ ប៉ុន្តែសំណាងល្អ គាត់បាន ផ្តេកខ្លួនមក



ស្លាកស្នាមនៅលើដៃស្តាំដែលឈ្លបខ្មែរក្រហមកាប់ទៅលើ ស៊ីណា

ក្រោយក៏ត្រូវចំដៃខាងស្តាំ (បន្សល់ស្លាកស្នាមរហូតមកដល់ពេលសព្វថ្ងៃ) ធ្វើឲ្យគាត់សន្លប់លែងដឹងខ្លួន ។ ឃើញដូច្នេះ ឆ្មាំគុកបានរុញ ស៊ីណា ទម្លាក់ចូលទៅក្នុងរណ្តៅរួមជាមួយសាកសពអ្នកទោសប្រមាណមួយពាន់នាក់ដែលបានសម្លាប់រួចហើយ ។

នៅវេលាម៉ោងបីទៀបភ្លឺ ស៊ីណា បានដឹងខ្លួនឡើងវិញ ហើយបានខាំស្រាយចំណងរហូតរបូត ទើបរត់ទៅលាក់ខ្លួននៅភ្នំត្រដាក់ចិត្ត ។ ស៊ីណា បានរស់នៅក្នុងព្រៃរហូតដល់ពេលកងទ័ពវៀតណាមវាយចូលមកនៅឆ្នាំ១៩៧៩ ទើបគាត់វិលត្រឡប់ទៅរកឪពុកម្តាយ និងបងប្អូននៅស្រុកកំណើតវិញ ។ ប៉ុន្តែ ពេលទៅដល់ភូមិ ទើប ស៊ីណា ដឹងថាឪពុកគាត់ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ហើយ ។

ដោយសារគំនុំ និងការឈឺចាប់ ទើបនៅឆ្នាំ១៩៨៣ ស៊ីណា បានចូលបម្រើកងទ័ពរដ្ឋកម្ពុជា ។ ស៊ីណា ត្រូវបានបញ្ជូនឲ្យទៅសមរភូមិស្រុកជាំក្សាន្ត ក្នុងខេត្តព្រះវិហារ ដើម្បីវាយជាមួយកងទ័ពខ្មែរក្រហមដែលមានមូលដ្ឋាននៅតំបន់ប្រាសាទព្រះវិហារ ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏កងពល របស់ ស៊ីណា មិនដែលវាយចូលទៅដល់មូលដ្ឋានរបស់ខ្មែរក្រហមដែរ ព្រោះតំបន់នោះគ្រប់គ្រងយ៉ាងរឹងមាំពីសំណាក់យោធារបស់ តាម៉ុក ។

រហូតមកដល់ឆ្នាំ១៩៨៨ ស៊ីណា បានចាកចេញពីកងទ័ពមកប្រកបមុខរបរធ្វើស្រែ និងធ្វើចម្ការវិញ ។

នៅពេលថ្មីៗនេះ ស៊ីណា ត្រូវបានប្រជាជននៅក្នុងឃុំជ្រើសរើសគាត់ឲ្យធ្វើជាគណៈកម្មាធិការ និងជាអាចារ្យនៅវត្តភ្នំដើងទៀន ។

តាមរយៈការរៀនសូត្រធម៌អាថ៌ និងការអញ្ជើញមកចូលរួមសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅភ្នំពេញ ស៊ីណា មានប្រសាសន៍ថា «គាត់លែងមានកំហឹងជាមួយមេដឹកនាំទាំងនោះហើយ នៅពេលគាត់ឃើញភាពចាស់របស់ ខៀវ សំផន ផ្ទាល់ ប៉ុន្តែគាត់ចង់ឲ្យមេដឹកនាំទាំងនោះទទួលផលកម្មដូចអ្វីដែលខ្មែរក្រហមបានប្រព្រឹត្តមកលើរូបគាត់» ។

**សោម ប៊ុនថន**

# ខ្សែភាពយន្តឯកសាររឿង "ក្បង់ទឹកទន្លេ"



«ក្បង់ទឹកទន្លេ» គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត «ក្បង់ទឹកទន្លេ» ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១២ហើយ ។ «ក្បង់ទឹកទន្លេ» បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញក ព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើប សហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ ។ ខ្សែភាពយន្តឯកសារនេះ ក៏គ្រោងនឹងដាក់បញ្ចាំងតាមសាកលវិទ្យាល័យ និងភូមិចំនួន៦០ នៅទូទាំងប្រទេសកម្ពុជា ដោយបើកឲ្យមានការពិភាក្សាស្តីពីការផ្លាស់ប្តូរបរិស្ថាន ដើម្បីស្វែងរកដំណោះស្រាយ ។ ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃសុក្រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ព័ត៌មានបន្ថែមសូមទាក់ទងកញ្ញា សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខៈ ០១២ ៥១១ ៩១៤ ។

អ៊ីម៉ែល : *truthfatily.s@dccam.org* គេហទំព័រ : *www.ariverchangescourse.com*

# ពីអតីតឈ្លបខ្មែរក្រហម មកជាឆ្មាំរក្សាប្រាសាទកោះកែរ




ព្រឹម ដិន ពេលផ្តល់បទសម្ភាសន៍នៅមុខប្រាសាទកោះកែរកាលពីខែឧសភា

ក្នុងឯកសណ្ឋានជាឆ្មាំយាមនៅតំបន់ប្រាសាទកោះកែរ មានខោអាវពណ៌ទឹកប៊ិចចាស់ ព្រឹម ដិន តែងតែជិះកង់កញ្ចាស់របស់គាត់ក្នុងចម្ងាយប្រមាណពីរគីឡូម៉ែត្រពីផ្ទះទៅកន្លែងយាមនៅប្រាសាទកោះកែរ និងត្រឡប់មកផ្ទះជារាងរាល់ថ្ងៃអស់រយៈពេលជាង១០ឆ្នាំមកហើយ ។ ក្នុងវ័យ៦៨ឆ្នាំ តាដិន មានសម្បុរសជ្រះរាងស្គមខ្ពស់ និងសក់រួញអង្គាំរដី បាននិយាយរៀបរាប់អំពីបទពិសោធន៍ជីវិតកាលពីវ័យក្មេង និងការបម្រើការងារជាកងឈ្លបនៅក្នុងរបបខ្មែរក្រហម ដោយសំឡេងរងឹនៗ ។

តាដិន មានស្រុកកំណើតនៅភូមិកោះកែរ ឃុំកោះកែរ ស្រុកជីក្រែង ខេត្តសៀមរាប ។ ភូមិកោះកែរ ត្រូវបានប្តូរឲ្យស្ថិតនៅក្នុងឃុំស្រយ៉ង ស្រុកកូលែន ខេត្តព្រះវិហារ បន្ទាប់ពីសម្តេចព្រះនរោត្តម សីហនុ បង្កើតខេត្តព្រះវិហារ ខណៈពេលដែលប្រទេសកម្ពុជាបានឈ្នះក្តីរឿងប្រាសាទព្រះវិហារនៅតុលាការយុត្តិធម៌អន្តរជាតិ នៅទីក្រុងឡាអេ ក្នុងឆ្នាំ១៩៦២ ។ តាដិន មានប្រពន្ធសរុបទាំងអស់បួននាក់ ។ ប្រពន្ធចុងក្រោយឈ្មោះ ឆែប ឡូ អាយុ ៦២ឆ្នាំ និងមានកូនប្រុសពីរនាក់រស់នៅក្នុងបន្ទុកគ្រួសារ ។ តាដិន មានឪពុកឈ្មោះ ព្រឹម និង ម្តាយឈ្មោះ ស សិទ្ធ គាត់ទាំងពីរបានស្លាប់នៅក្នុងរបបខ្មែរក្រហមដោយសារជំងឺ ។ តាដិន មានបងប្អូនបង្កើតចំនួនបីនាក់ ប្រុសពីរនាក់ ស្រីម្នាក់ ។

តាដិន មិនបានចូលរៀនទេកាលពីនៅក្មេង ពីព្រោះភូមិកោះកែរមិនមានសាលារៀន ។ តាដិន ត្រូវទៅឃ្វាលគោឃ្វាលក្របីនៅតាមវាលស្រែ និងជួយឪពុកដែលស៊ីឈ្នួលសម្អាតរូបចម្លាក់នៅកន្លែងប្រាសាទកោះកែរឲ្យជនជាតិបារាំង នៅខណៈពេលដែលបារាំងនៅកាន់កាប់ទឹកដីខ្មែរនៅឡើយ ។ តាដិន បាននិយាយថា មានរូបចម្លាក់ជាច្រើនដែលបារាំងដាក់តំរៀបជាជួរៗ និងថតរូបចម្លាក់ទាំងនោះ ។ បន្ទាប់មកទើបបារាំងរើសយករូបណាដែលស្អាតៗ ដែលមិនបែកបាក់ដាក់ក្នុងឡានបើកចេញពីប្រាសាទកោះកែរ ។

កាលពីជំនាន់ដើម ភូមិកោះកែរមានវត្តមួយស្ថិតនៅជាប់នឹងប្រាសាទធំ ប៉ុន្តែវត្តត្រូវបានបោះបង់ចោលបន្ទាប់ពីព្រះសង្ឃបានចាកចេញអស់ពីវត្តនៅដើមឆ្នាំ១៩៧០ ។ បន្ទាប់ពីមានរដ្ឋប្រហារ លន់ នល់ នៅភូមិកោះកែរ ពុំមានកើតហេតុការណ៍អីធំដុំឡើយ គឺគ្រាន់តែមានការទម្លាក់គ្រាប់បែកបន្តិចបន្តួចនៅក្នុងព្រៃចម្ងាយពីភូមិប្រហែលពីរបីគីឡូម៉ែត្រពីភូមិ ។ ក្រោយមកទៀតទើបមានការអំពាវនាវពីសម្តេច ព្រះនរោត្តម សីហនុ ឲ្យកូនចៅចូលព្រៃម៉ាគីដើម្បីរំដោះជាតិ តាដិន បានចូលបម្រើជាកងឈ្លបរបស់ខ្មែរក្រហមនៅអំឡុងឆ្នាំ១៩៧៣ ដោយមានឈ្មោះ ស៊ិន

ជាប្រធានយោធាស្រុកគូលែន, ឈ្មោះ ត្រង់ ជាប្រធានឃុំ និង ឈ្មោះ ខុម ជាប្រធានកងឈ្លបនៅឃុំកោះកែរ ។

បន្ទាប់ពីបានឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជន១៧មេសា ឲ្យមករស់ក្នុងភូមិកោះកែរ ។ គាជិន បានបន្តការងារជាកងឈ្លបរបស់ខ្មែរក្រហមដដែល ។ គាជិន បានឲ្យដឹងថាកងឈ្លបមានភារកិច្ចដើរតាមដាន និងយកការណ៍ពីប្រជាជន បន្ទាប់មកត្រូវរាយការណ៍ពីសកម្មភាពរបស់ប្រជាជនចាស់ និងថ្មីដែលរស់នៅក្នុងភូមិដល់ប្រធានឈ្លប ។ នៅថ្ងៃមួយ ក្នុងឆ្នាំ១៩៧៥ គាជិន បានទទួលបញ្ជាឲ្យចាប់ប្រជាជន១៧មេសាម្នាក់ឈ្មោះ លី ដែលត្រូវខ្មែរក្រហមចោទថា ជាអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ ។ បន្ទាប់ពី គាជិន បានចងឈ្មោះ លី រួច កងឈ្លបផ្សេងទៀតបានបណ្តើរឈ្មោះ លី ទៅដល់ចំណុចមុខផ្ទះមួយដែលមានដំបូលប្រក់ស័ង្កសីក្នុងភូមិកោះកែរនេះ កងឈ្លបនោះក៏បាញ់សម្លាប់ឈ្មោះ លី ដោយចោទថាឈ្មោះ លី បានរើបម្រះធ្វើឲ្យដាច់ខ្សែចំណង ។ សាកសពរបស់ លី ត្រូវបានកងឈ្លបខ្មែរក្រហមយកទៅកប់ចោលនៅកន្លែងមួយក្បែរប្រសាទស្តេចដំរីស ។ សព្វថ្ងៃសាច់ញាតិរបស់ លី ដែលរស់នៅទីក្រុងភ្នំពេញតែងតែមកធ្វើបុណ្យបង្សុកូលឧទ្ទិសដល់វិញ្ញាណក្ខន្ធរបស់ លី នៅភូមិកោះកែរជាប្រចាំ ។ បើតាមអតីតកងឈ្លបខ្មែរក្រហម និងអ្នកភូមិផ្សេងទៀតបាននិយាយថា បន្ទាប់ពីទទួលជ័យជម្នះនៅឆ្នាំ១៩៧៥ ខ្មែរក្រហមចាប់បានអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរជាច្រើននាក់ ។ ទាហាន លន់ នល់ មួយចំនួនត្រូវបានខ្មែរក្រហមសម្លាប់ និងកប់នៅក្បែរប្រាសាទលិង្គ ។ ចំណែកមួយចំនួនធំទៀត ត្រូវបានបញ្ជូនទៅដាក់គុក និងសម្លាប់នៅមន្ទីរសន្តិសុខនៅក្នុងស្រុកគូលែន ។

គាជិន បានប្រាប់ថាក្នុងភូមិកោះកែរមានឈ្លបបួននាក់ និងត្រូវផ្លាស់វេណគ្នាក្នុងការដើរយកការណ៍ពីប្រជាជន ។ ទោះជាយ៉ាងនេះក្តី គាជិន បានបដិសេធថាខ្លួនមិនដែលបានរាយការណ៍ពីកំហុសរបស់អ្នកភូមិទៅថ្នាក់លើរបស់ខ្លួនទេ គឺតែងតែខ្សឹបប្រាប់នៅពេលដែលប្រជាជនណាម្នាក់បានធ្វើខុស និងឲ្យប្រជាជននោះឆាប់កែប្រែខ្លួនពីព្រោះមិនមែនមានតែ គាជិន ម្នាក់ឯងទេ នៅមានកងឈ្លបផ្សេងទៀតដែលចាំឃ្លាំមើល និងរាយការណ៍អំពីទោសកំហុសទាំងនោះទៅថ្នាក់លើ ។

គាជិនបន្ថែមថា កម្មាភិបាល និងកងឈ្លបខ្មែរក្រហមមានការហូបចុកគ្រប់គ្រាន់ជាងប្រជាជន គឺមានពេលខ្លះបានហូបបាយជាមួយមាន់ស្ងោរ និងពេលខ្លះទៀតហូបបបរឈ្លូស ។ ចំណែកប្រជាជនទទួលបានតែបបររាវៗ ។ ប្រជាជនមួយចំនួនត្រូវស្លាប់ដោយសារអត់អាហារ និងធ្វើការហួសកម្លាំង ។

នៅចុងឆ្នាំ១៩៧៧ ឈ្មោះ ត្រង់ ត្រូវបានអង្គការចាប់ខ្លួន និងសម្លាប់ ។ នៅខណៈពេលនោះឈ្មោះ វៃ ត្រូវបានតម្លើងជាប្រធានឃុំកោះកែរ ។ ប៉ុន្តែ វៃ ក៏ត្រូវបានខ្មែរក្រហមចាប់ដាក់ខ្នោះ និងបញ្ជូនយកទៅសម្លាប់ចោលនៅ ចុងឆ្នាំ១៩៧៨ដែរ ។ ចំណែក ខុម ដែលជាប្រធានកងឈ្លបនៅឃុំកោះកែរត្រូវបានប្រជាជនចាប់សម្លាប់ចោលក្នុងឆ្នាំ១៩៧៩ ពីព្រោះ ខុម ធ្លាប់បានចាប់បងប្អូនសាច់ញាតិរបស់គាត់យកទៅសម្លាប់ ។

នៅឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានចូលមកដល់ភូមិកោះកែរ គាជិន ត្រូវបានវៀតណាមជ្រើសតាំងឲ្យធ្វើជាកងស្វ័យត្រាណការពារភូមិ ។ តែ គាជិន បម្រើការងារនេះបានរយៈពេលតែពីរឆ្នាំ ក៏កើតមានហេតុការណ៍កងទ័ពវៀតណាមចោទប្រុសៗ ដែលរស់នៅក្នុងភូមិកោះកែរថាបានចូលដៃចូលជើង និងយកការណ៍ឲ្យកងទ័ពខ្មែរក្រហម ។ នៅឆ្នាំ១៩៨៣ វៀតណាមចាប់ផ្តើមចាប់មនុស្សប្រុសមួយចំនួនយកទៅឃុំឃាំងនៅស្រុកគូលែន ។ ជាអកុសលអ្នកភូមិមួយចំនួនត្រូវបានស្លាប់នៅក្នុងគុកដោយសារទឹកជំនន់លិចបរិវេណគុក ។ ហេតុការណ៍នេះបានធ្វើឲ្យអ្នកភូមិមានការភ័យខ្លាច និងបាននាំគ្នារត់ចូលខ្មែរក្រហម ។ បន្ទាប់មកខ្មែរក្រហមបាននាំអ្នកភូមិទៅរស់នៅភ្នំដងរែក ដែលមាន តាម៉ុក ជាអ្នកគ្រប់គ្រង ។ គាជិន បានចូលធ្វើជាទាហានខ្មែរក្រហម បន្ទាប់មក គាជិន បានផ្លាស់មកខាងផ្នែកដឹកជញ្ជូនគ្រាប់ឲ្យទាហានខ្មែរក្រហមនៅតាមសមរភូមិវិញ ។ នៅឆ្នាំ១៩៨៦ គាជិន ឈប់រស់នៅជាមួយខ្មែរក្រហម និងផ្លាស់មករស់នៅក្នុងភូមិដំបូកខ្ពស់ ឃុំគាសេន ស្រុកស្វាយលើវិញ ។ គាជិន និងគ្រួសារបានត្រឡប់មករស់នៅភូមិកោះកែរវិញអំឡុងពេលដែលទាហានរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិចូលមកប្រទេសកម្ពុជាឆ្នាំ១៩៩២ ។

**មីន សាណាស់**

# ការអត់ឃ្លាន និងអំពើប្រល័យពូជសាសន៍

## សំឡេងយុត្តិធម៌ ៖ អំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម

***កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា (វគ្គទី៤)***

ការផ្សាយក្នុងវគ្គទីបួននេះ យើងខ្ញុំផ្តោតសំខាន់ទៅលើអំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាន ។ ប្រជាជនកម្ពុជាទូទៅយល់ឃើញថាឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងរបបខ្មែរក្រហមគឺជាអំពើប្រល័យពូជសាសន៍ ។ ហេតុដូច្នេះ យើងខ្ញុំនឹងពិភាក្សាអំពីពាក្យ "អំពើប្រល័យពូជសាសន៍" ហើយថាតើការអត់ឃ្លានដែលបានបន្តឡើងនៅក្នុងរបបខ្មែរក្រហមអាចចាត់ទុកជាអំពើប្រល័យពូជសាសន៍បានដែរឬទេ?

មុននឹងយើងចាប់ផ្តើមបទអត្ថាធិប្បាយវគ្គទីបួននេះ យើងខ្ញុំសូមជម្រាបជូនប្រិយមិត្តអ្នកស្តាប់ អំពីការវិវឌ្ឍរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ដូចដែលយើងខ្ញុំបានជម្រាបជូនប្រិយមិត្តអ្នកស្តាប់ នៅក្នុងការផ្សាយវគ្គទីបីកន្លងមក អៀង សារី ដែលជាជនជាប់ចោទក្នុងសំណុំរឿង០០២ របស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានស្លាប់នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ។ នួន ជា ដែល ជាជនជាប់ចោទមួយរូបនៅក្នុងសំណុំរឿង០០២ បានដាក់ញត្តិមួយទៅអង្គជំនុំជម្រះសាលាដំបូងដោយអះអាងថា ខ្លួនពុំមានកាយសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមដំណើរការរបស់តុលាការនោះទេ ។ នួន ជា បានលើកយកហេតុផលសុខភាពចុះខ្សោយ និងកាយសម្បទាមិនរឹងមាំ ដោយសារតែវ័យជរារបស់ខ្លួន ។ បន្ទាប់ពីបានបញ្ចប់សវនាការទៅលើកាយសម្បទារបស់ នួន ជា អង្គជំនុំជម្រះសាលាដំបូងរកឃើញថា នួន ជា មានកាយសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមដំណើរការតុលាការ ។ ទន្ទឹមនឹងនេះ អង្គជំនុំជម្រះសាលាដំបូងបានចាត់វិធានការសមរម្យមួយចំនួនដើម្បីការពារការចុះខ្សោយផ្នែកសុខភាពរបស់ជនជាប់ចោទ នួន ជា ។ ស្របពេលគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចរបស់ខ្លួនទាក់ទងទៅនឹងទំហំនៃការបំបែកសំណុំរឿង០០២ ឲ្យទៅជាសំណុំរឿងតូចៗ ស្របតាមការស្នើសុំរបស់អង្គជំនុំជម្រះតុលាការកំពូល ។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបន្តការកាត់សេចក្តីទៅលើបទចោទប្រកាន់ចំនួនប្រាំក្នុងសំណុំរឿងទីមួយ



កងកុមារដែលគ្មានស្បែកជើងពាក់វិលត្រឡប់មកពីការដ្ឋានធ្វើពលកម្មវិញជាមួយទឹកមុខហត់ហេវនិងអស់កម្លាំងក្នុងរបបខ្មែរក្រហម

នៃសំណុំរឿង០០២ រួមមាន ៖ ឧក្រិដ្ឋកម្មទាំងឡាយដែលបាន កើតឡើងនៅពេលដែលមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ការជម្លៀសប្រជាជនកម្ពុជារាប់សែននាក់ទៅកាន់ភាគខាងជើងប្រទេសកម្ពុជានៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ ។ ប៉ុន្តែ ឧក្រិដ្ឋកម្មផ្សេងៗទៀត ដូចជា ការដ្ឋានការងារ សហករណ៍របស់ខ្មែរក្រហម មន្ទីរសន្តិសុខ វាលពិឃាត ការរៀបការដោយបង្ខំ និងអំពើប្រល័យពូជសាសន៍លើជនជាតិចាមនឹងត្រូវបន្តនៅពេលក្រោយ ។

បន្ទាប់ពីចេញសេចក្តីសម្រេចទាំងពីរខាងលើនេះ អង្គជំនុំជម្រះសាលាដំបូង បានបន្តការកាត់សេចក្តីរបស់ខ្លួនទៅលើភ័ស្តុតាងនៅក្នុងសំណុំរឿងដែលនៅសល់ជនជាប់ចោទចំនួនពីររូប រួមមាន ខៀវ សំផន និង នួន ជា ។

## សេចក្តីផ្តើម៖ និយមន័យនៃអំពើប្រល័យពូជសាសន៍

អំពើប្រល័យពូជសាសន៍ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៤៨ ពេលដែលអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ត្រូវបានធ្វើឡើង និងអនុម័តដោយអង្គការសហប្រជាជាតិ ។ ពាក្យ "ប្រល័យពូជសាសន៍" ត្រូវបានបង្កើតឡើងដោយ លោក រ៉ាហ្វែល លិមគិន (Raphael Lemkin) ដោយការផ្គុំបញ្ចូលគ្នានៃពាក្យ "ពូជសាសន៍" និង "សម្លាប់" ជាភាសាឡាតាំង ពាក្យ "ប្រល័យពូជសាសន៍" មានន័យថា ការសម្លាប់ដោយចេតនាទៅលើក្រុមមនុស្ស ឬពូជសាសន៍ណាមួយ ។ ពាក្យនេះត្រូវបានបង្កើតឡើងនៅពេលដែលគ្មានបទឧក្រិដ្ឋកម្មណាមួយអាចបង្ហាញពីការប៉ុនប៉ងរបស់បក្ស ណាហ្ស៊ី-អាឡឺម៉ង់ (German Nazi Party) ក្នុងការកម្ចាត់ចោលជនជាតិ ជ្វីប (Jewish) ទាំងអស់ចេញពីអឺរ៉ុប ។ ជាលទ្ធផល ច្បាប់ប្រឆាំងនឹងឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ត្រូវបានបង្កើតឡើងដើម្បីដាក់ទោសចំពោះឧក្រិដ្ឋកម្មទាំងឡាយណាដែលមានស្ថានភាពស្រដៀងគ្នានឹងឧក្រិដ្ឋកម្មដែលបានបង្កឡើងដោយ បក្សណាហ្ស៊ី-អាឡឺម៉ង់ ប្រឆាំងនឹងជនជាតិជ្វីប ។

ដើម្បីបង្ហាញថាបទឧក្រិដ្ឋមួយគឺជា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ យើងត្រូវការធាតុផ្សំចំនួនបីដូចតទៅ៖

ទី១) ការប្រព្រឹត្តសកម្មភាពណាមួយក្នុងចំណោមសកម្មភាពទាំងប្រាំ រួមមាន ◆ ការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម ◆ ការបង្កការឈឺចាប់ និងខូចខាតជាដំណំខាងផ្នែករាងកាយ ឬផ្នែកស្មារតីដល់សមាជិកទាំងឡាយនៅក្នុងក្រុម ◆ ការបង្កឡើងដោយចេតនានូវមហន្តរាយ ឬការហិនហោចដល់ស្ថានភាពរស់នៅរបស់សង្គមមនុស្ស ដោយបំផ្លិចបំផ្លាញទាំងស្រុង ឬដោយផ្នែកនៃក្រុម ◆ ការដាក់ចេញនូវវិធានការណ៍នានាដែលបង្ការមិនឲ្យមានការបង្កកំណើតទារកនៅក្នុងក្រុម និង ◆ ការយកកូនក្មេងចេញពីសង្គមមួយទៅដាក់ក្នុងសង្គមរស់នៅមួយទៀតដោយបង្ខំ ។

ទី២) សកម្មភាពទាំងអស់ខាងលើត្រូវតែផ្តោតពិសេសទៅលើសមាជិកទាំងអស់នៅក្នុងក្រុមណាមួយក្នុងចំណោមក្រុមជាក់លាក់ទាំងបួនរួមមាន៖ ◆ ក្រុមជាតិ ◆ ជាតិពន្ធុ ◆ពូជសាសន៍ ឬ ◆ សាសនា ។

ទី៣) ជនដែលប្រព្រឹត្តសកម្មភាពដែលបានរៀបរាប់ខាងដើម ប្រព្រឹត្តសកម្មភាពទាំងនោះ ក្នុងគោលបំណងជាក់លាក់ដើម្បីកម្ទេចក្រុមណាមួយដូចដែលបានរៀបរាប់ខាងលើ ។

## ឧទាហរណ៍

ទីមួយ ៖ ប្រសិនបើមានប្រទេសណាមួយប៉ុនប៉ងសម្លាប់ប្រជាជនកម្ពុជា ការសម្លាប់នោះអាចចាត់ចូលទៅក្នុងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។

ទីពីរ ៖ ជាតិពន្ធុ គឺក្រុមមនុស្សទាំងឡាយណាដែលមានសារៈតាដូចគ្នា និយាយភាសាដូចគ្នា មានប្រពៃណី និងការរស់នៅក្នុងសង្គមដូចគ្នា ។ ឧទាហរណ៍ ជនជាតិចារាយ ខ្មែរកម្ពុជាក្រោម និងជនជាតិភាគតិចផ្សេងទៀតដែលរស់នៅក្នុងប្រទេសកម្ពុជា ។ ជាមួយគ្នានេះដែរ ជាតិខ្មែរ ក៏អាចចាត់ចូលទៅក្នុងក្រុមជាតិដែលអាចរងគ្រោះដោយសារអំពើប្រល័យពូជសាសន៍បានដែរ ប្រសិន បើក្រុមទាំងនោះស្ថិតក្រោមការប៉ុនប៉ងបំផ្លាញពីក្រុមដទៃទៀត ។

ទីបី ៖ នៅក្នុងប្រទេសកម្ពុជា ក្រុមសាសនាសំដៅទៅលើអ្នកដែលកាន់សាសនាព្រះពុទ្ធ សាសនាឥស្លាម និងជនជាតិភាគតិចដទៃទៀតដែលកាន់សាសនាផ្សេងៗ ។ ជារឿយៗ ក្រុមជាតិពន្ធុ និងក្រុមនៃសាសនាអាចជាក្រុមតែមួយ ។ ជាឧទាហរណ៍ បើយោងតាមនិយមន័យនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍

ខ្មែរឥស្លាម ត្រូវបានចាត់ចូលទៅក្នុងក្រុមសាសនាផង និងក្រុមជាតិពន្ធុផង ។

ទីបួន ៖ ក្រុមពូជសាសន៍ អាចមានលក្ខណៈប្រហាក់ប្រហែលទៅនឹងក្រុមជាតិពន្ធុ ។ ប៉ុន្តែ យើងអាចកំណត់ ក្រុមពូជសាសន៍បានដោយផ្អែកទៅលើបុគ្គលិកលក្ខណៈខាងក្រៅរបស់ក្រុមនោះ ដូចជាពណ៌សម្បុរជាដើម ។ ប្រសិនបើមានក្រុមណាមួយដែលមានពណ៌សម្បុរស្បែកដូចគ្នា ត្រូវក្រុមមួយផ្សេងទៀត ដែលមានពណ៌សម្បុរស្បែកខុសគ្នាប៉ុនប៉ងកម្ទេច ទង្វើនេះអាចចាត់ចូលទៅក្នុងឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ ។

ជាសរុប មានតែក្រុមបួនដូចដែលបានរៀបរាប់ខាងលើប៉ុណ្ណោះ ដែលអាចជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ ។ ប្រសិនបើ បុគ្គល ឬមនុស្សមួយក្រុមត្រូវបានសម្លាប់ដោយហេតុផលនយោបាយ ឬស្ថិតនៅក្នុងក្រុមមួយដែលវណ្ណៈសង្គមរបស់ក្រុមនោះមិនត្រូវបានស្វាគមន៍នោះ ឧក្រិដ្ឋកម្មដែលកើតឡើងទៅលើក្រុម ឬបុគ្គលនោះ មិនអាចចាត់ទុកថាជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍បានទេ ។ ប៉ុន្តែ យើងអាចចាត់ទុកឧក្រិដ្ឋកម្មនោះ ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

ជាលទ្ធផល យើងអាចនិយាយបានថា ឧក្រិដ្ឋកម្មមួយអាចចាត់ចូលទៅក្នុងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍បាន លុះត្រាតែជនដែលប្រព្រឹត្តនោះមានគោលបំណងច្បាស់លាស់ក្នុងការបំផ្លាញទាំងស្រុង ឬដោយផ្នែកនៃក្រុមមនុស្សដែលបានរៀបរាប់ខាងដើម ។ ហេតុដូច្នេះ ប្រសិនបើក្រុមមនុស្សនៃសាសនាមួយត្រូវបានសម្លាប់ ដោយសារតែជនដែលប្រព្រឹត្តនោះមានគោលបំណងច្បាស់លាស់ក្នុងការបំផ្លាញក្រុមនោះ ដោយហេតុផលសាសនារបស់ក្រុមនោះ ទង្វើនោះអាចចាត់ទុកបានថាគឺជាអំពើប្រល័យពូជសាសន៍ ។

ជាក់ស្តែង ការសម្លាប់មនុស្សនៅប្រទេសរ៉្វាន់ដា ត្រូវបានគេរកឃើញថាជាអំពើប្រល័យពូជសាសន៍ ដោយសារតែក្រុមជនជាតិហ៊ូទូ បានប៉ុនប៉ងសម្លាប់ក្រុមជនជាតិទុតស៊ីទាំងអស់នៅក្នុងប្រទេសរ៉្វាន់ដា ។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា បានដោះស្រាយនូវបញ្ហាដ៏ស្មុគស្មាញ ជាច្រើនទាក់ទងទៅនឹងនិយមន័យនៃអំពើប្រល័យពូជសាសន៍ នៅពេលដែលមានការសម្លាប់យ៉ាងរង្គាលបានកើតឡើងនៅប្រទេសរ៉្វាន់ដា នៅក្នុងឆ្នាំ១៩៩៤ ។

## អំពើប្រល័យពូជសាសន៍ និង ការអត់ឃ្លាន

ប្រជាជនកម្ពុជាមួយចំនួនយល់ថា ការស្លាប់ដោយសារការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម គឺជាអំពើប្រល័យពូជសាសន៍ ដោយសារតែពាក្យ "ប្រល័យពូជសាសន៍" ត្រូវបានប្រើប្រាស់ដើម្បីសំដៅទៅលើហេតុការណ៍ដ៏អាក្រក់ណាមួយដែលធ្វើឲ្យប្រជាជនជាច្រើននាក់ស្លាប់បាត់បង់ជីវិត ។ ប៉ុន្តែ ប្រជាជនកម្ពុជាអាចនឹងមានការមិនសប្បាយចិត្ត ប្រសិនបើតុលាការរកឃើញថាឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមមិនមែនជាអំពើប្រល័យពូជសាសន៍ ។ ប្រជាជនកម្ពុជាអាចយល់ថាឧក្រិដ្ឋកម្មដែលបានកើតឡើងនោះមិនមានលក្ខណៈធ្ងន់ធ្ងរ ឬមិនពិត ។

ទោះបីជាយ៉ាងណាក៏ដោយ ការបង្អត់អាហារអាចចាត់ទុកជាធាតុសំខាន់មួយនៃអំពើប្រល័យពូជសាសន៍ ។ ការបង្ហាញថា ការអត់ឃ្លានដែលបានកើតឡើង គឺជាអំពើប្រល័យពូជសាសន៍មិនមែនផ្អែកសំខាន់ទៅលើស្ថានភាពដ៏អាក្រក់ ឬចំនួនប្រជាជនដែលបានស្លាប់ដោយសារការអត់ឃ្លាននោះទេ ។ ផ្ទុយទៅវិញ វាអាស្រ័យទៅលើកត្តាមួយចំនួន ថាតើជនដែលបង្កឲ្យមានការអត់ឃ្លាននោះមានចេតនាបង្កឲ្យមានការអត់ឃ្លានដើម្បីបំផ្លាញក្រុមនៃពូជសាសន៍ ជាតិពន្ធុ ក្រុមជាតិ ឬសាសនាណាមួយដែរ ឬទេ? ហេតុដូច្នេះ ចម្លើយសម្រាប់សំណួរដែលសួរថា តើការបង្អត់អាហារអាចជាអំពើប្រល័យពូជសាសន៍ដែរឬទេ គឺអាស្រ័យទៅលើចេតនារបស់ជនដែលប្រព្រឹត្តទង្វើនោះ ។ នៅក្នុងចំណុចមួយនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍បានចែងថា ឧក្រិដ្ឋកម្មមួយអាចចាត់ទុកជាអំពើប្រល័យពូជសាសន៍បាន នៅពេលដែលឧក្រិដ្ឋកម្មនោះស្តែងឡើងតាមរយៈ "ការដាក់កំហិតលក្ខខណ្ឌរស់នៅក្នុងគោលបំណងដើម្បីបំផ្លាញទាំងស្រុង ឬដោយផ្នែកនូវ" ក្រុមជាតិ ជាតិពន្ធុ ជាតិសាសន៍ ឬសាសនា ។ ដូច្នេះ ប្រសិនបើក្រុមណាមួយនៃក្រុមទាំងអស់ខាងដើមត្រូវបានកំណត់ជាគោលដៅសម្រាប់ការកម្ទេច ហើយការកម្ទេចនោះបង្កឡើងតាមរយៈការបង្អត់អាហារទៅលើមនុស្សភាគច្រើននៃក្រុមណាមួយស្ថានភាពនោះអាចចាត់ចូលទៅក្នុងបទឧក្រិដ្ឋនៃអំពើប្រល័យពូជសាសន៍បាន ។

ផ្ទុយទៅវិញ ប្រសិនបើរដ្ឋាភិបាលមួយគ្រាន់តែបានបង្កឲ្យមានលក្ខខណ្ឌរស់នៅមួយដែលលំបាក និងបានបង្កឲ្យប្រជាជនជាច្រើននាក់ស្លាប់ ប៉ុន្តែរដ្ឋាភិបាលនោះមិនបានរៀបចំគម្រោងណាមួយ ដើម្បីកម្ទេចក្រុមណាមួយទេនោះ ករណីនេះមិនត្រូវបានចាត់ថាជាឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ទេ ។

## អំពើប្រល័យពូជសាសន៍ និងការអត់ឃ្លានក្នុងរបបខ្មែរក្រហម

នៅពេលដែលយើងធ្វើការថ្លឹងថ្លែងរវាងនិយមន័យនៃអំពើប្រល័យពូជសាសន៍ និងស្ថានភាពដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហម យើងអាចយល់បានថា ការអត់ឃ្លានដែលបានកើតឡើងក្នុងរបបខ្មែរក្រហមមិនមែនជាអំពើប្រល័យពូជសាសន៍នោះទេ ។

យើងលើកឡើងយ៉ាងដូច្នេះ ដោយសារតែមេដឹកនាំខ្មែរក្រហមបានបង្កើតគោលនយោបាយមួយដែលផ្តោតសំខាន់ទៅលើការបង្កើនផលិតកម្មកសិកម្ម និងតម្រូវការចាំបាច់របស់បដិវត្តន៍ជាងតម្រូវការរបស់ប្រជាជន ។ មេដឹកនាំខ្មែរក្រហមបានបង្ខំប្រជាជនទាំងអស់ឲ្យធ្វើការ និងហូបបាយរួមគ្នា ។ ជាងនេះទៅទៀត ការងារដែលមេដឹកនាំខ្មែរក្រហមបានដាក់ឲ្យប្រជាជនកម្ពុជាធ្វើ មានរយៈពេលច្រើនម៉ោង និងរបបអាហារដែលបានចែកឲ្យប្រជាជនមិនគ្រប់គ្រាន់ ។ កត្តាទាំងអស់នេះបានបង្កឲ្យការអត់ឃ្លានកើតឡើង និងរាលដាលស្ទើរគ្រប់តំបន់នៃប្រទេសកម្ពុជា ។

ជាមួយគ្នានឹងនេះដែរ យើងគ្មានភស្តុតាងណាមួយដែលអាចបង្ហាញថា មេដឹកនាំខ្មែរក្រហមបានបង្កើតគោលនយោបាយបង្អត់អាហារប្រជាជន ក្នុងគោលបំណងដើម្បីកម្ទេចក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយនៅក្នុងប្រទេសកម្ពុជាដែលបណ្តាលឲ្យប្រជាជនជាច្រើននាក់ស្លាប់នោះឡើយ ។ ផ្ទុយទៅវិញ យើងមើលឃើញថាមេដឹកនាំខ្មែរក្រហមគ្រាន់តែចង់ពង្រីកការបង្កបង្កើនទិន្នផលស្រូវ និងដំណាំផ្សេងទៀតរបស់ខ្លួន ដោយមិនបានគិតពីប្រជាជនរាប់ពាន់នាក់ដែលអាចស្លាប់ដោយសារទង្វើរបស់ខ្លួន ។ បើទោះបីជាការមិនគិតគូរពីអាយុជីវិតរបស់ប្រជាជន គឺជារឿងមួយដ៏គួរឲ្យរន្ធត់ ប៉ុន្តែវាក៏មិនបានបង្ហាញពីគោលបំណងនៃអំពើប្រល័យពូជសាសន៍ឡើយ ។

ហេតុផលដែលថា ការអត់ឃ្លានដែលបានកើតឡើងក្នុងរបបខ្មែរក្រហមមិនមានការពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងប្រជាជនកម្ពុជា បានឆ្លុះបញ្ចាំងឲ្យឃើញពីភាពជាក់លាក់នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងភាពចង្អៀតនៃនិយមន័យនៃពាក្យ "អំពើប្រល័យពូជសាសន៍" ។

បើទោះបីជា ទង្វើដែលមេដឹកនាំខ្មែរក្រហមបានប្រព្រឹត្តដែលបានបង្កឲ្យការអត់ឃ្លានកើតឡើងនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេលនៃការកាន់អំណាចរបស់ខ្លួន និងបានបង្កឲ្យប្រជាជនកម្ពុជារាប់សែននាក់ស្លាប់បាត់បង់ជីវិត មិនមែនជាអំពើប្រល័យពូជសាសន៍ ក៏ប៉ុន្តែទង្វើនោះអាចចាត់ចូលទៅក្នុងបទឧក្រិដ្ឋកម្មអន្តរជាតិផ្សេងទៀត ដូចជា ឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ។

ជាងនេះទៅទៀត បើទោះបីជាអំពើប្រល័យពូជសាសន៍ត្រូវបានគេទទួលស្គាល់ថាជា "ឧក្រិដ្ឋកម្មនៃឧក្រិដ្ឋកម្ម" ប៉ុន្តែពុំមានចំណាត់ថ្នាក់ណាមួយត្រូវបានកំណត់តាមផ្លូវច្បាប់ ដែលថាឧក្រិដ្ឋកម្មអន្តរជាតិណាមួយមានចំណាត់ថ្នាក់ខ្ពស់ ឬទាបជាងឧក្រិដ្ឋកម្មអន្តរជាតិណាមួយឡើយ ។ ធាតុតែមួយគត់ដែលកំណត់ថា អំពើប្រល័យពូជសាសន៍ ខុសពីឧក្រិដ្ឋកម្មអន្តរជាតិដទៃផ្សេងទៀត គឺស្ថិតនៅចំណុចមួយ ថាតើជនដែលប្រព្រឹត្តអំពើនោះមានគោលបំណងជាក់លាក់ចង់កម្ទេចក្រុមណាមួយដែរឬទេ ។ ជារឿយៗ បណ្តាញផ្សព្វផ្សាយព័ត៌មានមួយចំនួន ច្រើនតែប្រើពាក្យ "ប្រល័យពូជសាសន៍" ដើម្បីពិពណ៌នាអំពីឧក្រិដ្ឋកម្មណាមួយដែលមានលក្ខណៈធ្ងន់ធ្ងរ ។

ជាសរុប បើយោងតាមផ្លូវច្បាប់ ការអត់ឃ្លានដែលកើតឡើងនៅក្នុងរបបខ្មែរក្រហម ប្រហែលជាមិនមែនជាអំពើប្រល័យពូជសាសន៍នោះទេ ។ ប៉ុន្តែ ការអត់ឃ្លានដែលបានកើតឡើងនោះនៅតែឆ្លុះបញ្ចាំងអំពីពេលវេលាមួយដែលប្រជាជនកម្ពុជាទទួលរងទុក្ខវេទនា និងការឈឺចាប់ធ្ងន់ធ្ងរ ព្រមទាំងទទួលនូវរងការសម្លាប់រង្គាលពីសំណាក់ខ្មែរក្រហម ។

ក្នុងន័យនេះ ប្រសិនបើនៅក្រៅប្រព័ន្ធច្បាប់ ប្រជាជនភាគច្រើនអាចយល់ថា ទង្វើដែលបានកើតឡើងទាំងអស់ក្នុងរបបខ្មែរក្រហមគឺជាអំពើប្រល័យពូជសាសន៍ ។

**រ៉េនឌល ដឹហ្វាល់កូ**

# សេចក្ដីសម្រេចបំបែកសំណុំរឿង០០២របស់អង្គជំនុំជម្រះសាលាដំបូងនៅរក្សាស្ថានភាពដើម

ឆ្លើយតបនឹងការរិះគន់លើបណ្ដឹងឧទ្ធរណ៍ដែលបានលើកឡើងថា សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលសម្រេចបំបែកបទចោទប្រកាន់នៅក្នុងសំណុំរឿង០០២ គឺធ្វើឡើងដោយពុំបានពិភាក្សាជាមួយភាគី និងផ្ដល់ជូននូវការ "ការរំពឹក" ដែលមានសំអាងហេតុតិចតួចនោះ ឥឡូវនេះ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចេញសេចក្ដីសម្រេចដែលមានកម្រាស់ដល់ទៅ៧៨ទំព័រ ដោយរក្សាសុពលភាពនៃវិសាលភាពសំណុំរឿង០០២ ដែលមានស្រាប់ និងដាក់ចេញនូវផែនការសាកល្បងមួយសម្រាប់សវនាការចំនួនពីរបន្ថែមទៀត ។ សេចក្ដីសម្រេចបន្តសំណុំរឿង០០២/០១ នៅក្នុងផែនការបច្ចុប្បន្នគឺពុំមែនធ្វើឡើងដោយពុំគិតដល់ពេលវេលាដែលអូសបន្លាយសម្រាប់សវនាការអង្គសេចក្ដី ការរំពឹងទុកដែលថា សាលក្រមនឹងអាចចេញក្នុងពេលឆាប់ៗខាងមុខ និងការក្រើនរំឭកដ៏ខ្លាំងក្លាអំពីសុខភាពរបស់ជនជាប់ចោទ ដែលសុទ្ធតែមានវ័យ៨០ឆ្នាំ ចាប់តាំងពីមរណភាពរបស់ អៀង សារី កាលពីខែមុននោះឡើយ ។

នៅថ្ងៃសវនាការក្នុងខែតុលា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបំបែកបទចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿង០០២ ដោយអនុលោមតាមវិធាន៨៩ស្ទួនពីរ បានចែងថា ៖

> នៅពេលប្រយោជន៍យុត្តិធម៌តម្រូវនៅដំណាក់កាលណាមួយអង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឲ្យបំបែកកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងជនជាប់ចោទមួយរូប ឬច្រើនរូប និងផ្នែក ដែលពាក់ព័ន្ធនឹងបទចោទខ្លះឬទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ រឿងក្ដីដែលបានបំបែកត្រូវយកមកជំនុំជម្រះ និងវិនិច្ឆ័យចេញសាលក្រមទៅតាមលំដាប់លំដោយ ដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាសមស្រប ។

អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថាសំណុំរឿង ០០២/០១ ដែលជាដំណាក់កាលដំបូងនៃភាពពុំមានកំណត់នូវចំនួនជាក់លាក់នៃសវនាការតូចៗបន្តបន្ទាប់គ្នា អាចដោះស្រាយបានត្រឹមគោលនយោបាយឧក្រិដ្ឋកម្មនៅទូទាំងប្រទេសមួយក្នុងចំណោមប្រាំ ដែលសម្រាប់អតីតមេដឹកនាំខ្មែរក្រហមត្រូវបានចោទប្រកាន់ឲ្យទទួលខុសត្រូវនោះគឺ ៖ ឧក្រិដ្ឋកម្មទាក់ទងនឹងការជម្លៀសប្រជាជនដោយបង្ខំចេញពីភ្នំពេញ ចាប់ផ្ដើមពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បញ្ហាជម្លៀសប្រជាជនកម្ពុជាជាបន្តបន្ទាប់រាប់ម៉ឺននាក់ដោយបង្ខំទៅភាគខាងជើងនៃប្រទេសរវាងចុងឆ្នាំ ១៩៧៥ និង១៩៧៧ និងទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ បទចោទប្រកាន់ដែលនៅសេសសល់ដែលដោះស្រាយបញ្ហាការងារនៅការដ្ឋាន និងសហករណ៍ មន្ទីរសន្តិសុខ ទីតាំងសម្លាប់ ការរៀបការដោយបង្ខំនិងអំពើប្រល័យពូជសាសន៍ ស្ថិតក្នុងភាពមិនប្រាកដប្រជាសម្រាប់សំណុំរឿងក្នុងថ្ងៃអនាគត ។ សហព្រះរាជអាជ្ញា បានដាក់សំណើភ្លាមៗ សុំឲ្យពិចារណាលើសេចក្ដីសម្រេចឡើងវិញ ដោយស្វែងរកការដាក់បញ្ចូលជម្រើសបទចោទដែលមានចរិតលក្ខណៈជាតំណាងច្រើនជាង ដោយមានការព្រួយបារម្ភថា វ័យកាន់តែចាស់ និងសុខភាពកាន់តែខ្សោយរបស់ជនជាប់ចោទអាចរារាំងដល់លទ្ធភាពនៃសវនាការបន្ថែមទៀត ។

អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលសំណើរបស់សហព្រះរាជអាជ្ញា ក៏ប៉ុន្តែវិសាលភាពនៃសវនាការដំណាក់កាលដំបូងបានទុកចំហអស់រយៈពេលលើសពីមួយឆ្នាំ ដោយសារ

អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា ខ្លួននឹងពិចារណាលើការបន្ថែមបទចោទ «នៅក្នុងដំណាក់កាលណាមួយ ដោយអាស្រ័យលើសិទ្ធិជនជាប់ចោទដែលត្រូវទទួលបានឱកាសក្នុងការរៀបចំការការពារមួយប្រកបដោយ ប្រសិទ្ធភាព ហើយភាគីនានាត្រូវបានជូនដំណឹងនៅក្នុងរយៈពេលសមស្រប» ។ នៅខែតុលា ឆ្នាំ២០១២ អង្គជំនុំជម្រះបានបន្ថែមទីតាំងសម្លាប់មួយកន្លែងទៀត តាមសំណើរបស់សហព្រះរាជអាជ្ញា និងច្រានចោលទីតាំងសម្លាប់ពីរកន្លែងផ្សេងទៀត ហើយសហព្រះរាជអាជ្ញាបានប្តឹងជំទាស់លើការច្រានចោលនេះ ។

ក្នុងសេចក្តីសម្រេចនៅខែកុម្ភៈ ឆ្នាំ២០១៣ របស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញនូវកំហុសឆ្គងផ្នែកច្បាប់មួយចំនួនរបស់អង្គជំនុំជម្រះសាលាដំបូង រួមទាំងកង្វះខាតសម្អាងហេតុទាក់ទងនឹង «របៀបនៃការបំបែកសំណុំរឿងដែលសម្រេចឲ្យបាននូវផលប្រយោជន៍នៃយុត្តិធម៌» និងការខកខានមិនបានប្រឹក្សាជាមួយភាគីទាំងអស់ស្តីអំពីលក្ខខណ្ឌក្នុងការបំបែកសំណុំរឿងដែលអង្គជំនុំជម្រះសាលាដំបូងបានពិចារណាទាំងភាពពុំចាំបាច់ផ្នែកច្បាប់ និងលទ្ធផលនៃការពន្យាពេលដែលពុំអាចទទួលយកបាន ។ នាពេលនោះអង្គជំនុំជម្រះសាលាដំបូង បានយល់ព្រមស្តាប់អំណះអំណាងរបស់សហព្រះរាជអាជ្ញាលើការពង្រីកសំណុំរឿង គឺបន្ទាប់ពី «សវនាការដែលមានរយៈពេលជិតមួយឆ្នាំ បានកន្លងផុតទៅហើយ លើអង្គសេចក្តីដោយគោរពតាមលក្ខខណ្ឌនៃដីកាបំបែកកិច្ចដំណើរការនីតិវិធីនេះ ដោយបានធ្វើឲ្យវិសាលភាពនៃសំណុំរឿង០០២/០១ចេញជារូបរាងយ៉ាងមានប្រសិទ្ធភាព» ។

អង្គជំនុំជម្រះតុលាការកំពូលបានលុបចោលសេចក្តីសម្រេចដំបូងស្តីពីការបំបែកសំណុំរឿង និងបានសម្រេចថាអង្គជំនុំជម្រះសាលាដំបូងត្រូវតែវាយតម្លៃឡើងវិញនូវវិធីសាស្ត្ររបស់ខ្លួនក្នុងការបំបែកសំណុំរឿង បន្ទាប់ពីបានស្តាប់សំណើរបស់ភាគី និងថ្លឹងថ្លែងនូវផលប្រយោជន៍របស់គ្រប់ភាគីតទល់នឹងអង្គហេតុពាក់ព័ន្ធទាំងអស់ដូចដែលបានពន្យល់នៅក្នុងផែនការរបស់ខ្លួនសម្រាប់វិនិច្ឆ័យបទចោទប្រកាន់ ដោយពុំរាប់បញ្ចូលនូវសវនាការដំណាក់កាលទីមួយ ។ បើទោះបីជាសវនាការរយៈពេលមួយឆ្នាំកន្លះបានកន្លងផុតទៅ ហើយការបញ្ចប់សវនាការភ័ស្តុតាង ក៏ឈានជិតដល់ដែរនោះ ស្រាប់តែអង្គជំនុំជម្រះសាលាដំបូង កំណត់កាលវិភាគសវនាការភ្លាមៗក្នុងរយៈពេលបីថ្ងៃដើម្បីស្តាប់យោបល់របស់ភាគីទាក់ទងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ។ សហព្រះរាជអាជ្ញា ដោយបានយល់ដឹងពីការពន្យារពេលនិងការខិតខំប្រឹងប្រែងកន្លងមក ខ្លួនបានយល់ឃើញថា បានស្វែងរកការដាក់បញ្ចូលបន្ថែមមន្ទីរសន្តិសុខស-២១ដើម្បីបង្កើនភាពជាតំណាងនៃបទចោទ ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទំនងជាបារម្ភថា ការពង្រីកបទចោទដើមអាចរារាំងដល់ពេលវេលាចេញសាលក្រម ហើយខ្លួនពុំបានស្នើសុំបន្ថែមឧក្រិដ្ឋកម្មនោះឡើយ ប៉ុន្តែខ្លួនបានគាំទ្រសំណើរបស់សហព្រះរាជអាជ្ញា ។ ផ្ទុយទៅវិញ មេធាវីការពារក្តីទាំងអស់អះអាងថា សិទ្ធិរបស់កូនក្តីខ្លួនអាចការពារបាន ប្រសិនបើកាត់ទោសលើភាពទាំងស្រុងនៃបទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។




នៅក្នុងសេចក្តីសម្រេចដែលមានសម្អាងហេតុ ដែលទើបនឹងចេញនាពេលថ្មីៗនេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់អំពីភាពសមស្របនៃការរក្សាស្ថានភាពឲ្យនៅដដែល ដោយរកឃើញនូវការធានាលើកស្ទួយផ្នែកច្បាប់ឲ្យបានប្រសើរបំផុត និង «ដើម្បីតំណាងឲ្យភាពត្រឹមត្រូវស្មើគ្នារវាងកត្តាមួយចំនួនដែលបានកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល និងភាពចាំបាច់ដើម្បីការពារលទ្ធភាពរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការសម្រេចឲ្យបាននូវការចេញសាលក្រមទាន់ពេលវេលាសម្រាប់សំណុំរឿង០០២» ដោយសារភាពចាស់ជរា និងសុខភាពទ្រុឌទ្រោមរបស់ជនជាប់ចោទទាំងពីរ និងជនរងគ្រោះទាំងឡាយ ។

កត្តាមួយដែលបានលើកឡើងដោយអង្គជំនុំជម្រះ

តុលាការកំពូលនោះ គឺកាតព្វកិច្ចក្នុងការធានា ថាវិសាលភាពនៃសំណុំរឿង០០២/០១ រួមទាំងការចោទប្រកាន់ជាតំណាងសមហេតុផលនៃបទចោទទាំងអស់ប្រឆាំងនឹងជនជាប់ចោទ ជារួមដូចជាលទ្ធភាពនៃការចូលរួមសវនាការបន្ថែមពីចម្ងាយ ។ យោងតាម ការចង្អុលបង្ហាញដោយអង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះសាលាដំបូងបកស្រាយកាតព្វកិច្ច ដោយអនុលោមតាមយុត្តិសាស្ត្រនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី *(ICTY)* ។ តុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានសង្កត់ធ្ងន់ ដោយយកមកពិចារណានូវ «កាលៈទេសៈពាក់ព័ន្ធនឹងសំណុំរឿង» នៅពេលដែលវាយតម្លៃពីភាពជាតំណាងដោយរាប់បញ្ចូលទាំង «បទឧក្រិដ្ឋត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ, ការចាត់ថ្នាក់និងលក្ខណៈនៃបទល្មើស, ទីតាំងដែលបទល្មើសត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត, ទំហំនៃបទល្មើស និងជនរងគ្រោះ នៃឧក្រិដ្ឋកម្ម ។

នៅក្នុងការគាំទ្រសេចក្ដីសម្រេចរបស់ខ្លួនក្នុងការជំនុំជម្រះជនជាប់ចោទលើការចោទប្រកាន់គោលនយោបាយឧក្រិដ្ឋមួយក្នុងចំណោមប្រាំ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា ៖

> *នៅក្នុងការជម្លៀសដោយបង្ខំប្រហែលជាចំណុចទូទៅតែមួយគត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលពាក់ព័ន្ធ ឬប៉ះពាល់ដោយប្រយោលដល់ប្រជាជនកម្ពុជាទាំងមូល ។ រាល់ទីតាំងឧក្រិដ្ឋកម្ម ឬបទចោទផ្សេងទៀត ដែលរួមមានបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរ និងជនរងគ្រោះជាច្រើន បានព័ណ៌នាពីបទល្មើសដែលបានកើតឡើងទាំងក្នុងទីកន្លែងតែមួយ ឬប្រឆាំងនឹងក្រុមសាសនាជាក់លាក់ ឬជាតិពន្ធុជាក់លាក់ណាមួយ» ។*
>
> *ទោះជាឧក្រិដ្ឋកម្ម និងក្រុមមនុស្សទាំងនេះ គឺជាផ្នែកមួយយ៉ាងសំខាន់នៃការបង្កឲ្យមានជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដោយក៏ពុំមានព្រឹត្តិការណ៍តែឯកឯងណាមួយអាចត្រូវបានព័ណ៌នាថា អាចជាតំណាងជាក់លាក់ទាក់ទងនឹងចំនួន និងលក្ខណៈរបស់ជនរងគ្រោះនោះដែរ នៅពេលប្រៀបធៀបនឹងជនរងគ្រោះសរុប ដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ ។*

ក៏ប៉ុន្តែ ប្រសិនបើយោងតាមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងចំណោមជនរងគ្រោះជិត៤.០០០នាក់ដែលកំពុងចូលរួមជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ គឺមានតែ៧៥០ នាក់ប៉ុណ្ណោះត្រូវបានទទួលស្គាល់ដោយយោងលើព្យសនកម្មទាក់ទងនឹងបទឧក្រិដ្ឋជម្លៀសប្រជាជនដោយបង្ខំ ។ លើសពីនេះទៀត បទឧក្រិដ្ឋប្រព្រឹត្តនៅក្នុងទីតាំងមួយកន្លែង ត្រូវបានផ្ដល់និយមន័យដោយពិចារណាទៅលើ «ភាពជាតំណាង» ប្រសិនបើប្រភេទបទឧក្រិដ្ឋដូចគ្នា ត្រូវបានកើតឡើងនៅក្នុងទីតាំងផ្សេងៗគ្នា ដូចជាឧក្រិដ្ឋកម្មជាច្រើននៅក្នុងកន្លែងធ្វើការងារជាច្រើនកន្លែង និងមន្ទីរសន្តិសុខរបស់ខ្មែរក្រហម ។ ជាការពិត ដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់ជាច្រើននាក់ពុំត្រូវបានអនុញ្ញាតឲ្យផ្សារភ្ជាប់ការរងគ្រោះរបស់ខ្លួនទៅនឹងទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងដីការដំណោះស្រាយនៃសំណុំរឿង០០២ ដែល«បម្រើឲ្យតែមួយឧទាហរណ៍ដើម្បីចង្អុលបង្ហាញរាល់របៀបដែលមន្ទីរ និងទីតាំងទាំងនោះដំណើរការនៅទូទាំងប្រទេសកម្ពុជា» ។

តាមទស្សនៈយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងសវនាការមួយដែលដោះស្រាយពីឧទាហរណ៍ជាតំណាងនៃឧក្រិដ្ឋកម្មគឺពុំអាចនឹងអនុវត្តបាននោះទេ ៖ «វាជាការច្បាស់តាំងពីដំបូងដែលថា ទោះជាឧទាហរណ៍តែមួយនៃប្រភេទឧក្រិដ្ឋកម្មតែមួយក្ដី» ក៏អាចទូលំទូលាយពេកក្នុងការកាត់ក្ដីមុនពេលមរណភាពរបស់ជនជាប់ចោទដែលជា «ចំណុចមួយដែលព្រះរាជអាជ្ញាទទួលស្គាល់យ៉ាងច្បាស់នៅពេលសហព្រះរាជអាជ្ញា ស្នើសុំបន្ថែមមន្ទីរសន្តិសុខតែមួយទៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១» ។ តាមពិតទៅវិធីសាស្ត្របែបនេះគឺជាវិធីអ្វីដែលសហព្រះរាជអាជ្ញាបានស្នើសុំបន្ទាប់ពីការចេញសេចក្ដី សម្រេចបឋមស្ដីពីការបំបែកសំណុំរឿងនោះ ។ សហព្រះរាជអាជ្ញាបានកម្រិតសំណើសុំរបស់ខ្លួនមកវិញ ក្រោយពីអង្គជំនុំជម្រះសាលាដំបូងបានប្រានចោល

មិនពិចារណាហើយបានលើកឡើងថា ពុំមានសិទ្ធិប្ដឹងជំទាស់ទេ ។ ដូចដែលកត់សម្គាល់របស់អង្គជំនុំជម្រះតុលាការកំពូល នៅពេលសវនាការមួយប្រព្រឹត្តទៅបានយ៉ាងល្អ វិសាលភាពនៃសវនាការនោះត្រូវបានសម្រេចរួចទៅហើយ ។ ចំពោះហេតុផលនោះ គឺសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពុំមែនវាយតម្លៃឡើងវិញថាតើសំណុំរឿង០០២ គួរតែធ្វើឲ្យបានត្រឹមត្រូវរបៀបណានោះទេ ប៉ុន្តែគឺជាសេចក្ដីសម្រេចមួយដែលថាតើការបន្ថែមមន្ទីរសន្តិសុខស-២១ គឺចាំបាច់ដើម្បីធ្វើឲ្យការជំនុំជម្រះមានភាពជាតំណាងសមហេតុផលដែរឬទេ ។

ការប្រានចោលអំណះអំណាងរបស់សហព្រះរាជអាជ្ញា និងមេធាវីនាំមុខដំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលថា «ការបន្ថែមមន្ទីរសន្តិសុខស-២១តែមួយនឹងអាចបំពេញតាមលក្ខណៈវិនិច្ឆ័យនៃភាពជាតំណាងសមហេតុផល» ដោយបូកបន្ថែមវិសាលភាពភូមិសាស្ត្រនិងការបន្ថែមបទឧក្រិដ្ឋនោះ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា ជនរងគ្រោះរាប់ពាន់នាក់នៅមន្ទីរស-២១ យ៉ាងណាក៏ដោយ គឺ «ចំនួនជនរងគ្រោះរាប់ពាន់នាក់ នៅតែជាចំណែកតូចមួយនៃជនរងគ្រោះទាំងអស់ក្នុងសំណុំរឿង០០២» ។ លើសពីនេះទៅទៀតទីតាំងនោះនៅខ្វះភាពទាក់ទងជាក់ស្ដែងទៅនឹងគោលនយោបាយជម្លៀសដោយបង្ខំ និងជា «ទីតាំងឧក្រិដ្ឋកម្មតែមួយដែលបានធ្វើការវិនិច្ឆ័យប្រកបដោយការសន្និដ្ឋានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារហូតមកដល់បច្ចុប្បន្ន» ។

យោងតាមអង្គជំនុំជម្រះសាលាដំបូង វិសាលភាពដែលមានស្រាប់នៃសវនាការកន្លងមក «ឆ្លុះបញ្ចាំងនូវលក្ខណៈវិនិច្ឆ័យនៃភាពជាតំណាងសមហេតុផល និងស្ថិតនៅក្នុងផលប្រយោជន៍យុត្តិធម៌ និងភាពត្រឹមត្រូវ ព្រមទាំងពន្លឿនសវនាការ» ។ បទឧក្រិដ្ឋដែលចោទប្រកាន់ ផ្ដល់លទ្ធភាពឲ្យមាន «ការពិនិត្យប្រធានបទចំនួន២ ក្នុងចំណោមប្រធានបទចំនួន៥ នៃដីកាដំណោះស្រាយនៃសំណុំរឿង០០២ ឧទាហរណ៍ ការជម្លៀសដោយបង្ខំ និងការកាប់សម្លាប់ខ្មាំងនៃរបបនោះ» និង «ដាក់រួមបញ្ចូលតំបន់ភូមិសាស្ត្រមួយផ្នែកធំនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងប្រជាជនកម្ពុជារងគ្រោះជាច្រើន» ។

នៅក្នុងការប្រានចោលអង្គហេតុទាក់ទងនឹងមន្ទីរស-២១ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ៖

១) អាយុច្រើន និងភាពទ្រុឌទ្រោមផ្នែករូវកាយរបស់ជនជាប់ចោទក្នុងសំណុំរឿង០០២ ដែលនៅសេសសល់

២) ផលប្រយោជន៍សាធារណៈនៅក្នុងការសម្រេចបានសាលក្រមមួយ ទាក់ទងយ៉ាងហោចណាស់ទៅនឹងមួយផ្នែកនៃដីកាដំណោះស្រាយនៃសំណុំរឿង ០០២

៣) លទ្ធភាពចាត់ចែង និងគ្រប់គ្រងបាននៃសំណុំរឿង ០០២/០១ នៅក្នុងដំណាក់កាលចុងក្រោយនេះ រួមទាំងការដែលអាចមានផលប៉ះពាល់ចំពោះជនជាប់ចោទ ប្រសិនបើមានការពង្រីកវិសាលភាពនៃការជំនុំជម្រះបន្ថែមទៀត

៤) ភាពមិនច្បាស់លាស់មួយទៅលើថិរវេលានៃកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង០០២/០១ ប្រសិនបើមានការដាក់បញ្ចូលមន្ទីរស-២១ ទៅក្នុងវិសាលភាពនៃការជំនុំជម្រះ និង

៥) ភាពមិនច្បាស់លាស់ទាក់ទងនឹងថិរវេលា នៃការគាំទ្រផ្នែកហិរញ្ញវត្ថុដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ដោយគោរពទៅលើកាតព្វកិច្ចបានកំណត់នៅក្នុងផែនការវិនិច្ឆ័យទោសចំពោះបទចោទ ដែលនៅសេសសល់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អង្គជំនុំជម្រះបានលើកឡើងថា ៖

> បច្ចុប្បន្ន ផែនការសម្រាប់ការជំនុំជម្រះនាពេលអនាគត ពឹងផ្អែកលើយថាភាពនានាដែលមិនអាចដឹងជាមុន ហើយដែលហួសពីសមត្ថភាពរបស់អង្គជំនុំជម្រះសាលាដំបូង ដូចជាការបន្តមានសម្បទាគ្រប់គ្រាន់របស់ជនជាប់ចោទក្នុងការចូលរួមសវនាការ និងការបន្តទទួលបានជំនួយពីប្រទេសផ្ដល់ជំនួយដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ហេតុនេះអង្គជំនុំជម្រះសាលាដំបូងនៅមិនច្បាស់ថា ការព្យាករណ៍ទៅលើការជំនុំជម្រះនាពេលអនាគតអាចរៀបចំ «ផែនការ» ប្រកបដោយអត្ថន័យបាន ដើម្បីប្រើជាការបង្ហាញផ្លូវសកម្មភាពការងារច្បាស់លាស់ដល់ភាគី ឬការសម្រេចចិត្តនានារបស់ភាគីទាក់ទងនឹងការបែង

បែកធនធាន ។

ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានភ្ជាប់នូវឧបសម្ព័ន្ធជាមួយសេចក្តីសម្រេចនេះ "ផែនការសាកល្បងសម្រាប់សវនាការនាពេលខាងមុខក្នុងសំណុំរឿង០០២" ការគិតទុកជាមុននូវសវនាការចំនួនពីរបន្ថែមទៀត ។ អង្គជំនុំជម្រះសាលាដំបូងនឹងរៀបចំឲ្យមានកិច្ចប្រជុំរៀបចំសវនាការមួយគ្រប់គ្រងសវនាការដើម្បីពិភាក្សាពីភាពស្មុគស្មាញផ្នែកច្បាប់ "ដោយសារតែការកែប្រែស្ថានភាពនានាដែលអាចកើតមាន ។ សវនាការទីពីរស្តីពីមន្ទីរសន្តិសុខ ទីតាំងសម្លាប់ និងបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បទល្មើសទាក់ទងនឹងការរើសអើងប្រជាជនចាម និងវៀតណាម ។ សវនាការទីបី ស្តីពីឧក្រិដ្ឋកម្មទាក់ទង នឹងសហករណ៍ ទីតាំងធ្វើការងារ ការផ្លាស់ប្តូរទីលំនៅប្រជាជនដោយបង្ខំលើកទីបី ការសំដៅយកអ្នក កាន់ព្រះពុទ្ធសាសនា និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ។

ដោយគោរពទៅលើលទ្ធផលពុំជាក់លាក់នៃការបំបែក ការទទួលស្គាល់ការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ ចំពោះការទទួលរងការខូចខាត ដែលមិនពាក់ព័ន្ធអង្គជំនុំជម្រះ សាលាដំបូងបានបញ្ជាក់ជាថ្មី៖

> ដីកាសម្រេចឲ្យបំបែកកិច្ចដំណើរការនីតិវិធីពុំមានការប៉ះពាល់ចំពោះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះការជំនុំជម្រះនោះឡើយ ។ អង្គជំនុំជម្រះបន្តទៀតថាអង្គជំនុំជម្រះសាលាដំបូងពុំបានស្នើសុំឲ្យផ្តើមឡើងវិញលើសេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាន ដែលធ្វើឡើងក្នុងដំណាក់កាលបុរេជំនុំជម្រះឡើយនិងថាសមាជិកដើមបណ្តឹងរដ្ឋប្បវេណីដែលបានរួមបញ្ចូលគ្នាជាក្រុមតែមួយក៏នៅតែគ្មានការប្រែប្រួលដដែលបន្ទាប់ពីការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសាជាថ្មីនៃសំណុំរឿង០០២នេះ ។

អង្គជំនុំជម្រះលើកឡើងម្តងទៀតថា ខ្លួនពុំបានកំហិតនូវលទ្ធភាពនៃដើមបណ្តឹងរដ្ឋប្បវេណីជាលក្ខណៈបុគ្គល ដើម្បីទទួលបានផលប្រយោជន៍ពីការផ្តល់សំណង ដែលអង្គជំនុំជម្រះសាលាដំបូងបានប្រគល់ និងអនុម័តនៅទីបំផុតនោះទេ ទោះជាយ៉ាងណាទម្រង់នៃការទាមទារសំណង ដែលធ្វើឡើងតាមរយៈមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែគោរពនូវលក្ខខណ្ឌតម្រូវនៃវិធានផ្ទៃក្នុង ដែលអនុញ្ញាតឲ្យមានវិធានការសំណង ដែលផ្តល់មូលនិធិពីប្រភពខាងក្រៅជាជាងពីជនជាប់ចោទ ។ សម្រាប់ពេលដំបូង ភាគច្រើនអង្គជំនុំជម្រះសាលាដំបូងៈ

អង្គជំនុំជម្រះទទួលស្គាល់ថា កាលៈទេសៈនានាដែលហួសពីការគ្រប់គ្រងរបស់អង្គជំនុំជម្រះ រួមមានធនធានហិរញ្ញវត្ថុមានកម្រិតដើម្បីផ្តល់សំណង និងលទ្ធភាពដែលថាការជំនុំជម្រះនាពេលអនាគតអាច ត្រូវបានរារាំងដោយសារមរណភាព ឬការពុំទាន់មានសម្បទាគ្រប់គ្រាន់របស់ជនជាប់ចោទដែលនៅមានជីវិតក្នុងសំណុំរឿង០០២ អាចដកហូតសិទ្ធិពីដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនដ៏គួរឲ្យសោកស្តាយក្នុងការទទួលបានសំណងចំពោះព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង ។

នៅពុំទាន់ច្បាស់នៅឡើយទេថា សហព្រះរាជអាជ្ញានឹងប្តឹងជំទាស់ម្តងទៀតចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៅពេលនេះ ។

**អាន ហាញឧល**


## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthsocheat@dccam.org*

*Home page: www.dccam.org*

# សេចក្តីសម្រេចស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវីក្នុងសំណុំរឿង០០៤

សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបាននឹងកំពុងបំពេញភារកិច្ចរបស់ខ្លួនដោយពុំមានការចូលរួមពីសំណាក់ភាគីជាតិ បានអះអាងអំពីសិទ្ធិក្នុងការមានមេធាវីរបស់ជនជាប់ចោទក្នុងសំណុំរឿង០០៤ និងបានផ្តល់នូវដំណោះស្រាយមួយចំពោះភាពចម្រូងចម្រាសដែលមានរយៈពេលជាងមួយឆ្នាំ ជុំវិញការជ្រើសរើសមេធាវីអន្តរជាតិតំណាងឲ្យជនជាប់ចោទ ។

ការស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣ និង០០៤ បានត្រូវបានមើលឃើញយ៉ាងច្បាស់ថា មានការខ្វែងគំនិតគ្នាផ្នែកនីតិវិធី ជាងសំណុំរឿង០០១ និង០០២ទៅទៀត ។ នៅខែកក្កដា ឆ្នាំ២០០៧ ជនសង្ស័យនៅក្នុងសំណុំរឿង០០១ និង០០២ ត្រូវបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញា ។ ក្នុងអំឡុងពីរទៅបីខែបន្ទាប់ពីទទួលបានដីកាស្នើឲ្យមានការស៊ើបអង្កេតរបស់សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតបានសម្រេចចាប់ និងឃុំខ្លួនជនជាប់សង្ស័យទាំងប្រាំ ហើយធ្វើការស៊ើបអង្កេតរយៈពេលពីរឆ្នាំបន្ថែមទៀត តាមរយៈក្រុមមេធាវីការពារក្តីដែលផ្តល់ជូនដោយតុលាការ ។

នៅក្នុងឆ្នាំ២០០៨ អតីតសហព្រះរាជអាជ្ញាអន្តរជាតិ រ៉ូប៊ឺត ប៉ុទីត បានសម្រេចបើកការស៊ើបអង្កេតថ្មីចំនួនពីរនៅក្នុងសំណុំរឿង០០៣ និង០០៤ ទោះបីជាមានការជំទាស់ពីសំណាក់សមភាគីជាតិរបស់ខ្លួន គឺលោកស្រី ជា លាង យ៉ាងណាក្តី ។ ដោយសារពុំមានការព្រមព្រៀងក្នុងការបន្តសំណុំរឿង ដើម្បីបើកការស៊ើបអង្កេត លោក ប៉ុទីត បានដាក់ញត្តិមួយស្តីពីកំណត់ហេតុនៃការខ្វែងយោបល់គ្នា ស្នើឲ្យអង្គបុរេជំនុំជម្រះដោះស្រាយជម្លោះនេះ ។ ប្រហែលមួយឆ្នាំក្រោយមក សំណុំរឿងនេះត្រូវបាន ផ្ញើជូនសហចៅក្រមស៊ើបអង្កេត ដោយពុំមានសេចក្តីសម្រេចណាមួយត្រូវបានធ្វើឡើង បន្ទាប់ពីចៅក្រមជាតិ និងអន្តរជាតិនៃអង្គបុរេជំនុំជម្រះពុំអាចស្វែងរកសំឡេងជាឯកឆន្ទដើម្បីចេញសេចក្តីសម្រេច ។

ចាប់តាំងពីខែកញ្ញា ឆ្នាំ២០០៩ តាមរយៈសហចៅក្រមស៊ើបអង្កេតអន្តរជាតិបួនរូបដែលបានកាន់ដំណែងនេះ សំណុំរឿង ០០៣ និង០០៤ បានត្រូវទុកចោលនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយពុំមានជនសង្ស័យណាម្នាក់ត្រូវបានកំណត់ឈ្មោះជាផ្លូវការ ឬក៏ត្រូវបានចាប់ខ្លួននៅឡើយទេ ។ ដោយសារតែសហព្រះរាជអាជ្ញាជាតិ សហចៅក្រមស៊ើបអង្កេតជាតិ និងចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះទាំងអស់បានចេញសេចក្តីសម្រេចស្របគ្នា និងក្នុងករណីខ្លះធ្វើការរារាំង ប្រឆាំងនឹងកិច្ចប្រឹងប្រែងរបស់សហភាគាអន្តរជាតិរបស់ខ្លួន ដែលចង់ឲ្យកិច្ចដំណើរការនីតិវិធីបន្តទៅមុខអនុលោមតាមបទដ្ឋាននៃនីតិវិធី ។ មានការដឹងឮយ៉ាងទូលំទូលាយជាយូរមកហើយថា ការប្រឆាំងរបស់ចៅក្រម និងសហព្រះរាជអាជ្ញាជាតិទាំងអស់ គឺបណ្តាលមកពីការទទួលរងឥទ្ធិពលនយោបាយពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាដែលបានប្រឆាំងយ៉ាងខ្លាំងក្លាចំពោះការចោទប្រកាន់ជនសង្ស័យថ្មីបន្ថែមទៀត ។

នៅអំឡុងពេលនៃនិទាឃរដូវ ឆ្នាំ២០១១ នៅពេលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិទី២ ទំនងជាបានរួមគំនិតជាមួយសមភាគីជាតិរបស់ខ្លួន សម្រេចបិទសំណុំរឿង០០៣ និង០០៤ ដោយពុំមានការស៊ើបអង្កេត ។ បន្ទាប់មកក៏មានការបង្ហាញឈ្មោះរបស់ជនជាប់សង្ស័យទាំងប្រាំរូបជាសាធារណៈពីសំណាក់សកម្មជននៃសង្គមស៊ីវិលមួយរូប ហើយសំណើបឋមរបស់សហព្រះរាជអាជ្ញាអន្តរជាតិដើម្បីធ្វើការចោទប្រកាន់ត្រូវបានលេចធ្លាយព័ត៌មានដោយជនពុំស្គាល់មុខ ។ ក្រោយមក ជនជាប់សង្ស័យទាំងនោះត្រូវបណ្តាញសារព័ត៌មានជាច្រើន ទាំងក្នុងស្រុក និងអន្តរជាតិស្វែងរកដើម្បីស្នើសុំឲ្យផ្តល់បទសម្ភាសន៍ ។

អង្គភាពគាំពារក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប៉ុនប៉ងជាច្រើនលើកច្រើនសារ ក្នុងការផ្តល់ឲ្យជនសង្ស័យដែលពុំទាន់ត្រូវបានកំណត់ឈ្មោះ និងចោទប្រកាន់ជាផ្លូវការនូវសិទ្ធិក្នុងការមានមេធាវីការពារក្តី ដោយអះអាងថា ការបន្តកិច្ចដំណើរការនីតិវិធីដោយពុំមានការចូលរួមរបស់មេធាវីការពារក្តី នឹងរំលោភបំពានលើផ្នែកជាច្រើននៃសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ រួមទាំងសិទ្ធិទទួលបានសមភាពនៃមធ្យោបាយតតាំងក្តី សិទ្ធិទទួលបានការតំណាងប្រកបដោយប្រសិទ្ធភាព និងសិទ្ធិទទួលបានការគោរពគោលការណ៍ចំពោះមុខ ។ ការច្រានចោលរបស់សហចៅក្រមស៊ើបអង្កេត ចំពោះសំណើនេះ ត្រូវបានបញ្ជាក់ដោយអង្គបុរេជំនុំជម្រះ ដែលបានយល់ស្របថា សិទ្ធិមានការតំណាងមាននៅពេលដែលជនណាម្នាក់ត្រូវបាននាំខ្លួនមកចំពោះមុខចៅក្រម ឬ“ត្រូវបានចោទប្រកាន់” តែប៉ុណ្ណោះ ។ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលត្រូវបានផ្តាច់ផ្សេងពីគ្នាតាមការសន្មត់របស់ច្បាប់បានសម្រេចថា ទោះបីជាមានការចោទប្រកាន់ប្រឆាំងនឹងជនសង្ស័យត្រូវបានធ្វើឡើងជាសាធារណៈ និងមានការផ្សព្វផ្សាយតាមរយៈបណ្តាញសារព័ត៌មានក៏ដោយ ជនសង្ស័យនៅតែពុំទទួលរងផលប៉ះពាល់ណាមួយនៅឡើយទេ នៅខណៈដែលពុំទាន់មានការជូនដំណឹងណាមួយថា សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតបានបើកការស៊ើបអង្កេត ។ ហេតុដូច្នេះ ជនសង្ស័យដែលពុំទាន់ត្រូវបានបង្ហាញឈ្មោះ ជាផ្លូវការនៅតែមិនដឹងអំពីដំណើរការក្តីព្រហ្មទណ្ឌប្រឆាំងនឹងខ្លួនឡើយ ។

នៅពេលចៅក្រមបម្រុង កាស្តើ អានសែមិត ក្លាយជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិទីបី លោកបានសម្រេចជូនដំណឹងជនសង្ស័យទាំងអស់នៅក្នុងសំណុំរឿង០០៣ និង០០៤ ថាពួកគេកំពុងត្រូវបានស៊ើបអង្កេត និងមានសិទ្ធិក្នុងការមានមេធាវី ។ អ្វីដែលត្រូវបានដឹងជាសាធារណៈ គឺមានតែជនសង្ស័យមួយរូបនៅក្នុងសំណុំរឿង០០៣ និងជនសង្ស័យមួយរូបនៅក្នុងសំណុំរឿង០០៤ បានអនុវត្តសិទ្ធិនេះ ។ នៅក្នុងសំណុំរឿង០០៤ ជនសង្ស័យបានជ្រើសរើសអតីតប្រធានអង្គភាពគាំពារក្តី លោក រីឆាត រ៉ូជឺ ធ្វើជាមេធាវីការពារក្តីអន្តរជាតិរបស់ខ្លួន និងលោក មុំ លុជ្យូ ធ្វើជាមេធាវីជាតិ ។ ទោះបីជាយ៉ាងណាក្តី ប្រធានអង្គភាពគាំពារក្តីបច្ចុប្បន្ន គឺលោក អ៊ីសាក់ អែនឌែលី បានសម្រេចថា លោក រ៉ូជឺ ពុំមានគុណវុឌ្ឍិគ្រប់គ្រាន់សម្រាប់កាន់តំណែងជាមេធាវីការពារក្តីទេ ។ ការសម្រេចនេះដោយផ្អែកលើមូលដ្ឋាននៃៈ

១) លទ្ធភាពទំនាស់ផលប្រយោជន៍បណ្តាលមកពីតួនាទីពីមុនរបស់ លោក រ៉ូជឺ ជាប្រធានអង្គភាពគាំពារក្តី ។

២) ការយល់ឃើញអំពីភាពមិនប្រក្រតីខាងនីតិវិធីនៅក្នុងដំណើរការចាត់តាំង និង

៣) អង្គហេតុដែលថា លោក រ៉ូជឺ មិនទាន់ត្រូវបានចូលជាសមាជិកនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដូច្នេះហើយទើបគាត់មិនមានសិទ្ធិ ឬគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីតំណាងឲ្យជនក្រិក្រនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ ។

ហេតុផលនៅខាងក្រោយជម្លោះផលប្រយោជន៍នេះពុំមានការបញ្ជាក់ច្បាស់លាស់ទេ ប៉ុន្តែការព្រួយបារម្ភអំពីក្រមសីលធម៌ គឺត្រូវបានបញ្ជាក់នៅពេលបន្ទាប់ ដុំវិញកាលៈទេសៈមានជាប់ពាក់ព័ន្ធនឹងលោក រ៉ូជឺ ក្នុងការជ្រើសរើសអ្នកបន្តវេនធ្វើជាប្រធានអង្គភាពគាំពារក្តី ដែលបានដាក់ឈ្មោះរបស់គាត់ចូលទៅក្នុងបញ្ជីឈ្មោះមេធាវីដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ ។ ទាក់ទងនឹងការពុំទាន់ក្លាយជាសមាជិកភាពនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជារបស់លោក រ៉ូជឺ ទោះបីជាមានតម្រូវយ៉ាងដាក់លាក់ជាមុន ក៏ដោយ ការអនុវត្តជាក់ស្តែងទាំងនៅក្នុងសំណុំរឿង០០១ និងសំណុំរឿង០០២ តម្រូវឲ្យមេធាវី ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវចូលជាសមាជិកគណៈមេធាវី នៅក្រោយពេលការតែងតាំងរបស់ពួកគេ ដើម្បីជៀសវាងការចំណាយផ្សេងៗដែលមានតម្លៃខ្ពស់ ហើយពុំចាំបាច់ ។

ចៅក្រម កាស្តើ អានសែមិត បានទទួលស្គាល់នូវការតែងតាំង ទាំងលោក មុំ លុជ្យូ និងលោក រីឆាត រ៉ូជឺ មុនពេលលោកលាលែងចេញពីតំណែងទាំងពុំទាន់សម្រេចកិច្ចការ បណ្តាលមកពីការបដិសេធរបស់ភាគីជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងការទទួលស្គាល់ពីភាពស្របច្បាប់នៃការតែងតាំង និងសមត្ថកិច្ចក្នុងការបំពេញមុខងាររបស់លោក ។ ភ្លាមៗក្រោយពីការចាកចេញរបស់លោក ចៅក្រម កាស្តើ អានសែមិត អនុប្រធាននៃអង្គភាពរដ្ឋបាលបានស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតជាតិ

គឺលោក យូ ប៊ុនឡេង ធ្វើការបញ្ជាក់អំពីដីកាទទួលស្គាល់សិទ្ធិមានមេធាវីរបស់ជនសង្ស័យ ។ ចៅក្រម យូ ប៊ុនឡេង បានបដិសេធពុំទទួលស្គាល់ពីអនុភាពគតិយុត្តនៃដីកានោះទេ ។

ដោយសារមានការជំទាស់ពីសំណាក់អង្គភាពគាំពារក្តីចំពោះលោក វ៉ូជី ជនសង្ស័យដែលពុំទាន់ត្រូវបានបង្ហាញឈ្មោះ បានជ្រើសរើសយកលោក ហ្គោរ៉េន ស្ពូតធី ជាមេធាវីអន្តរជាតិមួយរូបទៀតរបស់ខ្លួន ។ នៅក្នុងខែតុលា ឆ្នាំ២០១២ លោក ស្ពូតធី ត្រូវបានតែងតាំងជាមេធាវីការពារក្តីឲ្យជនសង្ស័យ ។ បច្ចុប្បន្ននេះ លោក ស្ពូតធី និងលោក វ៉ូជី កំពុងស្វះស្វែងរកការទទួលស្គាល់ខ្លួនជាសហមេធាវីអន្តរជាតិ ដើម្បីទទួលបានការអនុញ្ញាតឲ្យចូលមើលឯកសារក្នុងសំណុំរឿង០០៤ ។

ចៅក្រមស៊ើបអង្កេតអន្តរជាតិទី៤ គឺលោក ម៉ាក ហារមិន បានចេញសេចក្តីសម្រេចជា ឯកតោភាគីមួយនៅពេលថ្មីៗនេះ ដោយដោះស្រាយចំពោះចំណុចដែលកំពុងស្ថិតនៅក្រោមការស៊ើបអង្កេត ប្រសិនបើសិទ្ធិរបស់ជនសង្ស័យដូចដែលបានកំណត់នៅក្នុងវិធាន២១(ឃ) នៃវិធានផ្ទៃក្នុង សំដៅ លើជនជាក់លាក់ណាមួយ ។ វិធាន២១(ឃ) បានចែងថា ៖

> *ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និងមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនិងនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី ត្រូវផ្តល់ព័ត៌មានដល់គេអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប ។*

ចៅក្រម ហារមិន បានធ្វើការកត់សម្គាល់ថា មាត្រា២៤ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចែងថា ៖

> *ក្នុងដំណាក់កាលស៊ើបអង្កេត ជនសង្ស័យមានសិទ្ធិទទួលបានការការពារពីមេធាវី ដែលជ្រើសរើសដោយខ្លួនឯង ដោយខានមិនបាន និងមានជំនួយផ្នែកច្បាប់ដល់ពួកគេដោយឥតគិតថ្លៃ ប្រសិនបើខ្លួនគ្មានលទ្ធភាពគ្រប់គ្រាន់ដើម្បីពឹងមេធាវី ព្រមទាំងមានសិទ្ធិទទួលបាននូវការបកប្រែចាំបាច់ជាភាសាដែលជនសង្ស័យនិយាយ និងយល់បាន ។*

សន្ទានុក្រមនៃវិធានផ្ទៃក្នុង បញ្ជាក់ថា "ជនសង្ស័យ" គឺជា "បុគ្គលដែលសហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត ចាត់ទុកថាអាចធ្លាប់បានប្រព្រឹត្តបទឧក្រិដ្ឋដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ប៉ុន្តែមិនទាន់ត្រូវបានចោទប្រកាន់នៅឡើយ" ។ ចំណែកឯ "ជនត្រូវចោទ" សំដៅលើ "បុគ្គលណាម្នាក់ដែលត្រូវបានចោទប្រកាន់ចំពោះរឿងក្តីណាមួយ ក្នុងចន្លោះពេលពីមានដីកាសន្និដ្ឋាន បញ្ជូនរឿងឲ្យស៊ើបសួរ រហូតដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់" ។

ទោះបីជាមានការរៀបរាប់លម្អិតនៅក្នុងមាត្រា២៤ថ្មី ដែលចែងអំពីការផ្តល់ឲ្យសិទ្ធិក្នុងការមានមេធាវីជូនបុគ្គលដែលសហព្រះរាជអាជ្ញាកំណត់ថាជាជនសង្ស័យក៏ដោយ ចៅក្រម ហារមិន បានសម្រេចថា ច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ច្បាប់កម្ពុជា និងការអនុវត្តបទដ្ឋានអន្តរជាតិ ដែលប្រើប្រាស់នៅក្នុងសេចក្តីសម្រេចមុនៗរបស់សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះបាន ចាត់ទុកថាមានតែ "ជនត្រូវចោទ" ប៉ុណ្ណោះ ដែលជាភាគីនៃកិច្ចដំណើរការនីតិវិធី ហើយត្រូវផ្តល់ឲ្យនូវសិទ្ធិមានមេធាវីការពារ ។ ហេតុដូច្នេះហើយ ទើបបានជាលោកសម្រេចថា ដោយសារតែចៅក្រម កាស្តើ អានសែមិត បានជូនដំណឹងអំពីឋានៈ និងសិទ្ធិក្នុងការមានមេធាវីដល់ជនសង្ស័យរួចហើយ ឥឡូវជនសង្ស័យមានសិទ្ធិក្នុងការមានមេធាវីតាមការជ្រើសរើសរបស់ខ្លួន តាមវិធាន២១.១(ឃ) នៃវិធានផ្ទៃក្នុងបានហើយ ។

ទាក់ទងនឹងការជ្រើសរើសមេធាវីការពារក្តីរបស់ជនសង្ស័យ លោកចៅក្រម ហារមិន បានសម្រេចថា អនុលោមតាមវិធានរបស់តុលាការ លោកពុំមានសមត្ថកិច្ចណាមួយ ក្នុងការពិនិត្យមើលលើកិច្ចការរបស់ប្រធានអង្គភាពគាំពារក្តី និងអនុប្រធានការិយាល័យរដ្ឋបាល ឬបញ្ជាឲ្យការិយាល័យរដ្ឋបាលចេញនូវកិច្ចសន្យាការងារជូនលោក វ៉ូជី ទេ ។ ប៉ុន្តែ លោកមានសមត្ថកិច្ចក្នុងពិនិត្យមើលឡើងវិញចំពោះសេចក្តីសម្រេចមុនៗរបស់លោកចៅក្រម កាស្តើ អានសើម៉េ ដែលបានទទួលស្គាល់ ការតែងតាំងលោក វ៉ូជី ធ្វើជាមេធាវីការពារក្តីឲ្យជនសង្ស័យ ។ ទោះបីជា ចៅក្រម កាស្តើ អានសែមិត លើកឡើងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនថា លោក

រ៉ូជឺ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីទទួលបានការតែងតាំងក៏ដោយ ប៉ុន្តែលោកចៅក្រម ហារមិន បានរកឃើញផ្សេងពីនេះថាៈ

នៅពេលដែលដីកាសម្រេចទទួលស្គាល់ត្រូវបានចេញនៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១២ លោកចៅក្រម កាស្តេ អានសៃមិត ពុំបានដឹងថា លោក រ៉ូជឺ អាចមិនមានបទពិសោធន៍ផ្នែកច្បាប់ជាប់ពាក់ព័ន្ធគ្រប់គ្រាន់ដើម្បីតំណាងជនក្រីក្រនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយអាចមានទំនាស់ផលប្រយោជន៍ទាក់ទងនឹងការតំណាង ជនសង្ស័យ ។ បន្ថែមពីលើនេះទៀត លោក រ៉ូជឺ មិនទាន់បានស្បថចូលកាន់តំណែងនៅពេលដែលចេញដីកាសម្រេចទទួលស្គាល់ ។ ការប្រែប្រួលទាំងនេះធ្វើឲ្យដីកាសម្រេចទទួលស្គាល់អស់សុពលភាព ។

ទោះបីជាយ៉ាងណាក្តី វាទំនងគ្រាន់តែជាការយល់ឃើញផ្ទាល់ខ្លួនរបស់លោកចៅក្រម ហារមិន តែប៉ុណ្ណោះ ដែលថា លោក អែនឌែលី បានបង្ហាញអំពីការព្រួយបារម្ភរបស់គាត់ ហើយបានដកចេញការតែងតាំងលោក រ៉ូជឺ នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ ២០១២ មុនពេលដែល ចៅក្រម អានសៃមិត ចេញដីកាសម្រេចទទួលស្គាល់លោក រ៉ូជឺ នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១២ ។ បន្ថែមពីលើនេះ ដូចជាការរំពឹងទុក សេចក្តីសម្រេចទទួលស្គាល់ថ្ងៃទី៣ ខែឧសភា នេះ អាចនឹងប្រឈមនឹងការជំទាស់ ចំពោះការតែងតាំងមេធាវី ហើយលោកចៅក្រម កាស្តេ អានសៃមិត ទំនងជាបានដឹងអំពីការព្រួយបារម្ភរបស់លោក អានឌែលី រួចទៅហើយ ។

ជាផលវិបាកនៃសេចក្តីសម្រេចរបស់លោកចៅក្រម ហារមិន គឺដោយសារតែជនសង្ស័យត្រូវបានជូនដំណឹងដោយលោកចៅក្រម កាស្តេ អានសៃមិត រួចទៅហើយថា រូបជនសង្ស័យកំពុងត្រូវបានស៊ើបអង្កេត ដូច្នេះជនសង្ស័យរូបនោះមានសិទ្ធិទទួលមេធាវីការពារក្តីដែលតុលាការផ្តល់ជូន គឺលោក មុំ លុជ្ស និងលោក ហ្គោរ៉េន ស្ទូតជី ដែលត្រូវបានទទួលស្គាល់ជាមេធាវីការពារឲ្យជនសង្ស័យ ។ ចំណែកឯលោក រ៉ូជឺ ត្រូវបានផ្តល់ជូននូវឱកាសដើម្បីបង្ហាញអំពីភ័ស្តុតាងទៅដល់អង្គភាពគាំពារក្តីអំពីគុណវុឌ្ឍិរបស់គាត់ក្នុងការបម្រើការងារជាសហមេធាវីការពារក្តីអន្តរជាតិ ។ ទោះបីជា ចៅក្រម ហារមិន ពុំបានលើកឡើងលម្អិតអំពីក្រុមមេធាវីការពារក្តីដែលទើបនឹងត្រូវបានចាត់តាំងនៅពេលនេះ អាចត្រូវបានអនុញ្ញាតឲ្យចូលមើលឯកសារក្នុងសំណុំរឿង០០៤ ក៏ដោយ សេចក្តីសម្រេចរបស់លោកចៅក្រមនឹងជាការបើកផ្លូវសម្រាប់មេធាវីការពារក្តីចូលមើលឯកសារក្នុងសំណុំរឿង ។

**អាន ហាញឌុល**

# ដំណឹងស្វែងរកបងប្រុស



នាងខ្ញុំឈ្មោះ ប៊ុនឡា ម៉ៃ សព្វថ្ងៃរស់នៅសហរដ្ឋអាមេរិក ។ សូមប្រកាសស្វែងរកបងប្រុសឈ្មោះ ប៊ុនឡា ទោត ដែលបានបែកគ្នានៅចុងឆ្នាំ១៩៧៥ កាលពីអាយុ១៦ឆ្នាំ ក្នុងភូមិអៀន ស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ ក្បែរព្រំប្រទល់ខេត្តបន្ទាយមានជ័យ ។

ឪពុកឈ្មោះ ប៊ុនឡា ប៊ុតស៊ី (ស្លាប់) និងម្តាយឈ្មោះ ប៊ុនឡា តឿ (ស្លាប់) ។ គាត់ទាំងពីរនាក់មានកូនទីមួយឈ្មោះ ប៊ុនឡា ទោត (បាត់ខ្លួន), កូនទីពីឈ្មោះ ប៊ុនឡា អាត (នៅរស់), កូនទីបីឈ្មោះ ប៊ុនឡា លេត (នៅរស់), កូនទីបួនឈ្មោះ ប៊ុនឡា ឡៃ (នៅរស់), កូនទីប្រាំ ឈ្មោះ ប៊ុនឡា ម៉ៃ (នៅរស់) ។

បើបងប្អូនណាបានស្គាល់ឈ្មោះ ប៊ុនឡា ទោត សូមទំនាក់ទំនងមកនាងខ្ញុំ ប៊ុនឡា ម៉ៃ ឬ មជ្ឈមណ្ឌលឯកសារកម្ពុជា អាសយដ្ឋានៈ ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ភ្នំពេញ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១៦ ៨៧៦ ៦៩២ ។ ***សូមអរគុណ!***

# ច្បាប់ស្តីពីការបដិសេធមិនទទួលស្គាល់ថាមាន អំពើប្រល័យពូជសាសន៍

◆ ទន្ទឹមពេលដែលច្បាប់អន្តរជាតិទទួលស្គាល់ថា មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិយោបល់ ។ ច្បាប់នេះបានទទួលស្គាល់ស្របគ្នាដែរថា សេរីភាពនេះមានដែនកំណត់ ។

◆ រដ្ឋមានកាតព្វកិច្ចហាមឃាត់ការគាំទ្រណាមួយនៃការស្អប់ជាតិសាសន៍ ពូជសាសន៍ និងសាសនា ដែលញុះញង់ឲ្យមានការរើសអើង ការប្រឆាំង ឬអំពើហិង្សា ។

◆ ក្រៅពីនេះ រដ្ឋមានសេរីភាពក្នុងការដាក់កំហិតលើសេរីភាពបញ្ចេញយោបល់ ប្រសិនបើការដាក់កំហិតនេះឆ្លើយតបទៅនឹងលក្ខណ្ឌដែលបានចែងក្នុងមាត្រា១៩នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។

◆ ជាទូទៅ ដោយអនុលោមតាមយុត្តិសាស្ត្រនៃធម្មនុញ្ញអឺរ៉ុប សេរីភាពក្នុងការបញ្ចេញមតិ ត្រូវមានសមតុល្យទៅនឹងការការពារសេចក្តីថ្លៃថ្នូរ និងកត្តិយសរបស់មនុស្ស ។ ដោយអនុលោមតាមវិធីសាស្ត្របែបនេះ រដ្ឋមួយចំនួនហាមឃាត់ការនិយាយស្តីដែលបដិសេធមិនទទួលស្គាល់អំពើប្រល័យពូជសាសន៍ ការកែប្រែអំពើប្រល័យពូជសាសន៍ ឬការមិនផ្តល់សារសំខាន់ដល់អំពើប្រល័យពូជសាសន៍ ។ ការដាក់កំហិតលើការនិយាយស្តីដែលបដិសេធមិនទទួលស្គាល់ អំពើប្រល័យពូជសាសន៍ផ្ទុយទៅនឹងវិធីសាស្ត្រសហរដ្ឋអាមេរិក ដែលចាត់ទុកការបដិសេធមិនទទួលស្គាល់អំពើប្រល័យពូជសាសន៍ថាជាបែបបទមួយនៃសេរីភាពបញ្ចេញមតិ ដរាបណាការបញ្ចេញមតិនោះមិនញុះញង់អោយមានអំពើហិង្សា ។

◆ បទពិសោធន៍ទាក់ទងទៅនឹងច្បាប់ស្តីពីការបដិសេធមិនទទួលស្គាល់អំពើប្រល័យពូជសាសន៍របស់ប្រទេសរ្វ៉ាន់ដាគឺជាការចន្លុលបង្ហាញដល់ស្ថានភាពក្នុងប្រទេសកម្ពុជា ។ ប្រទេសរ៉ាហ្វាន់ដា ត្រូវវេងការរិះគន់ពីបទប្រើប្រាស់ច្បាប់ស្តីពីការបដិសេធមិនទទួលស្គាល់អំពើប្រល័យពូជសាសន៍ក្នុងគោលបំណងនយោបាយ ។

◆ ប្រសិនបើប្រទេសកម្ពុជា អនុម័តច្បាប់ស្តីពីការបដិសេធមិនទទួលស្គាល់អំពើប្រល័យពូជសាសន៍ រាជរដ្ឋាភិបាលកម្ពុជាប្រហែលជាថានឹងបង្កើតនូវកង្វល់ស្រដៀងគ្នាទៅនឹងកង្វល់ដែលប្រទេសរ្វ៉ាន់ដាបានជួបប្រទះ ។ ការព្យាករណ៍អំពីការត្រួតពិនិត្យមើលល្អិតល្អន់ និងការរិះគន់ លើច្បាប់នេះ ត្រូវបានផ្សព្វផ្សាយតាមរយៈបណ្តាញសារព័ត៌មានក្នុងប្រទេសកម្ពុជា ។

◆ ដោយសំអាងលើហេតុផលខាងលើប្រទេសកម្ពុជានឹងទទួលបានផលប្រយោជន៍ក្នុងការបង្វែរចំណាប់អារម្មណ៍សាជាថ្មីទៅរកមធ្យោបាយជំនួសផ្សេង ដូចជាការអប់រំអំពីអំពើប្រល័យពូជសាសន៍ ក្នុងការដោះស្រាយជាមួយនឹងអ្នកដែលបដិសេធមិនទទួលស្គាល់អំពើប្រល័យពូជសាសន៍ កែប្រែអំពើប្រល័យពូជសាសន៍ ឬការមិនផ្តល់សារសំខាន់ដល់អំពើប្រល័យពូជសាសន៍ ។

**គ្រីស ឌេវីឌ**

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ វិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែងគឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះជាយ៉ាងនេះក្តី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទងដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិនិងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ស៊ីវ សាវីណា តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល : truthsavina.s@dccam.org

**◆ ទីកន្លែង : អាគារ "ក" ជាន់លើ ◆ ពេលវេលា : ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវត្តរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបុរសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺជាឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្ងាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហមនិងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមានៈ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ធនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ុំ សារីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។





















# ការពិតអាចយកឈ្នះលើការមិនទទួលស្គាល់ដោយគ្មានការរឹតបន្តឹងសេរីភាពនៃការបញ្ចេញមតិ

*ខ្លឹមសារនៅក្នុងអត្ថបទនេះគឺជាមតិរបស់អ្នកនិពន្ធ ហើយមិនបានបង្ហាញពីជំហររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទេ*

រដ្ឋាភិបាលកម្ពុជាកំពុងតែស្វះស្វែងប្រយុទ្ធប្រឆាំងនឹងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យតាមរយៈច្បាប់មួយដែលនឹងផ្តន្ទាទោសដោយការដាក់ពិន័យ ឬដាក់ពន្ធនាគារចំពោះការសម្តែងមតិជាសាធារណៈអំពីការមិទទួលស្គាល់បែបនេះ ។ ជាជាងបន្ថយសិទ្ធិសេរីភាពបញ្ចេញមតិតាមរយៈការផ្តន្ទាទោសព្រហ្មទណ្ឌ រដ្ឋាភិបាលកម្ពុជាគួរស្វះស្វែងបញ្ចប់ការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យតាមវិធីដែលមានលក្ខណៈស្រាលជាងនេះ ។ តាមរយៈការអប់រំ ការពិភាក្សា និងការស្តីបន្ទោសរដ្ឋាភិបាលកម្ពុជាអាចកាត់បន្ថយការរិះគន់របស់បរទេសមកលើភាពស្មោះត្រង់របស់រដ្ឋាភិបាលក្នុងការគោរពសិទ្ធិមនុស្សព្រមទាំងអាចកសាងកេរ្តិ៍ឈ្មោះល្អថាជាអ្នកគាំទ្រដល់ដំណើរស្វែងរកការពិតក្នុងចំណោមប្រជាជនកម្ពុជាទាំងមូល ។

ច្បាប់អន្តរជាតិទទួលស្គាល់ថាបុគ្គលគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការសម្តែងមតិយោបល់ ប៉ុន្តែច្បាប់នេះក៏ទទួលស្គាល់ដែរថា ការរឹតត្បិតមួយចំនួនលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិអាចជាការចាំបាច់ ។ រដ្ឋត្រូវតែហាមប្រាមចំពោះសេចក្តីថ្លែងការណ៍ដែលមានលក្ខណៈជំរុញឲ្យមានការស្អប់ខ្ពើមដែលអាចឈានដល់ការស្អប់ខ្ពើមជាតិសាសន៍ ពូជសាសន៍ សាសនា ឬការលើកទឹកចិត្តឲ្យមានការរើសអើងឬអំពើហិង្សា ។ រដ្ឋក៏អាចរឹតត្បិតសេរីភាពបញ្ចេញមតិ ប៉ុន្តែការរឹតត្បិតអាចធ្វើឡើងតែក្នុងករណីដែលការរិតត្បិតនេះគឺពិតជាចាំបាច់ដើម្បីការពារនិងគោរពសិទ្ធិឬកិត្តិយសរបស់បុគ្គលផ្សេងទៀតឬដើម្បីការពារសណ្តាប់ធ្នាប់ សុខមាលភាពសីលធម៌សាធារណៈឬសន្តិសុខជាតិ ។

ប្រទេសនៅអឺរ៉ុបជាច្រើនបានដាក់ការរឹតត្បិតចំពោះទម្រង់នៃការបញ្ចេញមតិមួយចំនួនដែលរាប់ទាំងសេចក្តីថ្លែងការណ៍ដែលជំរុញឲ្យមានការស្អប់ខ្ពើមនិងការបដិសេធអត្ថិភាពរបស់ហូឡូខសដោយថ្លឹងថ្លែងយ៉ាងប្រយ័ត្នប្រយែងរវាងសេរីភាពបញ្ចេញមតិ និងការការពារសេចក្តីថ្លៃថ្នូរនិងកិត្តិយសរបស់មនុស្ស ។ ច្បាប់បដិសេធអត្ថិភាពហូឡូខសនៅអឺរ៉ុបបានចាប់ផ្តើមមានការវិវត្តភ្លាមៗបន្ទាប់ពីសង្គ្រាមលោកលើកទី២ ។ នាពេលនោះមានអ្នកខ្លះបានស្វះស្វែងដោះសារចំពោះគោលនយោបាយរបស់ណាហ្ស៊ីអាល្លឺម៉ង់ និងស្តារឡើងវិញនូវមុខមាត់របស់គណៈបក្សណាហ្ស៊ីដោយបដិសេធស្ថានភាពធ្ងន់ធ្ងរនៃអំពើឃោរឃៅឬដោយបដិសេធការទទួលខុសត្រូវ ។ ប្រទេសអឺរ៉ុបខាងលិចនិងខាងកើតជាច្រើនរួមទាំងប្រទេសអ៊ីស្រាអែលដែរមានច្បាប់ដាក់ទោសទណ្ឌដល់ការបន្ទូរបន្ថយការគាំទ្រការដោះសារ ឬបដិសេធអត្ថិភាពហូឡូខស ។ រដ្ឋខ្លះទៀតដូចជាប្រទេសហូឡង់បានចាត់ទុកការបដិសេធអត្ថិភាពហូឡូខសថាជាទម្រង់មួយនៃសាបព្រោះការស្អប់ខ្ពើមហើយដូច្នេះត្រូវបានចាត់ទុកថាជាបទល្មើសដែលអាចដាក់ទោសទណ្ឌបាន ។

ដោយឡែកច្បាប់របស់ប្រទេសអាល្លឺម៉ង់ បានផ្តន្ទាទោសយ៉ាងជាក់ច្បាស់ដល់ការបដិសេធការគាំទ្រនិងការបន្ទូរបន្ថយអត្ថិភាពហូឡូខសនិងឧក្រិដ្ឋកម្មរបស់ពួកណាហ្ស៊ី ។ យុត្តិសាស្ត្ររបស់អាល្លឺម៉ង់បង្ហាញថាច្បាប់ហាមប្រាមមិនឲ្យបដិសេធអត្ថិភាពហូឡូខសគឺអាចមានបានពីព្រោះសេចក្តីថ្លែងការណ៍បែបនេះគឺជំរុញឲ្យមានការប្រកាន់ពូជសាសន៍ និងការស្អប់ខ្ពើមប្រឆាំងនឹងក្រុមមួយជាក់លាក់ ។ តុលាការធម្មនុញ្ញរបស់អាល្លឺម៉ង់ បានពន្យល់ថាខណៈដែលការសម្តែងមតិរបស់នរណាម្នាក់ត្រូវបានការពារដោយច្បាប់ធម្មនុញ្ញរបស់អាល្លឺម៉ង់មតិទាំងឡាយណាដែលយោងទៅលើ “អង្គហេតុដែលអាចបង្ហាញថាមិនពិត” ពុំទទួលបានការ

ការពារពីរដ្ឋធម្មនុញ្ញទេ ។ តាមហេតុផលនេះតុលាការបានសម្រេចថាការថ្កោលទោសចំពោះការបដិសេធអត្ថិភាពហូឡូខសគឺជាការរិតត្បិតមួយដែលទទួលបានការអនុញ្ញាតនៅលើសេរីភាពក្នុងការបញ្ចេញមតិ ។ ទោះបីជាយ៉ាងនេះក្តីបញ្ហាបានកើតឡើង នៅពេលដែលរដ្ឋបានប្រើប្រាស់ច្បាប់ប្រឆាំងនឹងការបដិសេធអំពើប្រល័យពូជសាសន៍ ឬសេចក្តីថ្លែងការណ៍ដែលជំរុញឲ្យមានការស្អប់ខ្ពើមតាមវិធីម្យ៉ាងដែលធ្វើបាបអ្នកដែលមានទស្សនៈមិនប្រជាប្រិយឬសម្រាប់គោលបំណងនយោបាយ ។

ឧទាហរណ៍ ប្រទេសរ៉្វាន់ដាដែលធ្វើច្បាប់ប្រឆាំងនឹងការបដិសេធឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលកើតឡើងក្នុងឆ្នាំ១៩៩៤ត្រូវបានរិះគន់ថា បានប្រើប្រាស់ច្បាប់នេះដើម្បីកាត់ទោសគូបក្ខដិបក្ខនយោបាយ និងអ្នកដែលប្រឆាំង ។ ក្នុងខែមករា ឆ្នាំ២០១២ តុលាការរ៉្វាន់ដា បានកាត់ទោសអ្នកកាសែតពីរនាក់ឲ្យជាប់ទោសពីបទជំទាស់នឹងព្រឹត្តការណ៍ដែលត្រូវបានទទួលស្គាល់ជាផ្លូវការ ។ អ្នកកាសែតនោះបានធ្វើខុសពីការបរិយាយដែលធ្វើឡើងដោយរដ្ឋដែលនិយាយតែអំពីអំពើប្រល័យពូជសាសន៍លើជនជាតិទុតស៊ី ដោយពួកហ៊ូទូតែម្ខាងនៅពេលដែលអ្នកកាសែតនោះបានលើកឡើងថាទាំងទុតស៊ីទាំងហ៊ូទូសុទ្ធតែបានប្រព្រឹត្តអំពើមនុស្សឃាត ។អ្នកកាសែតទាំងពីរនេះ បានរិះគន់ប្រធានាធិបតីរ៉្វាន់ដាថាពុំបានប្រឹងប្រែងឲ្យបានគ្រប់គ្រាន់ក្នុងការផ្តន្ទាទោសអ្នកប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ តាមរយៈនេះ វាច្បាស់ណាស់ថាអ្នកកាសែតខាងលើនេះមិនត្រូវបានកាត់ទោសពីបទបដិសេធអំពើប្រល័យពូជសាសន៍ទេពីព្រោះអ្នកកាសែតទាំងពីរពុំបានបដិសេធអត្ថិភាពនៃអំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដាទេ ។ ផ្ទុយទៅវិញអ្នកកាសែតនោះត្រូវបានជាប់ចោទពីបទស៊ើបអង្កេតនិងផ្សព្វផ្សាយប្រវត្តិសាស្ត្រមួយដែលខុសពីការបរិយាយរបស់ក្រុមទុតស៊ី ។ ជ្រកក្រោមស្លាកការបដិសេធអំពើប្រល័យពូជសាសន៍ រដ្ឋាភិបាលរ៉្វាន់ដា បានកាត់ទោសចំពោះការផ្សព្វផ្សាយការរៀបរាប់ផ្ទុយក៏ដូចជាការប្រើប្រាស់ច្បាប់ប្រឆាំងនឹងការបដិសេធអំពើប្រល័យពូជសាសន៍ដើម្បីបំបិទមាត់ការរិះគន់នយោបាយនិងក្រុមប្រឆាំងនឹងប្រធានាធិបតីរ៉្វាន់ដា ។

ផ្ទុយទៅនឹងច្បាប់ប្រឆាំងនឹងការបដិសេធអំពើប្រល័យពូជសាសន៍នៅអឺរ៉ុប និងរ៉្វាន់ដាច្បាប់ស្តីពីការបញ្ចេញមតិនៅសហរដ្ឋអាមេរិកពុំបានហាមប្រាមការបដិសេធអត្ថិភាពហូឡូខសឬអំពើប្រល័យពូជសាសន៍ទេ ។ នៅសហរដ្ឋអាមេរិករាល់សេចក្តីថ្លែងការណ៍ទាំងអស់ ត្រូវបានការពារពីការត្រួតពិនិត្យផ្សេងៗលើកលែងតែរដ្ឋាភិបាលអាចបង្ហាញថាការរិតត្បិតគឺចាំបាច់ក្នុងការការពារផលប្រយោជន៍សំខាន់ខ្លាំងរបស់រដ្ឋាភិបាល ។ ផលប្រយោជន៍រដ្ឋាភិបាលបែបនេះនៅក្នុងយុត្តិសាស្ត្រសហរដ្ឋអាមេរិកត្រូវបានរកឃើញនៅពេលដែលច្បាប់នេះត្រូវបានធ្វើឡើងយ៉ាងពិសេសដើម្បីហាមប្រាមមិនឲ្យមានការញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋការពារអនីតិជនឬការពារសន្តិសុខជាតិ ។ ហេតុផលនោះគឺថាការអនុញ្ញាតឲ្យមានការពិភាក្សាទោះបើលើគំនិតដែលពុំមានប្រជាប្រិយឬធ្វើឲ្យគេមិនសប្បាយចិត្តក៏ដោយ គឺមានប្រយោជន៍ច្រើនជាងការរិតត្បិតការបញ្ចេញមតិ ។

សេចក្តីសម្រេចរបស់តុលាការកំពូលសហរដ្ឋអាមេរិកបង្ហាញឲ្យឃើញអំពីសេរីភាពបញ្ចេញមតិនៅពេលដែលតុលាការកំពូលនេះបានគាំទ្រសិទ្ធិធ្វើបាតុកម្មរបស់ក្រុមដែលមានទំនោរគាំទ្រណាហ្ស៊ី ។ បន្ទាប់ពីមានសេចក្តីសម្រេចនោះមកសាធារណជនបានប្រមូលផ្តុំគ្នានិងបង្កើតជាកុប្បកម្មប្រឆាំងនឹងក្រុមដែលមានទំនោរគាំទ្រណាហ្ស៊ីហើយដែលមានមនុស្សចូលរួមយ៉ាងច្រើនលើសលុប ។ អស់រយៈពេលជាច្រើនឆ្នាំបន្ទាប់ពីសេចក្តីសម្រេចនោះមកអ្នករស់នៅក្នុងទីក្រុងនោះ បានបើកជាសារមន្ទីរហូឡូខសមជ្ឈមណ្ឌលអប់រំនិងបូជនីយដ្ឋានមួយ ។ អ្នកទាំងនោះថែមទាំងបានបញ្ចុះបញ្ចូលសមាជិកសភាសម្រាប់រដ្ឋនោះ ដោយតម្រូវឲ្យមានការអប់រំអំពីហូឡូខសនៅតាមសាលារៀនទៀតផង ។ តាមរបៀបនេះ សាធារណជនបានដោះស្រាយការប្រកាន់ពូជសាសន៍ដែលមានទំនោរណាហ្ស៊ីដោយរួបរួមគ្នា និងនិយាយជាសាធារណៈប្រឆាំងនឹងការប្រកាន់ពូជសាសន៍នេះ ។ តាមរយៈបង្កើតឲ្យមានកម្មវិធីអប់រំការពិតបានយកជ័យជម្នះទៅលើការបដិសេធ ។

ច្បាប់ដែលដាក់ទោសទណ្ឌប្រឆាំងនឹងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យបានបង្កឲ្យមានក្តីព្រួយបារម្ភស្រដៀងគ្នានឹងករណីនៅប្រទេសរ៉្វាន់ដាដែរ ។ ដូចគ្នានឹងនៅប្រទេសរ៉្វាន់ដាដែរសេរីភាពបញ្ចេញមតិនៅ

តែមានបញ្ហានៅឡើយ នៅកម្ពុជា ។

ការស្រាវជ្រាវប្រវត្តិសាស្ត្រនិងការអប់រំនៅកម្ពុជាពុំដែលឈានទៅរកការសើរើប្រវត្តិសាស្ត្រ ដូចដែលធ្លាប់កើតមាននៅអឺរ៉ុបក្រោយសង្គ្រាមលោកលើកទី២នោះទេ ។ ច្បាប់ប្រឆាំងនឹងការបដិសេធហូឡូខសនៅអឺរ៉ុបគឺជាការឆ្លើយតបទៅនឹងចលនាខ្លាំងមួយក្នុងការសើរើប្រវត្តិសាស្ត្រ ។ ក្រោយសង្គ្រាមលោកលើកទី២នៅអឺរ៉ុបមានជ្រុងមួយនៃសង្គមបានស្វះស្វែងដោះសារចំពោះអំពើរបស់របបណាហ្ស៊ីឬបដិសេធអំពើឃោរឃៅដែលបានកើតឡើង ។ អ្នកទីមួយដែលបដិសេធហូឡូខសគឺលោក ម៉ូរ៉ាយស៍ បាដែហ្ស ដែលបានអះអាងក្នុងសៀវភៅ «នូរឹមបឺក ឬ ដែនដីសន្យា» *(Nuremberg ou le Terre Promise)* ក្នុងឆ្នាំ១៩៤៨ ដែលថាឡូខស្ទ័នសម្លាប់មនុស្សនៅអូស្វិចត្រូវបានប្រើប្រាស់ដើម្បីសម្លាប់មេរោគជាប់នឹងខោអាវប៉ុណ្ណោះ ។ អ្នកសរសេរសៀវភៅម្នាក់ទៀតឈ្មោះផូលរ៉ាស៊ីននីញ៉េបានអះអាងថាទាំងអំពើឃោរឃៅដែលប្រព្រឹត្តឡើងដោយអាល្លឺម៉ង់ និងទាំងចំនួនជនជាតិជ្វីបដែលត្រូវបានសម្លាប់គឺជារឿងបំផ្លើសយ៉ាងខ្លាំង ។ អ្នកនិពន្ធទាំងនេះបានបង្កឲ្យមានជាចលនាបន្ទាប់បន្សំសរសេរបដិសេធហូឡូខសដែលនៅបន្តរហូតមកទល់សព្វថ្ងៃ ។

ផ្ទុយទៅវិញបើទោះបីជាមានការគាំទ្រខ្លះឲ្យមានការសរសេរប្រវត្តិសាស្ត្រឡើងវិញនៅក្នុងតំបន់អតីតមូលដ្ឋានខ្មែរក្រហមមួយចំនួនក៏ដោយ នេះក៏មិនទំនងជាហេតុផលសម្រាប់ច្បាប់ប្រឆាំងនឹងការបដិសេធឧក្រិដ្ឋកម្មខ្មែរក្រហមដែរ ។ នៅស្រុកម៉ាឡៃ និងអន្លង់វែងក្នុងខេត្តភាគពាយ័ព្យនៃប្រទេសកម្ពុជាមានភ័ស្តុតាងមួយចំនួនបង្ហាញថាប្រជាជននៅចាត់ទុកខ្មែរក្រហមជាមនុស្សចិត្តល្អ ដែលជាអ្នកសេដ្ឋកិច្ចដ៏ឆ្នើម និងជាអ្នកអភិវឌ្ឍជនបទ ។ ប៉ុន្តែច្បាប់នេះពុំឆ្លើយតបនឹងរបាយការណ៍អំពីលក្ខខណ្ឌទាំងនេះទេ ។ តាមពិត ច្បាប់នេះគឺស្នើឡើងដើម្បីឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍ដែលធ្វើឡើងដោយលោក កឹម សុខា ប្រធានស្តីទីបក្សប្រឆាំងកាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣ ។ លោក កឹម សុខា ត្រូវបានចោទថាបាននិយាយថាគុកទួលស្លែងត្រូវបានរៀបចំជាឆាកដោយវៀតណាមបន្ទាប់ពីដួលរំលំរបបខ្មែរក្រហមក្នុងឆ្នាំ១៩៧៩ ។ ល្បឿនដែលសភាជាតិកម្ពុជានិងព្រឹទ្ធសភាអនុម័តច្បាប់នេះក្នុងការឆ្លើយតបនឹងសេចក្តីថ្លែងការណ៍តែមួយគត់របស់បក្សប្រឆាំងបើទោះជាមានការគាំទ្រយូរមកហើយចំពោះទស្សនៈសើរើប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមក៏ដោយ បានបង្ហាញឲ្យឃើញថាច្បាប់នេះអាចត្រូវប្រើប្រាស់សម្រាប់គោលបំណងនយោបាយ ។ ការណ៍ដែលថាការបោះឆ្នោតនឹងខិតជិតមកដល់ក្នុងពេលឆាប់ៗខាងមុខនេះនៅកម្ពុជាបានបង្កជាចម្ងល់ថែមទៀតទាក់ទិននឹងមូលហេតុនៅពីក្រោយការធ្វើច្បាប់នេះ ។

ក្នុងបរិបទនេះច្បាប់ស្តីពីការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនៅកម្ពុជាគឺជាច្បាប់ដែលមិនចាំបាច់មួយដែលអាចបង្កឲ្យមានហានិភ័យច្រើន ។ ច្បាប់នេះអាចបង្កឲ្យមានហានិភ័យក្នុងការធ្វើឲ្យទៅជារឿងនយោបាយនូវដំណើរការផ្សះផ្សា និងធ្វើឲ្យរាំងស្ទះដល់ការស្រាវជ្រាវប្រវត្តិសាស្ត្រទាក់ទិននឹងរបបខ្មែរក្រហម ។ បើទោះបីជាពុំមានការហាមប្រាមដោយច្បាប់អន្តរជាតិក៏ដោយការរិតត្បិតសេរីភាពក្នុងការបញ្ចេញមតិតាមរយៈច្បាប់ស្តីពីការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យគឺជាវិធីមិនសមស្របមួយក្នុងការប្រយុទ្ធប្រឆាំងការមិនទទួលស្គាល់អំពើឃោរឃៅរបស់ខ្មែរក្រហមនៅកម្ពុជា ។

វិធីដែលសមស្របជាងនេះមួយក្នុងការប្រយុទ្ធប្រឆាំងនឹងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មបែបនេះគឺការប្រើប្រាស់ការពិភាក្សាការស្តីបន្ទោសជាសាធារណៈនិងការអប់រំ ។ ការស្តីបន្ទោសជាសាធារណៈ ជាជាងការដាក់ទណ្ឌកម្មព្រហ្មទណ្ឌអាចប្រយុទ្ធប្រឆាំងនឹងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មខ្មែរក្រហមយ៉ាងមានប្រសិទ្ធិភាពព្រមទាំងបានបង្ហាញឲ្យឃើញនូវការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការលើកតម្កើងសេរីភាពបញ្ចេញមតិ ។ ផ្ទុយទៅនឹងប្រទេសក្រោយជម្លោះដទៃទៀតដែលប្រើប្រាស់ការរិតត្បិត ការបញ្ចេញមតិដើម្បីប្រយុទ្ធប្រឆាំងនឹងការមិនទទួលស្គាល់អំពើប្រល័យពូជសាសន៍ កម្ពុជាគួរតែធ្វើជារដ្ឋក្រោយជម្លោះគំរូ ។ កម្មវិធីអប់រំផ្សេងៗដូចជាកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងសង្គមស៊ីវិលអាចជាមធ្យោបាយដ៏មានប្រសិទ្ធិភាពក្នុងការប្រយុទ្ធប្រឆាំងនឹងការមិនទទួលស្គាល់

ក្នុងពេលជាមួយគ្នានោះអាចជៀសវាងបាននូវការប្រើប្រាស់រូបភាពទណ្ឌកម្មព្រហ្មទណ្ឌ ។កម្មវិធីផ្សព្វផ្សាយរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានអនុញ្ញាតឲ្យប្រជាជនកម្ពុជាច្រើនជាង៧ម៉ឺននាក់មកពីខេត្តក្រុងទូទាំងប្រទេសឲ្យមកទស្សនកិច្ចនៅអង្គជំនុំជម្រះតែក្នុងមួយឆ្នាំ២០១២ប៉ុណ្ណោះ ហើយសកម្មភាពផ្សព្វផ្សាយតាមសារព័ត៌មានដូចជាកម្មវិធីវិទ្យុប្រចាំសប្តាហ៍ផ្សព្វផ្សាយទៅដល់មនុស្សរាប់ពាន់នាក់បន្ថែមទៀត ។ កម្មវិធីនៃដំណើរទស្សនកិច្ចនៅសាលាក្តីខ្មែរក្រហមដែលនាំទៅទស្សនកិច្ចនៅអង្គជំនុំជម្រះសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងវាលពិឃាដបឹងជើងឯករួមទាំងផ្តល់ឱកាសឲ្យចោទសំណួរទៅកាន់មន្ត្រីសាលាក្តីផងអនុញ្ញាតឲ្យប្រជាជនកម្ពុជាច្រើនជាង១ម៉ឺននាក់ចូលរួម ។ គ្រាន់តែកម្មវិធីដែលឧបត្ថម្ភដោយសាលាក្តីខ្មែរក្រហមមួយប៉ុណ្ណោះគឺនាំប្រជាជនច្រើនជាងបីសែនពីរម៉ឺននាក់មកទស្សនកិច្ចនៅសាលាក្តីចាប់ពីឆ្នាំ២០០៩មក ។ លើសពីនេះទៀត កម្មវិធីផ្សព្វផ្សាយផ្សេងៗដែលរៀបចំឡើងដោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងក្រៅស្រុក បានអប់រំប្រជាជនរាប់ពាន់នាក់អំពីអំពើឃោរឃៅរបស់ខ្មែរក្រហម ។ ជាងនេះទៀត ក្រសួងអប់រំយុវជននិងកីឡារួមសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា បាននឹងកំពុងបណ្តុះបណ្តាលការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) នៅតាមអនុវិទ្យាល័យ និងវិទ្យាល័យនៅទូទាំងប្រទេស ។

តាមរយៈការអប់រំការស្តីបន្ទោសនិងការពិភាក្សារដ្ឋាភិបាលច្បាស់ជាអាចដោះស្រាយបានចំពោះមនុស្សធម្មតាមួយចំនួនតូចដែលនៅតែមិនទទួលស្គាល់អំពើឃោរឃៅរបស់ខ្មែរក្រហម ។ ប្រជាជនកម្ពុជាគួរតែត្រូវបានលើកទឹកចិត្តឲ្យបញ្ចេញមតិប្រឆាំងនឹងបុគ្គលបែបនោះហើយកិច្ចខិតខំប្រឹងប្រែងគួរតែផ្តោតជាសំខាន់លើការអប់រំនិងការពិភាក្សាច្រើនជាង ។ ដោយការអប់រំចេះតែបន្តព្រមទាំងការសម្តែងមតិកាន់តែច្រើនឡើងថែមទៀត នោះច្បាប់ស្តីពីការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យគឺពុំចាំបាច់ឡើយ ។ កម្ពុជាស្ថិតនៅត្រង់ចំណុចសំខាន់មួយក្នុងដំណើរការផ្សះផ្សាក្រោយជម្លោះដូច្នេះ កម្ពុជាមិនគួរត្រូវប្រើប្រាស់ទណ្ឌកម្មព្រហ្មទណ្ឌដើម្បីដោះស្រាយនូវអ្វីដែលអាចដោះស្រាយបានតាមរយៈការសម្តែងមតិ និងការអប់រំ ។ **ខេត ឡេងហួត**



អាគារ ក នៃសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ឬមន្ទីរស-២១ ក្នុងទសវត្សរ៍៨០

# លទ្ធភាពក្នុងការប្រឌិតសាច់រឿងនៅមន្ទីរស-២១ ហួសពីអ្វីដែលវៀតណាមអាចធ្វើបាន

ខ្ញុំចាប់ផ្តើមអានឯកសារចេញពីសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងនាដើមទសវត្សរ៍៩០ ហើយចាប់តាំងពីពេលនោះមក ខ្ញុំបន្តអានឯកសារទាំងនោះរាប់ពាន់សន្លឹកទៀត និងបានឡើងធ្វើបាឋកថានៅឯសិក្ខាសាលាជាច្រើនកន្លែងស្តីអំពីសារមន្ទីរ និងគុកក្នុងសម័យកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានដឹងឮជាទូទៅក្រោមការគ្រប់គ្រងរបស់ ប៉ុល ពត ថាជា "មន្ទីរស-២១" ដែលគ្របដណ្តប់ទីតាំងសារមន្ទីរសព្វថ្ងៃ ។ នៅក្នុងសៀវភៅដែលខ្ញុំបានសរសេរមានចំណងជើងថា "សំឡេងពីមន្ទីរស-២១" ខ្ញុំបានធ្វើការសង្ខេបនូវអ្វីដែលខ្ញុំបានស្រាវជ្រាវ ដែលរួមមានអត្ថបទដែលខ្ញុំបានអានទាំងអស់នេះ និងការសម្ភាសន៍មួយចំនួនជាមួយអ្នកទោសដែលនៅរស់រានមានជីវិត និងជាមួយអ្នកដែលធ្លាប់បម្រើការនៅទីនោះ ។ ចាប់តាំងពីពេលនោះមក ខ្ញុំបានស្គាល់ច្បាស់ពីឯកសារដទៃៗទៀតដែលទាក់ទងទៅនឹងគុកនៅទីនោះ ជាពិសេសឯកសារ និងសម្ភារជាច្រើនដទៃទៀតដែលក្រោយមកយកទៅប្រើប្រាស់នៅសាលាក្តីខ្មែរក្រហមឬមានឈ្មោះជាផ្លូវការថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ជាច្រើនលើកច្រើនសាក្នុងអំឡុងទសវត្សរ៍៩០ និងមិនសូវជាញឹកញាប់ប៉ុន្មាននាអំឡុងពេលក្រោយៗមកទៀត ប្រជាជនកម្ពុជាមួយចំនួនបានប្រាប់ខ្ញុំថា មន្ទីរស-២១ត្រូវបានប្រឌិតឡើងដោយវៀតណាម ហើយការប្រឌិតរឿងបែបនេះគឺដើម្បីបន្ទាប់ដល់កេរ្តិ៍ឈ្មោះប្រជាជនកម្ពុជា និងដើម្បីចោទប្រកាន់ប្រជាជនកម្ពុជាទាំងអស់ថាជាអ្នកប្រព្រឹត្តបទប្រល័យពូជសាសន៍ ។ គ្មានប្រជាជនកម្ពុជាណាម្នាក់ដែលនិយាយមកកាន់ខ្ញុំត្រូវបានចាត់ទុកថាជា "ខ្មែរក្រហម" នោះទេ ។



គំនរឯកសារដែលបន្សល់នៅគុកទួលស្លែងក្រោយរបបខ្មែរក្រហមដួលរលំក្នុងឆ្នាំ១៩៧៩ ។

ខ្ញុំតែងតែឆ្លើយតបទៅអ្នកទាំងនោះវិញថា ការអះអាងបែបនេះមិនត្រឹមត្រូវទេ ។ លទ្ធភាពក្នុងការប្រឌិតសាច់រឿងនៅមន្ទីរស-២១ហួសពីអ្វីដែលវៀតណាមអាចទទួលរ៉ាប់រងបានឆ្ងាយណាស់ ហើយការបង្កើតនេះមានលក្ខណៈស្មុគស្មាញទៅទៀត ។ នៅក្នុងកំឡុងឆ្នាំ១៩៧៩-១៩៨០ ប្រទេសវៀតណាមមិនមានធនធានអ្វីក្នុងការបង្កើតឯកសាររាប់ពាន់សន្លឹកដែលបានរកឃើញនៅក្នុងបណ្ណសារនៃមន្ទីរស-២១ និងឯកសារដែលពាក់ព័ន្ធទៅនឹងមន្ទីរស-២១ រាប់ពាន់សន្លឹកផ្សេងទៀតដែលត្រូវបានរកឃើញនៅកន្លែងដទៃទៀតក្នុងទីក្រុងភ្នំពេញបន្ទាប់ពីវៀតណាមបានចេញពីកម្ពុជានោះទេ និងឯកសារមួយចំនួនទៀតនៅតែរកឃើញក្នុងទសវត្សរ៍៩០ ។ មកដល់ត្រឹមពាក់កណ្តាលឆ្នាំ១៩៧៩ នៅពេលដែលអ្នកស្រាវជ្រាវនិងអ្នករួចរស់ជីវិតជនជាតិខ្មែរកំពុងតែធ្វើការរៀបចំបណ្ណសារមន្ទីរស-២១ វៀតណាមគ្មានពេលនឹងបង្កើតឈ្មោះនិងប្រវត្តិរូបអ្នកធ្លាប់ធ្វើការនៅគុកនេះទេ គ្មានពេលនឹងក្លែងបន្លំភស្តុតាងដ៏ខ្លោចផ្សាដែលខ្មែរក្រហមបានធ្វើមកលើជនរងគ្រោះដ៏ច្រើនសន្ធឹកសន្ធាប់ ហើយក៏គ្មានពេលនឹងប្រឌិតប្រវត្តិរូបសម្រាប់អ្នករួចរស់ជីវិត និងអ្នកធ្លាប់ធ្វើការនៅមន្ទីរស-២១នេះដែរ ។ម្យ៉ាងវិញទៀត ប្រសិនជាវៀតណាមបានព្យាយាមធ្វើកិច្ចការច្រើនបែបនេះមែនម្ល៉េះអ្នកដែលធ្លាប់ចូលរួមធ្វើការងារនេះកាលពីទសវត្សរ៍៩០និយាយពីរឿងរ៉ាវទាំងអស់នេះ ហើយជាពិសេសក្រោយពីកងទ័ពវៀតណាមដកចេញពីប្រទេស ។

ភាពពិតនោះគឺថា កម្លាំងរុញច្រានក្នុងការផ្លាស់ប្តូរពីគុកទួលស្លែងទៅជាសារមន្ទីរប្រល័យពូជសាសន៍គឺមកពីវៀតណាមដែលស្ថិតក្រោមការណែនាំពីមន្ត្រីយោធាជាន់ខ្ពស់របស់វៀតណាមម្នាក់ឈ្មោះ ម៉ៃ ឡាំ ដែលទើបតែទទួលមរណភាពនៅក្នុងទីក្រុងហូជីមិញកាលពីពេលថ្មីៗនេះប៉ុណ្ណោះ ។ ម៉ៃ ឡាំ ត្រូវបានសម្ភាសន៍ជាញឹកញាប់នៅក្នុងកំឡុងទសវត្សរ៍៨០និង៩០ ។ ម៉ៃ ឡាំ ធ្លាប់និយាយថា គាត់ពិតជាមានមោទកភាពខ្លាំងណាស់ក្នុងការសហការការងារដើម្បីផ្លាស់ប្តូរពីមន្ទីរស-២១ឲ្យទៅជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ គាត់ក៏មានសេចក្តីសោមនស្សរីករាយដែរដែលគាត់បានចូលរួមផ្លាស់ប្តូរពីវាលពិឃាតជើងឯក ដែលមានអ្នកទោសជាងមួយម៉ឺននាក់មកពីមន្ទីរស-២១ត្រូវបានយកមកសម្លាប់នៅទីនោះ ឲ្យក្លាយទៅជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ ។

ម៉ៃ ឡាំ ធ្វើការជាមួយនឹងអ្វីដែលគាត់បានរកឃើញក្នុង



ម៉ៃ ឡាំ (ឆ្វេង) ជំនាញការវៀតណាមនិងជាអ្នកជួយបង្កើតសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ជាមួយក្រុមអ្នកជំនាញការខ្មែរ និងអតីតកម្មាភិបាលខ្មែរក្រហម ។

ប្រទេសកម្ពុជាក្រោយឆ្នាំ១៩៧៩ ដែលនេះអាចនិយាយបានថា ជាភ័ស្តុតាងនៃការសួរចម្លើយ ការធ្វើទារុណកម្ម ការសម្លាប់ដ៏ច្រើន សន្ធឹកសន្ធាប់ដែលត្រូវបានកត់ត្រាយ៉ាងច្បាស់លាស់ ព្រមទាំង រូបភាពជនរងគ្រោះរាប់ពាន់សន្ធឹក ហើយរូបថតជាច្រើនសន្ធឹក ត្រូវបានសាច់ញាតិដែលនៅរស់រានមានមានជីវិតចំណាំបាន ហើយ គ្រួសារខ្លះក៏បានអានចម្លើយសារភាពសាច់ញាតិរបស់ខ្លួនដែរ ។

វៀតណាមបានបង្កើតជាសារមន្ទីរនៅទួលស្លែងនៅក្នុង អំឡុងឆ្នាំ១៩៧៩ និងឆ្នាំ១៩៨០ ដោយហេតុផលមួយចំនួន ។ មូលហេតុចម្បងនោះខ្ញុំជឿជាក់ថាជាការចាំបាច់សម្រាប់វៀតណាម ក្នុងការស្វែងរកនូវមូលដ្ឋានស្របច្បាប់សម្រាប់វត្តមានរបស់ខ្លួន នៅក្នុងប្រទេសកម្ពុជា ហើយនឹងភាពស្របច្បាប់របស់រដ្ឋាភិបាល សាធារណរដ្ឋប្រជាមានិតកម្ពុជា ដោយហេតុថា ខ្លួនបានរំដោះ ប្រទេសកម្ពុជាចេញពីអ្វីដែលហៅថា “ក្រុមប្រល័យពូជសាសន៍” ក្រោមការដឹកនាំរបស់ ប៉ុល ពត និង អៀង សារី ដែលត្រូវបានកាត់ ទោសប្រហារជីវិតក្នុងខែសីហា ឆ្នាំ១៩៧៩ ដោយកំបាំងមុខ ។ ការបង្កើតសារមន្ទីរនេះក៏មានសារសំខាន់ដែរសម្រាប់ប្រទេស ដែលជាសម្ព័ន្ធមិត្តរបស់វៀតណាមនៅក្នុងប្លុកសូវៀត ដើម្បីផ្តាច់ បក្សកុម្មុយនីស្តវៀតណាមនិងដៃគូរកម្ពុជារបស់ខ្លួនចេញពីរបប កុម្មុយនីស្តនៃកម្ពុជាប្រជាធិបតេយ្យ ។ ជាការសំខាន់ដែរសម្រាប់ វៀតណាម និងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដើម្បីចាត់ទុក របបកម្ពុជាប្រជាធិបតេយ្យថាជា “របបហ្វាស៊ីសផ្តាច់ការ” ដូច ណាស៊ីអាល្លឺម៉ង់ ជាជាងគ្រាន់តែជាប្រទេសកុម្មុយនីស្តដែលប្រទេស កុម្មុយនីស្តផ្សេងទៀតទទួលស្គាល់ ។ ការរៀបចំជាសារមន្ទីរនេះក៏ មានការសារសំខាន់ដែរដើម្បីអះអាងបញ្ជាក់ថា អ្វីដែលបានកើត ឡើងនៅក្នុងប្រទេសកម្ពុជាក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ហើយជាពិសេសគឺនៅមន្ទីរស-២១ គឺអំពើប្រល័យពូជសាសន៍ ស្រដៀងទៅនឹងរបបហ្វូឡូខស៍ដែលបានកើតឡើងនៅក្នុងសម័យ សង្គ្រាមលោកលើកទី២ដែរ ជាជាងគ្រាន់តែជាអំពើសម្លាប់ដោយ ប្រព័ន្ធមកលើសត្រូវនយោបាយដែលបានកើតឡើងនាដំណាក់ កាលផ្សេងៗគ្នានៅក្នុងប្រវត្តិសាស្ត្រសហភាពសូវៀត កុម្មុយនីស្ត ចិន និងវៀតណាម ។

វៀតណាមបានរៀបចំមន្ទីរស-២១ ទៅជាសារមន្ទីរមួយ ដោយប្រើប្រាស់នូវឯកសារយ៉ាងច្រើនសន្ធឹកសន្ធាប់ដែលនៅសេស សល់ ។ ស្រដៀងគ្នានេះដែរ វៀតណាមបានកែប្រែវាលពិឃាត ជើងឯកឲ្យក្លាយទៅជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ បន្ទាប់ពី សាកសពរាប់ពាន់នាក់ត្រូវបានជីកគាស់ពីក្នុងរណ្តៅ ។ នៅក្នុង ករណីទាំងពីរកន្លែងនេះ មិនមែនវៀតណាមជាអ្នកបង្កើតនោះទេ ។ តែជាក់ស្តែងឯកសារជាច្រើនទំព័រពីបណ្ណសារនៅស-២១ រូបថត អ្នកទោសរាប់ពាន់សន្ធឹក បទសម្ភាសន៍ជាច្រើនជាមួយអ្នករួចរស់ ជីវិត និងអតីតកម្មាភិបាលនៅស-២១ និងភ័ស្តុតាងយ៉ាងច្រើន សន្ធឹកសន្ធាប់ឯទៀតដែលបានប្រើ ដើម្បីកាត់ទោស ឌុច នៅអង្គជំនុំ ជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ធ្វើឲ្យខ្ញុំសន្និដ្ឋានបានថាក្នុងចន្លោះពី ពាក់កណ្តាលឆ្នាំ១៩៧៦ រហូត ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ស-២១គឺជាមន្ទីររបស់កម្ពុជា ប្រជាធិបតេយ្យយ៉ាងពិតប្រាកដ ដែលបង្ហាញពីគំនិតដ៏គួរឲ្យខ្លាច របស់អ្នកដឹកនាំដ៏ព្រៃផ្សៃនិងជា របបដ៏ព្រៃផ្សៃសម្រាប់ប្រជាជន កម្ពុជា ។ **ដេវីដ ឆេនដល័រ**



បន្ទប់ឃុំឃាំងអ្នកទោសនៅមន្ទីរស-២១ និងស្នាមឈាមអ្នកទោសដែលខ្មែរក្រហមសម្លាប់មុនពេលគេចខ្លួនក្នុងឆ្នាំ១៩៧៩

# ទស្សនៈផ្ទុះបញ្ចាំងស្ដីពីសុខភាពផ្លូវចិត្តក្នុងសំណុំរឿង០០២

ចាប់តាំងពីថ្ងៃទី៤ដល់ទី៦ ខែមិថុនា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានស្ដាប់សវនាការរបស់លោកស្រី បេ សុផានី ដែលជាដើមបណ្ដឹងរដ្ឋប្បវេណី និងវេជ្ជបណ្ឌិត ឈឹម សុធារ៉ា ជាសាក្សីជំនាញមួយរូប ។ លោកស្រី សុផានី ជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅសហរដ្ឋអាមេរិក ហើយឥឡូវនេះបម្រើការជាអ្នកផ្ដល់ប្រឹក្សាសុខភាពផ្លូវចិត្តសម្រាប់ជនភៀសខ្លួនកម្ពុជានៅទីក្រុងសានហូសេ រដ្ឋកាលីហ្វ័រញ៉ា ។ វេជ្ជបណ្ឌិត ឈឹម សុធារ៉ា



បេ សុផានី នៅសាលាក្ដីខ្មែរក្រហមខែវិច្ឆិកា ឆ្នាំ២០១១



វេជ្ជបណ្ឌិត ឈឹម សុធារ៉ា

ជាអ្នកជំនាញដ៏ល្បីឈ្មោះខាងសុខភាពផ្លូវចិត្តមួយរូបក្នុងចំណោមបីបួនរូបនៅក្នុងប្រទេសកម្ពុជា ដែលបច្ចុប្បន្នបម្រើការជានាយកប្រតិបត្តិរបស់អង្គការចិត្តសង្គម អន្តរវប្បធម៌ ។ ការសួរសំណួររបស់សាលាក្ដីទៅលើដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រី សុផានី និងសាក្សីជំនាញ វេជ្ជបណ្ឌិត សុធារ៉ា បានបង្ហាញថា ខណៈដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចាប់ផ្ដើមទទួលស្គាល់ការឈឺចាប់ផ្នែកផ្លូវចិត្តរបស់ជនរងគ្រោះនៅក្នុងសម័យខ្មែរក្រហម ការធ្វើឲ្យប្រសើរឡើងវិញអាចកើតមានតាមរយៈដំណើរការនៃការផ្ដល់សក្ខីកម្មរបស់អ្នកជំនាញ ទាក់ទងនឹងសុខភាពផ្លូវចិត្តនេះ ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្ដែងនូវការទទួលស្គាល់ពីភាពជាប់ពាក់ព័ន្ធនឹងជំងឺផ្លូវចិត្តនៅក្នុងការសាកសួរដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រី សុផានី ។ មុននឹងឆ្លើយតបទៅនឹងសំណួររបស់លោកស្រី សុផានី ប្រធានអង្គជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លោក និល ណុន បានបញ្ជាក់យ៉ាងច្បាស់ថា ៖ «ក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រីមានឱកាសធ្វើសេចក្ដីថ្លែងពីការឈឺចាប់ដែលប៉ះពាល់មកលើរូបលោកស្រី ផ្នែកសម្ភារផ្លូវចិត្ត និងខាងរូបរាងកាយ» ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដើមបណ្ដឹងរូបនេះបានរំឭកឡើងវិញនូវសាច់រឿងដ៏មានឥទ្ធិពលក្នុងពេលជម្លៀសចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា និងការស្លាប់កូនរបស់លោកស្រីចំនួនបីនាក់ ។ ខណៈពេលកំពុងធ្វើសក្ខីកម្ម ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានគូសបញ្ជាក់អំពីការឈឺចាប់ផ្នែកខាងផ្លូវចិត្ត ។ នៅពេលដែលលោកស្រីពណ៌នាអំពីស្ថានភាពផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរដែលលោកស្រីត្រូវបានបង្ខំឲ្យទ្រាំទ្រ ចំណុចផ្ដោតអារម្មណ៍របស់លោកស្រីគឺកូន ថាតើកូនរបស់លោកស្រីត្រូវបានធ្វើបាប និងបំពារបំពានយ៉ាងដូចម្ដេចខ្លះពីសំណាក់ទាហានខ្មែរក្រហម ហើយថាតើការស្លាប់របស់កូនលោកស្រីបានជះឥទ្ធិពលយ៉ាងដូចម្ដេចខ្លះមកលើរូបលោកស្រី ។ លោកស្រីបាននិយាយអំពីសុបិន្តអាក្រក់ជាប្រចាំ មិនអាចនិយាយរួច មានភាព

ប្របូកប្រុបល់ និងភ្លេចភ្លាំងច្រើន យំមិនឈប់ និងចង់ស្លាប់បន្ទាប់ពីការស្លាប់របស់កូនៗ ។ លោកស្រីពន្យល់បន្ថែមទៀតថា លោកស្រីនៅតែមានរោគសញ្ញាទាំងអស់នេះរហូតមកដល់សព្វថ្ងៃនេះ ។ ក្នុងនាមជាអ្នកប្រឹក្សាយោបល់ខាងសុខភាពផ្លូវចិត្ត លោកស្រីបានដឹងថា រោគសញ្ញានេះគ្មានលក្ខណៈប្លែកពីគេទេ លោកស្រីមើលឃើញថាមានរោគសញ្ញាដូចគ្នាក្នុងចំណោមអតិថិជនរបស់លោកស្រី និងសហគមន៍ជនភៀសខ្លួនកម្ពុជា ។

ខណៈដែលការពណ៌នាអំពីការឈឺចាប់ផ្នែកផ្លូវចិត្តមានភាពរំជួលចិត្តហើយបានធ្វើឲ្យអ្នកចូលរួមក្នុងសវនាការស្រក់ទឹកភ្នែក លោក សុន អារុណ សហមេធាវីជាតិការពារក្តីលោក នួន ជា បានប្រើសក្ខីកម្មរបស់លោកស្រីដើម្បីចោទសួរពីភាពត្រឹមត្រូវនៃសក្ខីកម្មនិងស្ថានភាពចិត្តសាស្ត្ររបស់លោកស្រីទៅវិញ ។ ទាក់ទងនឹងការសុបិន្តអាក្រក់ជាប្រចាំនិងការធ្លាក់ទឹកចិត្ត សហមេធាវីរូបនេះបានស្នើសុំថាតើលោកស្រីអាចជួយអ្នកផ្សេងទៀតដែលមានបញ្ហាផ្លូវចិត្តយ៉ាងដូចម្តេច ដោយសារបញ្ហាសុខភាពផ្លូវចិត្តរបស់លោកស្រីមិនសមស្រប ហើយការចងចាំរបស់លោកស្រីទៀតសោត "មិនល្អ" ទៀតនោះ ដែលព្យាយាមបង្កប់ន័យថាតើលោកស្រីពិតជាចងចាំអ្វីៗគ្រប់យ៉ាងដ៏ត្រឹមត្រូវដែរឬទេ ។ មុនពេលដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបដិសេធ និងអះអាងថា ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចនិយាយអ្វីៗអំពីការបាត់ការចងចាំនោះឡើយ ហើយថាមេធាវីការពារក្តីមិនគួរសន្មតទុកនូវការពិតបែបនោះទេ ។ តុលាការទទួលយកការជំទាស់របស់មេធាវីការពារក្តី ។

ទោះបីជាមានការទទួលស្គាល់ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអំពីការប៉ះពាល់ផ្លូវចិត្តរបស់លោកស្រី សុផានី ការស្តាប់សវនាការរបស់សាក្សីជំនាញ វេជ្ជបណ្ឌិត ឈឹម សុធារ៉ា បានលាតត្រដាងពីភាពទន់ខ្សោយជាច្រើននៅក្នុងជំនាញរបស់បុគ្គលិកតុលាការ និងដំណើរការដែលចាំបាច់សម្រាប់ការប្រើប្រាស់សក្ខីកម្មអ្នកជំនាញប្រកបដោយប្រសិទ្ធភាពទៅលើសុខភាពផ្លូវចិត្តនោះឡើយ ។ សាក្សីជំនាញរបស់វេជ្ជបណ្ឌិត ឈឹម សុធារ៉ាហាក់ដូចជាមិនបានសម្រេចគោលដៅដែលចង់បាន ដើម្បីគូសបញ្ជាក់អំពីកម្រិតឬទំហំនៃផលប៉ះពាល់ផ្នែកផ្លូវចិត្តដែលរបបខ្មែរក្រហមបានបង្កមកលើប្រជាជនកម្ពុជាឡើយ ។ ទីមួយ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីនិងព្រះរាជអាជ្ញាមិនបានចោទសួរវេជ្ជបណ្ឌិត ឈឹម សុធារ៉ា តាមរបៀបមួយដែលអាចប្រើប្រាស់ជំនាញរបស់លោកប្រកបដោយប្រសិទ្ធភាពនៅក្នុងការគូសបញ្ជាក់ និងពន្យល់ទស្សនវិស័យក្នុងនីកនៅក្នុងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្តីពីផលប៉ះពាល់ផ្នែកផ្លូវចិត្តនៅក្រោមរបបខ្មែរក្រហម ។ ទីពីរ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីនិងព្រះរាជអាជ្ញាអាចបង្កើតមូលដ្ឋានយ៉ាងរឹងមាំនៃជំនាញខាងគ្លីនីករបស់វេជ្ជបណ្ឌិត ឈឹម សុធារ៉ា ។ នៅចុងបញ្ចប់មានភាពប្របូកប្រុបល់នៅក្នុងការបកប្រែពាក្យបច្ចេកទេសដែលមានលក្ខណៈទូទៅសម្រាប់ឯកទេសផ្លូវចិត្ត ។

នៅក្នុងការចោទសួរសាក្សី មេធាវីបាននិយាយសង្ខេបអំពីជនរងគ្រោះដែលវេជ្ជបណ្ឌិត ឈឹម សុធារ៉ា បានជួបតាមរយៈកិច្ចការរបស់លោកជាមួយអង្គការចិត្តសង្គម-អន្តរវប្បធម៌ និងរោគសញ្ញាស្តីពីស្ថានភាពផ្លូវចិត្តផ្សេងៗទៀត ដែលកើតមានចំពោះជនរងគ្រោះនៃរបបខ្មែរក្រហម មានដូចជា ជំងឺបាក់ទឹកចិត្ត ធ្លាក់ទឹកចិត្តថប់បារម្ភ និងរោគឆ្កួត ។ បន្ថែមពីនេះទៀត មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានសាកសួរអំពីសភាពការណ៍ជាក់ស្តែង និងកម្រិតដែលជំងឺផ្លូវចិត្តបានកើតឡើង ។ លោក វ៉ិចទ័រ កូប៉េ មេធាវី ការពារក្តីលោក នួន ជា បានជំទាស់ជាញឹកញាប់ ដោយអះអាងថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនបានព្យាយាមបង្កើតមូលដ្ឋានដ៏សមស្របមួយទាក់ទងនឹងជំនាញខាងគ្លីនីករបស់អ្នកជំនាញឡើយ ។ តាមទស្សនៈរបស់លោក មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបន្តស៊ើបអង្កេតទៅលើហេតុការណ៍ជាក់លាក់ ដែលអ្នកជំនាញអាច ឬមិនអាចមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីផ្តល់សក្ខីកម្មទេ ។ ការណ៍នេះបង្ហាញថា ភាពប្របូកប្រុបល់មួយចំនួនក្នុងចំណោមមេធាវីទាក់ទងនឹងវិសាលភាពនៃសក្ខីកម្មរបស់វេជ្ជបណ្ឌិត ឈឹម សុធារ៉ា ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានចោទសួរវេជ្ជបណ្ឌិត ឈឹម សុធារ៉ា អំពីបទពិសោធន៍គ្លីនីកផ្ទាល់ខ្លួនរបស់លោក ប៉ុន្តែមិនមែនជាបញ្ហាវន្តដែលគួរផ្តល់សក្ខីកម្មអំពីការពិនិត្យមើលផ្នែកអក្សរសាស្ត្រឲ្យបានច្បាស់លាស់ និងទូលំទូលាយទាក់ទងនឹងផលប៉ះពាល់របស់របបខ្មែរក្រហមទៅលើសុខភាពផ្លូវចិត្តនៅប្រទេសកម្ពុជាទេ ។ ខណៈដែលបទពិសោធន៍របស់លោកពិតជាកើតចេញពីព័ត៌មាន

និងការរៀបរាប់យ៉ាងច្រើនសន្ធឹកសន្ធាប់ ការពិនិត្យមើលផ្នែកអក្សរសាស្ត្រប្រហែលជាមានប្រសិទ្ធភាពបំផុត ដោយសារតែការពិនិត្យមើលបែបនោះផ្អែកលើភ័ស្តុតាងដែលកើតមានឡើង និងត្រូវបានបោះពុម្ពផ្សាយដែលមានលក្ខណៈទូលំទូលាយ និងច្បាស់លាស់ជាងមុន ។

ខណៈដែលមានព័ត៌មានតាមស្ថិតិជាច្រើនដែលប្រមែប្រមូលបានពីសុខភាពផ្លូវចិត្តដែលទាក់ទងនឹងជំងឺប៉ះទង្គិចផ្លូវចិត្ត ហើយព័ត៌មានមួយចំនួនតម្រូវឲ្យទទួលយកធ្វើជាភ័ស្តុតាងនៅក្នុងតុលាការទៀតផងនោះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនបានអើពើចំពោះភ័ស្តុតាងបែបនោះទេ នៅក្នុងពេលចោទសួរ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីនិងព្រះរាជអាជ្ញាហាក់ដូចជាមិនបានសាសួរអំពីចំណេះដឹងផ្នែកគ្លីនិករបស់វេជ្ជបណ្ឌិត ឈឹម សុធារ៉ា ដើម្បីប្រមូលតួលេខពិតប្រាកដនិងការពិតនានាដែលទិន្នន័យស្តីពីបរិមាណ ដែលគួរតែអាចគាំទ្រសក្ខីកម្មពីមុនៗអំពីការលំបាកខាងផ្លូវចិត្តនៅជំនាន់ខ្មែរក្រហម ។ ជំនួសមកវិញ សំណួរសម្រាប់វេជ្ជបណ្ឌិត ឈឹម សុធារ៉ា តម្រូវឲ្យមានចម្លើយបែបវិភាគ ដែលមិនមានភាពរឹងមាំដូចរឿងរ៉ាវចេញពីជនរងគ្រោះដោយខ្លួនឯងឡើយ នេះបើយោងតាមអ្នកជំនាញរូបនេះ ។ ចម្លើយរបស់វេជ្ជបណ្ឌិត ឈឹម សុធារ៉ា ទាក់ទងនឹងផលប៉ះពាល់ខាងផ្លូវចិត្តដែលបានកើតឡើងពីសភាពការណ៍មួយចំនួនមិនត្រូវបានគាំទ្រជាទូទៅទេពីសំណាក់ការសិក្សាផ្សេងៗទៀត ប៉ុន្តែបានត្រឹមតែការពណ៌នារបស់វេជ្ជបណ្ឌិត ឈឹម សុធារ៉ា តែប៉ុណ្ណោះ ។ វេជ្ជបណ្ឌិត ឈឹម សុធារ៉ា មិនបាននិយាយអំពីភ័ស្តុតាងផ្អែកលើស្ថិតិដែលត្រូវបានបង្កើតឡើងស្តីពីសុខភាពផ្លូវចិត្តរបស់ប្រជាជនកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមឡើយ ដោយសារលោកមិនត្រូវបានសួរអំពីរឿងនេះសោះ ។ នៅទីបញ្ចប់ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីនិងព្រះរាជអាជ្ញាមិនបាននិយាយសំដៅទៅរកការសិក្សាជាក់លាក់ណាមួយដែលវេជ្ជបណ្ឌិត ឈឹម សុធារ៉ា បានធ្វើកិច្ចការនេះដើម្បីទទួលបានទិន្នន័យជាតួលេខជាក់ស្តែង ទាក់ទងនឹងសុខភាពផ្លូវចិត្តនៃជនរងគ្រោះខ្មែរក្រហមទេ ។

បន្ថែមពីនេះទៀត មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងព្រះរាជអាជ្ញាមិនបានបង្កើតមូលដ្ឋានសម្រាប់សុខភាពផ្លូវចិត្ត ។ ពួកគេមិនបានសួរសំណួរទាំងឡាយដូចជា «តើគ្រូពេទ្យចិត្តសាស្ត្រវាយតម្លៃទៅលើរោគសញ្ញាជំងឺថប់អារម្មណ៍ទាក់ទងនឹងបទពិសោធន៍ជំងឺផ្លូវចិត្តយ៉ាងដូចម្តេច?» «តើអ្វីជារបៀបកំណត់រោគសញ្ញានិងស្ថិតិស្តីពីរោគផ្លូវចិត្ត? ហើយតើត្រូវអនុវត្តយ៉ាងដូចម្តេច?» ហើយ «អ្វីជាលទ្ធផលចេញពីការសិក្សា ដែលបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជា និងឬនៅក្នុងចំណោមជនភៀសខ្លួនកម្ពុជា ដើម្បីសម្រួលដល់ការយល់សក្ខីកម្មរបស់អ្នកជំនាញរបស់តុលាការ ។ សំណួរជាក់លាក់ទៅលើបទពិសោធន៍ផ្នែកគ្លីនិករបស់វេជ្ជបណ្ឌិត ឈឹម សុធារ៉ា ហាក់ដូចជាមិនបានផ្តល់ចំណេះដឹងជាមូលដ្ឋានដ៏ចាំបាច់ទៅលើសុខភាពផ្លូវចិត្តនោះឡើយ ។

លោក កូប៉េ មេធាវីការពារក្តីលោក នួន ជា ចង់បានពេលវេលាបន្ថែមដើម្បីសួរវេជ្ជបណ្ឌិត ឈឹម សុធារ៉ា អំពីភាពលម្អៀងយ៉ាងខ្លាំងទៅលើចុងចោទ សមត្ថភាព ការសិក្សា និងវិធីសាស្ត្រ ក្នុងការធ្វើការស្រាវជ្រាវ ។ ទាំងខាងចុងចោទនិងព្រះរាជអាជ្ញាត្រូវបានផ្តល់ពេលវេលាច្រើនថែមទៀត ដើម្បីសាកសួរវេជ្ជបណ្ឌិត ឈឹម សុធារ៉ា នៅថ្ងៃបន្ទាប់ ។ នៅថ្ងៃទី៦ ខែមិថុនា ព្រះរាជអាជ្ញាសួរសំណួរផ្សេងៗ ដោយសំដៅទៅលើការសិក្សារបស់វេជ្ជបណ្ឌិត ឈឹម សុធារ៉ា ។ តែទោះជាយ៉ាងណា ការសួរដេញដោលរបស់លោក កូប៉េ បានបំផ្លាញដល់សក្ខីកម្មនេះ ។ វេជ្ជបណ្ឌិត ឈឹម សុធារ៉ា ត្រូវបានបង្ខំឲ្យនិយាយថា លោកមិនមែនជាវេជ្ជបណ្ឌិតនៅក្នុងន័យសិក្សាស្រាវជ្រាវទេ ដោយសារលោកមិនទាន់ទទួលបានសញ្ញាប័ត្រថ្នាក់បណ្ឌិតនៅឡើយ ហើយស្ថិតក្នុងដំណាក់កាលទទួលបានសញ្ញាប័ត្រថ្នាក់បណ្ឌិត ។ នៅក្នុងការចោទសួរនោះ លោក កូប៉េ បន្តនិយាយសំដៅទៅលើស្ថិតិដែលបំផ្លាញដល់ផលប៉ះពាល់ផ្លូវចិត្តមកលើប្រជាជនកម្ពុជាពីសំណាក់របបខ្មែរក្រហម ។ ព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនបានជំទាស់សោះ ហើយវេជ្ជបណ្ឌិត ឈឹម សុធារ៉ា ក៏មិនបានកែតម្រូវការប្រើប្រាស់ស្ថិតិនោះពីសំណាក់លោក កូប៉េ ដែរ ។ លោក កូប៉េ ក៏បានវាយប្រហារទៅលើអព្យាក្រិតភាពរបស់ វេជ្ជបណ្ឌិត ឈឹម សុធារ៉ា ក្នុងនាមជាសាក្សីជំនាញ ដោយសារតែលោកក៏ជាជនរងគ្រោះនៃរបបខ្មែរក្រហមដែរ ។ ការណ៍នេះបង្ហាញថា ប្រហែលជាជំនាញដទៃទៀត មានដូចជាវេជ្ជបណ្ឌិត ហ្ស៊ីប ដេជុង ឬ វេជ្ជបណ្ឌិត ជេមស៍ បូឡេន អាចជាសាក្សីជំនាញប្រសើរជាងនេះ ដោយសារតែមិនអាចលម្អៀង

ឡើយ ។

មុនពេលផ្អាកសវនាការនៅថ្ងៃទី៥ ខែមិថុនា បន្ទាប់ពីត្រួតពិនិត្យពីសំណាក់ព្រះរាជអាជ្ញាទៅលើវេជ្ជបណ្ឌិត ឈឹម សុធារ៉ា លោកប្រធានបានស្នើឲ្យវេជ្ជបណ្ឌិតកុំប្រើប្រាស់ភាសាអង់គ្លេសក្នុងអំឡុងពេលធ្វើសក្ខីកម្ម ។ នៅក្នុងការពិភាក្សាជាមួយវេជ្ជបណ្ឌិត ឈឹម សុធារ៉ា មុនពេលធ្វើសក្ខីកម្ម លោកវេជ្ជបណ្ឌិតបានសម្រេចចិត្តប្រើប្រាស់ភាសាអង់គ្លេសសម្រាប់ពាក្យពេជន៍ចិត្តសាស្ត្រមួយចំនួនដោយសារតែលោកមានអារម្មណ៍ថា សក្ខីកម្មរបស់លោកនៅក្នុងសំណុំរឿង០០១ ត្រូវបានបង្វែរដោយសារការប្រើពាក្យខុសពីសំណាក់អ្នកបកប្រែ ។ លោកវេជ្ជបណ្ឌិតមិនប្រាកដក្នុងចិត្តថាតើអ្នកបកប្រែមានចំណេះដឹងជាមូលដ្ឋានអំពីសុខភាពផ្លូវចិត្តសម្រាប់សក្ខីកម្មអ្នកជំនាញនៅក្នុងសំណុំរឿង០០២ ហើយមិនចង់ឲ្យសក្ខីកម្មរបស់លោកត្រូវបានយល់ខុសជាថ្មីទៀត ។

បើទោះជាតុលាការទទួលស្គាល់ការឈឺចាប់ខាងផ្លូវចិត្តរបស់ជនរងគ្រោះនៅក្នុងសវនាការ ដើមបណ្តឹងរដ្ឋប្បវេណី ការចោទសួរអ្នកជំនាញគូសបញ្ជាក់អំពីចំណុចគន្លឹះមួយចំនួនសម្រាប់កែលម្អ ។ គោលបំណងរបស់សក្ខីកម្មជំនាញរបស់វេជ្ជបណ្ឌិត ឈឹម សុធារ៉ា ត្រូវតែបញ្ជាក់អំពីសារជាតិនៃការប៉ះទង្គិចផ្លូវចិត្តដែលកើតចេញពីអំពើឃោរឃៅរបបសម័យខ្មែរក្រហម ។ ជាអកុសល មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងព្រះរាជអាជ្ញាបានសួរលោកវេជ្ជបណ្ឌិត តាមរបៀបជាសាក្សីធម្មតាដោយសុំឲ្យលោករៀបរាប់មិនមែនតួលេខ និងការសន្មត ប៉ុន្តែមិនមែនការពិត ហើយនៅពេលដែលលោកវេជ្ជបណ្ឌិតកំពុងត្រូវបានសួរដេញដោលអំពីសមត្ថភាពរបស់លោក មេធាវីដើមបណ្តឹង និងព្រះរាជអាជ្ញាមិនអាចទប់ស្កាត់ការវាយប្រហារនោះឲ្យបានគ្រប់គ្រាន់ទៅលើភាពជឿជាក់ ឬស្តារឡើងវិញនូវសក្ខីកម្មរបស់លោកនោះទេ ។ ប្រសិនបើក្រឡេកទៅក្រោយវិញ វិសាលភាពនៃសក្ខីកម្មរបស់លោកវេជ្ជបណ្ឌិត គួរតែមានភាពប្រសើរជាងនេះ ហើយមេធាវីគួរតែអាចប្រើប្រាស់ការត្រួតពិនិត្យ ដែលត្រូវបានបង្កើតឡើងទៅលើផលប៉ះពាល់របស់របបខ្មែរក្រហមទៅលើសុខភាពផ្លូវចិត្តនៅក្នុងប្រទេសកម្ពុជា ។

ដើម្បីគោរព និងបញ្ចូលការឈឺចាប់ផ្នែកផ្លូវចិត្តរបស់ជនរងគ្រោះនៅក្នុងការស្វែងរកយុត្តិធម៌ នៅតុលាការអន្តរជាតិ មេធាវីគួរទទួលការបណ្តុះបណ្តាលដើម្បីសាកសួរគ្រូពេទ្យចិត្តសាស្ត្រជំនាញ និងគ្រូពេទ្យគ្លីនីកប្រកបដោយប្រសិទ្ធភាព និងដឹងអំពីភាសាខាងចិត្តសាស្ត្រ និងផ្លូវចិត្ត ដើម្បីប្រើប្រាស់ចំណេះដឹងរបស់អ្នកជំនាញឲ្យបានប្រសើរជាងមុន ។ មេធាវីគួរទទួលបានការអប់រំដើម្បីបង្កើតនូវការជឿទុកចិត្តរបស់អ្នកជំនាញនិងជួយស្តារសក្ខីកម្មរបស់អ្នកជំនាញនៅពេលសក្ខីកម្មនោះមានលក្ខណៈច្របូកច្របល់ ឬទន់ខ្សោយ ។ សាក្សីជំនាញ ជាពិសេសអ្នកដែលមិនមានបទពិសោធន៍នៅក្នុងតុលាការ គួរតែត្រូវបានអនុញ្ញាតមានការជួបប្រជុំទទួលព័ត៌មាន ឬការជួបប្រជុំជាមួយក្រុមមេធាវីទាក់ទងនឹងសំណួរទូទៅ ។ បន្ថែមពីនេះទៀត ក្រុមអ្នកបកប្រែនៅតាមតុលាការអន្តរជាតិគួរតែសិក្សាពាក្យបច្ចេកទេសខាងចិត្តសាស្ត្រ និងផ្លូវចិត្ត ដើម្បីឲ្យមានការទំនាក់ទំនងប្រសើរជាងមុន នៅពេលមានសវនាការពីអ្នកជំនាញសុខភាពផ្លូវចិត្ត ។ ការអប់រំជាមូលដ្ឋានស្តីពីសុខភាពផ្លូវចិត្តនិងចិត្តសាស្ត្រពីចៅក្រម និងមេធាវីតុលាការនឹងជួយសម្រួលដល់ការស្វែងយល់ពីសក្ខីកម្មជំនាញខាងសុខភាពផ្លូវចិត្ត ។

ការចោទសួររបស់តុលាការទៅលើដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី បេ សុផានី និងសាក្សីជំនាញ វេជ្ជបណ្ឌិត ឈឹម សុធារ៉ា បានបង្ហាញថា ខណៈដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបោះជំហានដ៏សំខាន់មួយក្នុងការទទួលស្គាល់សុខភាពផ្លូវចិត្តរបស់ជនរងគ្រោះ មានចំណុចជាច្រើនដែលត្រូវកែលម្អក្នុងការដោះស្រាយចំពោះតម្លៃនៃសហគមន៍ចិត្តសាស្ត្រចំពោះសហគមន៍យុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិ ។ វាជាកិច្ចការសំខាន់សម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិក្នុងការទទួលស្គាល់ចំពោះការកើនឡើងយ៉ាងខ្លាំងនៃការរីករាលដាលនៃបញ្ហាវិបត្តិផ្លូវចិត្តនៅក្នុងសង្គមក្រោយជម្លោះ និងឥទ្ធិពលយ៉ាងធំធេង ដែលស្ថិតិលម្អៀងមានទៅលើបុគ្គល និងតួនាទីរបស់សង្គម ។ ដើម្បីបញ្ចូលការឈឺចាប់ផ្នែកចិត្តសាស្ត្រ នៅក្នុងការស្វែងរកយុត្តិធម៌ តុលាការឧក្រិដ្ឋកម្មអន្តរជាតិត្រូវតែធ្វើឲ្យប្រសើរឡើងនូវជំនាញរបស់បុគ្គលិកតុលាការ និងដំណើរការទាំងឡាយនៅក្នុងអំឡុងពេលផ្តល់សក្ខីកម្មរបស់អ្នកជំនាញនៅក្នុងបញ្ហាសុខភាពផ្លូវចិត្ត ។ **គីម យ៉ុងហ៊ី**

# ទណ្ឌិតផ្លែល្ពៅ



រូបគំនូរដោយអ្នកនិពន្ធ ឆាយ ស៊ូឆាត្រ

**(តពីលេខមុន)**

**៧) បញ្ញាវន្តអធន**

អស់រយៈពេលប្រាំពីរថ្ងៃយើងទាំងអស់មកដល់វត្តខ្ទុង ពពក ។ មនុស្សម្នាជាច្រើនកកកុញនៅទីនេះ ។ ទីនេះជាវត្តបុរាណ ព្រោះមានក្បូរក្បាច់រចនាដ៏ល្អវិចិត្រ លាបលនដោយពណ៌យ៉ាង ស្រស់ ។ អ្វីដែលវិសេសនោះ គឺសំណង់ព្រះវិហារមានពីរជាន់ ជាការស្តែងឲ្យឃើញថា អ្នកស្រុកជីវភាពធូរធារនិងចេះដឹងខ្លាំង ណាស់ ។ ថ្វីត្បិតតែស្ថិតនៅចម្ងាយជាងសាមសិបគីឡូម៉ែត្រពីក្រុង កំពង់ឆ្នាំងក្តី តែវាហាក់នៅឆ្ងាយសែនឆ្ងាយណាស់ ។ ខ្ញុំធ្លាប់តែឮ ឈ្មោះស្រុកនេះតាំងនៅវ័យកុមារ ហើយល្បីថាអង្ករនៅខ្ទុងពពក ដាំបាយឆ្ងាញ់ណាស់ ឥឡូវនេះខ្ញុំបានមកដល់ក៏បានប្រាកដក្នុងចិត្ត ថាស្រុកនេះពិតជាល្បីមែន ។ អំឡុងសង្គ្រាមស៊ីវិលមុនរបបខ្មែរ ក្រហម ស្រុកនេះស្ថិតនៅក្នុងតំបន់រំដោះ ម៉្លោះហើយអ្នកស្រុកភាគ ច្រើនបានក្លាយទៅជាយុទ្ធជនបដិវត្តន៍របស់រណសិរ្សរំដោះជាតិ កម្ពុជា ក្រោមការដឹកនាំរបស់សម្តេចឪ ។ មានតែមួយភាគតូច ប៉ុណ្ណោះដែលបានចេញទៅរស់នៅតំបន់ដែលគ្រប់គ្រងដោយរបប

សាធារណរដ្ឋខ្មែរដែលដឹកនាំដោយ លន់ នល់ ។ អនិច្ចា វត្តដីមានសោភ័ណភាពអស្ចារ្យបានក្លាយទៅជាជង្រុកស្រូវរបស់រណសិរ្សរំដោះជាតិកម្ពុជា ។ យើងពុំបានឃើញវត្តមានព្រះសង្ឃនៅក្នុងវត្តនេះទេ ។ ក្នុងបរិវេណវត្ត យោធាខ្មែរក្រហមកាន់អាវុធត្រៀបត្រាដើរចុះដើរឡើង ។ ខ្មែរក្រហមបានប្រើប្រាស់កុដិមួយដើម្បីជាទីស្នាក់ការ ។

ក្នុងបរិវេណវត្តមានរថយន្តតូចធំពាសវាលពាសកាលភាគច្រើនជាគ្រួសារមន្ត្រីរាជការ ភ្នំពេញ ពាណិជ្ជករ នាយទាហាន សិស្សនិស្សិតដែលខ្លះមកពីកំពង់ឆ្នាំង ភ្នំពេញនិងស្រុកនានា ។ នៅតាមកុដិនានា យើងឃើញមានទាហានរបួស ពិការ ដេករណ្ដូករណែលខ្លះដាច់ដៃ ដាច់ជើង គ្មានថ្នាំព្យាបាល គ្មានគ្រូពេទ្យ មុខរបួសធំក្លិនស្អុយ ។ យើងក៏ឃើញមេដឹកនាំខ្មែរក្រហមជិះរថយន្តហ្ស៊ីបដែលរឹបអូសយកបានពីកងទ័ព លន់ នល់ បើកចេញចូលជាបន្តតដាច់ ។ នៅទីនោះ ខ្ញុំបានជួបមិត្តភក្តិជាច្រើនដែលធ្លាប់រៀនជាមួយកាលនោះនៅវិទ្យាល័យព្រះសុរាម្រិត ។ ខ្ញុំបានជួប សុខ មេត្រី ជាកូនលោក សុខ ហេង អធិការបឋមសិក្សាដែលរៀននៅមហាវិទ្យាល័យវេជ្ជសាស្ត្រភ្នំពេញ ។ សុខ មេត្រី បានសួររកឪពុករបស់ខ្លួន ហើយខ្ញុំក៏បានប្រាប់ថា បានឃើញគាត់បើកឡានឡើងទៅលើជាមួយក្រុមគ្រួសារហើយ ។ បន្ទាប់មក ខ្ញុំជួប ជួន លីសុផល, ឈៀង ចំរើន, ជា ប៊ុនប៉ា ដែលជានិស្សិតនៅមហាវិទ្យាល័យពហុបច្ចេកទេស និងមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ។

ខណៈនោះដែរ ខ្ញុំក៏បានជួបដុកទ័រ ព្រាំ ជុនស្រេង និង គុង យៀ ដែលម្នាក់ៗមានសម្លៀកបំពាក់ប្រឡាក់ពក្អក់ ដៃកាន់ឆ្នាំងបាយ រីឯរថយន្តរបស់គាត់អស់សាំងលែងទៅមុខរួចហើយ ។ ដុកទ័រ ស្រេង បីកូនស្រីម្នាក់នៅនឹងដៃដែលនាងមានជំងឺគ្រុនក្តៅ រីឯសាស្ត្រាចារ្យ យី លឹមហេង ដៃកាន់ឆ្នាំងបាយកញ្ចាស់មួយ ។ គួរឲ្យអនិច្ចាបញ្ញវន្តដែលមានការចេះដឹងធ្វើការក្នុងម៉ាស៊ីនត្រជាក់ពាក់វ៉ែនតាពណ៌ស ពាក់អាវដាក់ក្រវ៉ាត់ក ចេញទៅណាមកណាមានអ្នកគោរពដូចព្រះអង្គម្ចាស់ តែឥឡូវមើលទៅដូចជាមនុស្សសុំទានមានឡាន តែឥតសាំងចាក់ក្នុងឡានមានតែលុយតែចាយពុំបាន មើលទៅដូចមនុស្សវិកលចរិត ។

មើលចុះក្នុងរថយន្តម៉ាស៊ីដេសរបស់គាត់មានតែលុយ និងមាស ពេជ្រ សូម្បីតែថ្នាំមួយគ្រាប់សម្រាប់កូនស្រីក៏គ្មានផង ចំណែកលោកសាស្ត្រាចារ្យក៏ពុំបានយកអង្ករមកជាមួយ បានកាន់ឆ្នាំងដើម្បីសុំអង្ករពីក្រុមយុទ្ធជនដែលកំពុងមមាញឹកនៅឯកុដិមួយ ។ យើងសម្រាកនៅទីនោះបួនថ្ងៃ ។ ដោយពុំមានអង្ករ បងថ្លៃស្រីរបស់ខ្ញុំឈ្មោះ ដានី និង ស៊ីថា បានយកចិញ្ចៀនមាសទៅដូរបានអង្ករនិងអំបិលខ្លះក៏ប៉ុន្តែបរិមាណតិចតួចពុំអាចដាំបាយក៏ត្រូវបង្ខំចិត្តដាំបបរលាយជាមួយត្រកួន ។ ទោះបីយ៉ាងនេះក្តី ក៏ក្មេងៗពុំព្រមហូបដដែលក្នុងនោះមានក្មេងៗអាយុពី៦-៨ឆ្នាំបីនាក់ធ្លាក់ខ្លួនឈឺងើបពុំរួច ។ នៅថ្ងៃទីប្រាំ ខ្មែរក្រហមម្នាក់ជិះម៉ូតូហុងដាយ៉ាងសង្ហាអមដោយនីរសារពីរនាក់បានបង្ហាញខ្លួននៅស្នាក់ការកុដិ ។ វេលាម៉ោងប្រាំបួនព្រឹក មានការអំពាវនាវដោយសំឡេងមួយៗច្បាស់ៗថា ពុកម៉ែបងប្អូនទាំងអស់ នេះជាសាររបស់អង្គការបដិវត្តន៍ថ្នាក់លើ សូមបងប្អូនពុកម៉ែទាំងអស់អញ្ជើញមកចុះឈ្មោះនៅទីនេះ បងប្អូនដែលជាអ្នករាជការ បញ្ញវន្ត គ្រូបង្រៀន អញ្ជើញមកចុះឈ្មោះមុនគេ ព្រោះអង្គការបដិវត្តន៍ត្រូវការអ្នកចេះដឹងដើម្បីឲ្យទៅបម្រើការកសាងប្រទេសជាតិឡើងវិញ ។ សូមបងប្អូនពុកម៉ែកុំលាក់លៀម អ្នកណាធ្លាប់ធ្វើអ្វី សូមរាយការណ៍ដោយស្មោះត្រង់នឹងបានធ្វើនោះវិញដូចដើម ។ អង្គការបដិវត្តន៍ត្រូវការអ្នកបញ្ញវន្តដើម្បីស្តាបនាជាតិ ព្រោះបងប្អូនទាំងសុទ្ធអស់ជាបញ្ញវន្ត អធនអ្នកណាចុះឈ្មោះមុននឹងបានចេញដំណើរមុន ។

ទោះជាសាមសិបប្រាំពីរឆ្នាំកន្លងទៅហើយក៏ដោយ ខ្ញុំនៅតែចាំរូបភាពបុរសម្នាក់នេះឈ្មោះថា តា សារុន ជាគណៈស្រុកទឹកផុសដែលបន្ទាប់មកជាតំបន់៣១កំពង់ឆ្នាំង ។ បន្ទាប់ពីការប្រកាសរបស់ តា សារុន មក មានមន្ត្រីរាជការជាច្រើននាក់បានទៅចុះឈ្មោះដើម្បីឆាប់បានចេញដំណើរ ។ ខ្ញុំសង្កេតឃើញថា ដុកទ័រ ព្រាំ ជុនស្រេង, នាយកវិទ្យាល័យព្រះបាទសុរាម្រិត យឹម, អ៊ឹមារិន ព្រមទាំងសាស្ត្រាចារ្យជាច្រើននាក់បានចុះឈ្មោះ ហើយចាកចេញពីវត្តខ្ពង់ពកជាបន្តបន្ទាប់ ។ អ្នកទាំងនោះបានបោះចោលរថយន្ត ម៉ូតូ និងសម្ភារជាច្រើននៅទីនោះ ។

នៅថ្ងៃបន្ទាប់ តាសារុន បានធ្វើការប្រកាសសាជាថ្មីដល់អតីតទាហាន រដ្ឋការ លន់ នល់ ឲ្យមកចុះឈ្មោះដើម្បីចេញដំណើរ ។ សារុន បានបញ្ជាក់ផង ចំពោះបងប្អូនដែលធ្លាប់កាន់អាវុធ ជាទាហានក្តីជាកងកុម្ម៉ង់ដូក្តី ជាសេនាជន ឬមេដប់ខ្ទង់ ឬមេហាសិបខ្ទង់ក្តី សូម

អញ្ជើញមកចុះឈ្មោះឲ្យរួសរាន់ ព្រោះអង្គការបដិវត្តន៍ត្រូវការអ្នកដែលមានបទពិសោធដើម្បីការពារជាតិ អ្នកពាក់ស័ក្តិប៉ុន្មាន និងត្រូវរក្សាឲ្យនៅដដែលឬអាចតម្លើងស័ក្តិឲ្យធំជាងមុនទៀត អ្នកណាចុះឈ្មោះមុន នឹងត្រូវបានទៅរៀនសូត្រមុន ហើយបានការងារធ្វើមុន ។

ម្តងនេះមហាជនមានការចាប់អារម្មណ៍ខ្លាំងជាងមុន មានគ្រួសារទាហានរដ្ឋការ លន់ នល់ ទាំងហ្វូងបានមកចុះឈ្មោះ អ្នកខ្លះពាក់ស័ក្តិមួយ ក៏មកចុះឈ្មោះថា ពាក់ស័ក្តិពីរ ស័ក្តិបី ដើម្បីឲ្យឆាប់បានចេញព្រោះនៅទីនោះគ្មានអង្ករ ត្រីសាច់ ឯលុយក៏ពុំចាយ ត្រូវតែរកមធ្យោបាយឆាប់បានចេញ ។ រយៈពេលតែមួយថ្ងៃ អ្នករដ្ឋការ លន់ នល់ និងអតីតទាហានបានចាកចេញយ៉ាងច្រើនពីវត្តខ្ទុំពពក ។

ដោយទ្រាំនឹងភាពលំបាកនៅវត្តខ្ទុំពពកយូរពេក ខ្ញុំក៏បានជួបពិភាក្សាជាមួយឪពុកខ្ញុំ ព្រមទាំងបងស្រីមានបំណងនឹងចុះឈ្មោះជាគ្រួសារទាហានដែរ ក៏ប៉ុន្តែគាត់បានជួបជាមួយប្អូនជីដូនមួយរបស់គាត់ម្នាក់ជាយុទ្ធជនឈ្មោះ ណៃម ។ បន្ទាប់ពីសួរយោបល់ពូណៃម អំពីរឿងនោះ ពូណៃម ហាក់បីដូចជាស្ទាក់ស្ទើរពុំហ៊ាននិយាយស្តីឲ្យចំ ។

ពូណៃម បានប្រាប់ពុកថា សូមកុំឲ្យគាត់ចុះឈ្មោះទៅជាមួយអ្នករដ្ឋការ និងទាហានឲ្យសោះ ។ និយាយតែប៉ុណ្ណោះ គាត់ក៏បានចាកចេញពីយើងបាត់ទៅ ។ នៅថ្ងៃបន្ទាប់ យើងក៏បានជួបគ្រួសាររបស់កូវអី ត្រូវជាភាសាចិនប្រែថា មីងខាងឪពុក ។ កូវមានបងប្អូនបួននាក់ ព្រមទាំងចៅៗជាច្រើននាក់ ។ គាត់បានចេញពីកំពង់ឆ្នាំង ដោយរថយន្តកាមីញ៉ុងទាំងអស់មានគ្នា២៦នាក់ ។ នៅលើរថយន្តមានគ្រឿងឧបភោគបរិភោគគ្រប់មុខ ។ កូវអ៊ី បានមកហៅពុកឲ្យចុះឈ្មោះទៅជាមួយគ្រួសារគាត់ តែពូណៃម ក៏បានមកប្រាប់ពុកថា កុំឲ្យទៅតាមគ្រួសារគាត់ឲ្យសោះ ។ ទីបំផុតយុទ្ធជនម្នាក់ដែលមុនសង្គ្រាមស៊ីវិលធ្លាប់ធ្វើជាកម្មកររបស់កូវអ៊ី បានមកសុំដល់តាសារុន ក៏យល់ព្រមទុកតែ កូវអ៊ី ម្នាក់ឯង ។ គាត់ពុំសុខចិត្តក៏ទាមទារទៅជាមួយកូនចៅដោយពុំបានដឹងថាដំណើរនេះគឺជាដំណើរទៅកាន់មរណភាពសោះឡើយ ។

ឥឡូវនេះ អ្នករដ្ឋការ បញ្ញវន្ត ទាហាន និងអ្នកមានបានចាកចេញអស់ទៅហើយ នៅសល់តែប្រជាជនធម្មតា អ្នកជំនួញមធ្យម និងអ្នកស្រែចម្ការដែលកំពុងរង់ចាំការចាកចេញដំណើរជាបន្តបន្ទាប់ ។ ក្នុងនោះមានគ្រួសារគ្រូបង្រៀន សាស្ត្រាចារ្យ ពេទ្យខ្លះដែលពុំសូវទុកចិត្ត មិនបានចុះឈ្មោះ ហើយក៏មានគ្រួសារខ្ញុំដែលជាគ្រួសារទាហានដែរ ។

## ៨) កម្មាភិបាល

ឥឡូវនេះដល់វេនយើងហើយ ។ តាសារុន បានប្រកាសតាមមេក្រូ ចំពោះ ពុកម៉ែ បងប្អូនដែលជាប្រជាជនធម្មតាសូមរៀបចំខ្លួនដើម្បីចាកចេញដំណើរ ។ សូមពុកម៉ែ បងប្អូន រៀបចំជាក្រុម ក្នុងមួយក្រុម ហាសិបគ្រួសារ ដើម្បីរង់ចាំបន្តិចទៀត នឹងមានកម្មាភិបាលចុះមកទទួលដែលខ្ញុំបានឮពាក្យកម្មាភិបាល ខ្ញុំមិនទាន់យល់អំពីពាក្យនេះនៅឡើយ ប៉ុន្តែខ្ញុំហាក់បីដូចជាយល់ថាគឺជាបុគ្គលអ្នកដែលមានឋានៈធំដុំ ក្នុងជួរខ្មែរក្រហមជាមិនខាន យើងមិនបានបបួលគ្រួសារជាច្រើនទៀតដែលយើងពុំធ្លាប់ស្គាល់ដើម្បីចងក្រងជាក្រុមដែលមានហាសិបគ្រួសារក្នុងនោះមាន ខ្លះជាគ្រូបង្រៀន ពេទ្យ ទាហាន ពាណិជ្ជករ ។ អ្នកខ្លះមកពីភ្នំពេញ កំពង់ឆ្នាំង និងពីស្រុកដទៃទៀត ។ ខ្ញុំអន្ទះសារចង់ស្គាល់កម្មាភិបាលដែលមកទទួលយើង ។

មុននៃការមកដល់ ខ្ញុំស្រមៃថាគិតថា កម្មាភិបាលប្រាកដជាបញ្ញវន្តដែលមានការចេះដឹងថ្នាក់មហាវិទ្យាល័យដែលបានចូលព្រៃម៉ាកគី ចូលរួមចលនា សីហនុ និយម ប្រឆាំងរដ្ឋការ លន់ នល់ ពុករលួយ ខ្ញុំរំពឹងទុកបន្ថែមទៀតថា កម្មាភិបាលប្រហែលជាស្លៀកខោបារាំង ពាក់អាវស ដាក់ក្រវ៉ាត់ក និងជិះរថយន្តហ្ស៊ីប មកទទួលយើងទៅកាន់តំបន់រំដោះ ក៏ប៉ុន្តែនៅពេលមកដល់គឺជាយុទ្ធជន ដូចដែលយើងធ្លាប់ឃើញរួចមកហើយ ។ គាត់ប្រាប់ថាគាត់ឈ្មោះ សមមិត្ត សឿន ឬអាចហៅគាត់ថា មិត្តសឿន អាយុប្រហែល ៣៥ឆ្នាំ ។ នៅពីក្រោយគាត់មាននីរសារពីរនាក់ ដែលមានអាយុប្រហែល១៥ - ១៧ឆ្នាំ ។ កំពុងតែស្ងួងទៅក្នុងអារម្មណ៍អណ្តែតអណ្តូងដែលរលាយបាត់ទៅហើយនោះ ស្រាប់តែខ្ញុំភ្ញាក់ព្រើតដោយសំឡេងដ៏មុតស្រួចរបស់មិត្ត សឿន ។

ពុកម៉ែ បងប្អូន ទាំងអស់គ្នាចេញដំណើរគឺជាពាក្យសម្តីដែលពោរពេញដោយភាពម៉ឺងម៉ាត់ និងអំណាច ។ មិត្ត សឿន ឡើងជិះកង់ យើងទាំងអស់គ្នាក្រោកឈរស្តាយទូលអូសរទេះតាមផ្លូវលេខ៥៣

ទៅលិចកាត់ស្ពានចាត្រង់ ។ មិត្តសឿន ជិះកង់ទៅមុខប្រហែលមួយគីឡូម៉ែត្រទើបឈរចាំយើង ឯនីរសារពីរនាក់ស្ពាយកាំភ្លើងជិះតាមយើងពីក្រោយ ។ គាត់បានប្រាប់យើងថា ប្រហែលជាបីម៉ោងដល់សហករណ៍ ។ ពូតែពាក្យថា "សហករណ៍" ខ្ញុំគិតថាជាអគារសង់ពីបេតុងអាម៉េប្រក់គ្រឿងមានអគារលក់ដូរផលិតផលដែលប្រជាជនផលិតបានក្នុងចិត្តខ្ញុំនៅមានក្តីសង្ឃឹមលើរណសិរ្សរំដោះជាតិ លើសម្តេចឪ ព្រះនរោត្តម សីហនុ ។

មកដល់ផ្ទះវត្តដីរស ក្បួនដំណើររបស់យើងបានបត់ទៅខាងស្តាំ ។ ខ្ញុំមិនដឹងថាមានចម្ងាយប៉ុន្មានគីឡូម៉ែត្រនោះទេ តែវាហាក់ដូចជាឆ្ងាយណាស់ មិនដូចជាយើងបើកឡានសព្វថ្ងៃនេះទេ ផ្លូវដែលដើរគឺជាផ្លូវដីសម្រាប់រទេះគោក្របី ។ ដោយសារយើងស្ពាយស្បៀងឥវ៉ាន់សំពីងសំពោងនេះ វាដូចជាកាន់តែឆ្ងាយទៅៗ ទីបំផុតក៏បានមកដល់ភូមិចាស់បុរាណមួយយើងមានផ្ទះឈើបុរាណធំៗ មានដើមត្នោត ដើមឈើហូបផ្លែ និងមានខ្ទមស្លឹកតូចៗជាច្រើនទៀតដែរ ។

វេលាម៉ោងបួនរសៀល យើងបានមកដល់មុខអគារមួយសង់ពីឈើប្រក់ស្បូវ មិត្តសឿន បានឈប់កង់នៅពីមុខអគារនោះ ហើយប្រាប់យើងថា យើងមកដល់សហករណ៍កោះកណ្តាលហើយ ។ តាមពិតពាក្យថា "សហករណ៍" ពុំមែនជាអ្វីដែលខ្ញុំគិតនោះទេ ។ វាជាអង្គការចាត់តាំងរបស់រណសិរ្សរំដោះជាតិកម្ពុជាដែលកាលនោះមានតែឈ្មោះតែប៉ុណ្ណោះ រីឯអគាររបស់សហករណ៍កាលនោះគឺជាកូនផ្ទះយ៉ាងសាមញ្ញមួយប្រក់ស្បូវគ្មានជញ្ជាំង និងមានតុឈើពីរនិងកៅអីធ្វើពីក្តារមួយបន្ទះ ។ នៅទីនោះ មានសមមិត្តម្នាក់ស្លៀកពាក់ពណ៌ខ្មៅបង់កក្រមា កាន់កាំភ្លើងអាកា ដែលក្រោយមកខ្ញុំស្គាល់ថា ជាកងឈ្លប ។ ទីនេះមានរបៀបរៀបរយស្អាតបាត ប៉ុន្តែខុសទាំងស្រុងពីការសន្និដ្ឋានរបស់ខ្ញុំ ព្រោះវាគ្មានសង្ហារឹមអ្វីសោះ ។

## ៩) អង្គការថ្នាក់លើ

កោះកណ្តាលពុំមែនជាតំបន់ដាច់ស្រយាលព្រៃផ្សៃនោះទេ គឺជាភូមិមួយដែលកាលជំនាន់សង្គមរាស្ត្រនិយម អ្នកស្រុកមានជីវភាពធូរធារ ព្រោះអំណោយផលពីធម្មតាជាតិ ដីមានជីជាតិ ធ្វើឲ្យផលស្រែចម្ការបានផលល្អ ។ បើគិតចម្ងាយពីកំពង់ឆ្នាំងប្រហែលជាហាសិបគីឡូម៉ែត្រ អ្នកស្រុកគោរពព្រះពុទ្ធសាសនា ។ ភូមិនេះស្ថិតក្នុងឃុំជៀប ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ក៏ប៉ុន្តែកាលនោះគឺខែមេសា ឆ្នាំ១៩៧៥ សីលធម៌របស់អ្នកស្រុកនោះពុំដឹងជាបាត់ទៅណាអស់ ។

មកដល់មុខស្នាក់ការសហករណ៍ ខ្ញុំសង្កេតឃើញថា យើងមានគ្នាប្រហែលជាហាសិបគ្រួសារទាំងក្មេងទាំងចាស់ ប្រហែលជាងពីររយនាក់ ។ យើងមានការនឿយហត់ខ្លាំងណាស់ ព្រោះដំណើរធ្វើរដើងដោយរែកសែងព្រមទាំងត្រូវបីពកូនតូច ។ ខ្ញុំនឹកសង្ឃឹមថា មកដល់សហករណ៍ច្បាស់ជាត្រូវបាន ទទួលបាយទឹក កាប់គោ ជ្រូក ទទួលមិនខាន និងត្រូវបានសម្រាកយ៉ាងស្រួលហើយប្រហែលត្រូវបានអនុញ្ញាតឲ្យទៅផ្ទះវិញ ។ ក៏ប៉ុន្តែភ្លាមនោះ មិត្ត សឿន បានឲ្យយើងមកអង្គុយជុំវិញគាត់ ដើម្បីប្រជុំជីវភាព ពេលនេះ ខ្ញុំហាក់បានដឹងខ្លួនថា បានរៀនសូត្រនូវពាក្យថ្មីៗដែលខ្ញុំមិនដែលបានឮទៀតហើយ ។ យើងអង្គុយជុំវិញ ជួនជាព្រលប់មកដល់ ទាំងអស់គ្នាហេវហត់ដោយការធ្វើការដំណើរ និងឃ្លានអាហារទាំងចាស់ជរាទាំងកូនក្មេងត្រូវអង្គការឲ្យមកស្តាប់ មិត្តសឿន និយាយតាំងពីព្រលប់រហូតដល់ម៉ោង១២យប់ ។ ក្មេងៗដេកលក់ទាំងអត់អាហារ ឯមនុស្សជរា ទាំងមានជំងឺក៏ត្រូវអង្គុយហាលសន្សើមក្រោមពន្លឺចន្ទ ។ មិត្ត សឿន និយាយវែងណាស់ ។ គាត់រៀបរាប់ពីប្រវត្តិតស៊ូរបស់បដិវត្តន៍វណ្ណៈអធន ប្រឆាំងចក្រពត្តិអាមេរិក និងអាយ៉ង លន់ នល់ ក្រោមការដឹកនាំរបស់អង្គការបដិវត្តន៍ដ៏ភ្លឺស្វាង មហាលោតផ្លោះ មហាអស្ចារ្យ ។ ពាក្យសម្តីរបស់មិត្ត សឿន ពោរពេញទៅដោយកំហឹងរបស់កសិករ កម្មករ ហើយអ្វីដែលខ្ញុំចាំជាងគេនោះ គឺការដឹកនាំរបស់អង្គការថ្នាក់លើ ។ រហូតមកដល់ពាក់កណ្តាលអាធ្រាត្រ ទើបការប្រជុំចប់ហើយបានអនុញ្ញាតឲ្យរំសាយ យប់នោះខ្ញុំបានសុំផ្ទះអ្នកស្រុកម្នាក់សម្រាកដោយម្តាយនិងក្មួយៗខ្ញុំផ្អាក់ខ្លួនឈឺជាខ្លាំង ។

## ១០) កម្មសិទ្ធិសមរម្យគឺស្បៀងមួយតូច

ព្រឹកឡើងបងស្រី និងបងថ្លៃស្រី ខ្ញុំពីរនាក់ទៀតបានយកខ្សែកមួយតម្លឹងយកទៅដូរម្ចាស់ផ្ទះ បានអង្ករសាមសិបកំប៉ុងប្រហែលប្រាំបីគីឡូយកមកដាំបាយឲ្យទាំងអស់គ្នាហូប ។ ខ្សែកនេះបើគិតតម្លៃយើងអាចទិញបានអង្ករបួនតោន ឬមួយឡានកាមីញ៉ុងក៏ប៉ុន្តែពេលនេះ យើងគ្មានជម្រើសទៀតទេ ។ ម្តាយខ្ញុំផ្អាក់ខ្លួនគ្រុនញាក់ដែលសម័យនោះហៅថា គ្រុនចាញ់ ។ គាត់ទទួលអាហារបានតិចតួច យើងក៏យកបន្តោងពេជ្រមួយទៅដូរបានអំបិលមួយកំប៉ុង ។

យើងគ្មានសាច់ ឬត្រីអ្វីទេចំពោះ គ្រួសារដទៃដែលជាអ្នកស្រែធ្លាប់ដឹកក្តាម កង្កែប ចំពោះយើងគ្មាននរណាម្នាក់ចេះរកក្តាម កង្កែបឡើយ ។ ដូច្នេះមានតែស្ងោរស្លឹកអំពិលចាស់ៗដាក់អំបិលបរិភោគជាមួយបាយ ។ មិនទាន់បរិភោគបាយស្រួលបួលផង ស្រាប់តែមានសមមិត្តជំទង់ៗពីរនាក់ប្រដាប់ដោយអាវុធបានមកជួបយើងដើម្បីស្នើត្រួតពិនិត្យកម្មសិទ្ធិ ដោយបានប្រាប់យើងថា អង្គការលើបានដំណឹងថាមាន សេ.អ៊ី.អា បានលាក់ខ្លួនក្នុងចំណោមយើងទាំងអស់គ្នា ដូចច្នេះ ដើម្បីការពារសណ្តាប់ធ្នាប់ និងប្រជាជនឲ្យបានល្អ អង្គការថ្នាក់លើមានគោលការណ៍ឆែកឆេរគ្រប់ទាំងអ្នកជម្លៀសទាំងអស់ ក្រែងមានលាក់កាំភ្លើង ឬក៏គេអូសម្រាប់ហៅខ្មាំងអាមេរិកឲ្យមកទម្លាក់គ្រាប់បែកអាស្រ័យហេតុនេះសូមពុកម៉ែបងប្អូនកុំលាក់អ្វីឲ្យសោះ ធ្វើយ៉ាងនេះទើបក្លាយជាជនបដិវត្តន៍ ។

សមមិត្តទាំងពីរបង្គាប់ឲ្យយើងយកសំពាយមកម្នាក់ម្តងៗ ដើម្បីត្រួតពិនិត្យ ។ បងស្រីខ្ញុំ ប៊ុនណាយ និងបងថ្លៃទាំងពីរ ផានី និង ស៊ីថា បានយកសំពាយរបស់គាត់មកស្រាយនៅលើដើមបង្ហាញសមមិត្ត ។ សមមិត្តពិនិត្យយឺតៗលើបង្ខិចសម្លៀកបំពាក់ ហើយចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះនាឡិកាដែលផលិតនៅប្រទេសជប៉ុន ក៏មិនចាប់អារម្មណ៍លើសំពត់ខោអាវថ្មីទេ ឯចំណែកការ៉ុងដាក់លុយថ្មីទាំងនោះ ក៏ពុំយកភ្នែកមើលសោះឡើយ គឺអង្អែលតែនាឡិការបស់បង ផានី ដែលប្តីគាត់បានទទួលបញ្ចាំពីកូនទាហាន មុនថ្ងៃ១៧ មេសា ។ សមមិត្តដែលរាងធាត់អាយុប្រហែល១៧ឆ្នាំ បានសួរទៅកាន់បងផានី ។

តាមគោលការណ៍របស់អង្គការថ្នាក់លើ ប្រជាជនថ្មីពុំមានសិទ្ធិពាក់នាឡិកា ខ្ញុំត្រូវដកហូតនាឡិកានេះ ប៉ុន្តែ ខ្ញុំអាណិតមិត្តឯងចង់ប្តូរនាឡិកានេះ នឹងអង្ករហាសិបកំប៉ុងបានទេ? ឮតែអង្ករហាសិបកំប៉ុង បងផានី ស្ទើរហោះផុតពីដី ។ ចាស៎! មិត្តប្អូន សុំយកនាឡិកានេះចុះ ខ្ញុំត្រូវការអង្ករសម្រាប់កូន និងប្អូនទាំងអស់ ។ សមមិត្តបានដកហូតវិទ្យុ ម៉ាស៊ីនថតរូប តែបានផ្តល់អង្ករដែលប្តូរជាមួយនាឡិកាមកយើងវិញ ។ មិត្តទាំងពីរបានយកអង្ករមកឲ្យយើងនៅពេលយប់ស្ងាត់ហើយផ្តាំមិនឲ្យនិយាយប្រាប់នរណាឲ្យសោះ ។ សំណាងល្អ បងស្រីខ្ញុំ ប៊ុនណាយ និងបងថ្លៃទាំងពីរបានលាក់ទុកមាសពេជ្រនៅក្នុងអាវទ្រនាប់របស់គាត់ ។

មុននឹងចេញ សមមិត្តទាំងពីរបាននិយាយប្រាប់យើងថា បដិវត្តន៍វណ្ណៈអធន ត្រូវបំបាត់អ្នកមាន នាយទុនប្រតិកិរិយា សក្តិភូមិ ដោយមិនត្រូវមានអ្នកមាន អ្នកក្រទៀតទេ យើងត្រូវតែរស់នៅស្មើភាពគ្នាបំបាត់កម្មសិទ្ធិឯកជនជនបដិវត្តន៍ត្រូវតែមានកម្មសិទ្ធិសមរម្យគឺស្បោងមួយតូច ។ ខ្ញុំចាំពាក្យនេះរហូតដល់សព្វថ្ងៃ វាមានន័យជ្រាលជ្រៅដល់បដិវត្តន៍វណ្ណៈដែលឈានទៅដល់វិនាសកម្មដ៏ធំធេងដោយសារតែទ្រឹស្តីនេះ ។

## ១១) កង់ប្រវត្តិសាស្ត្រ

ម្តាយខ្ញុំបានធ្លាក់ខ្លួនឈឺកាន់តែធ្ងន់ឡើង ឯក្មួយតូចៗក៏កាន់តែមានសភាពធ្ងន់ធ្ងរដែរ ។ យើងដេកក្រោមផ្ទះអ្នកមូលដ្ឋានចាស់ដែលពុំហ៊ាននិយាយអ្វីជាមួយយើងឡើយ ។ បើយើងសួរមួយម៉ាត់ក៏ឆ្លើយមួយម៉ាត់និយាយឲ្យចំគឺអ្នកទាំងនោះព្យាយាមគេចពីយើង ។ ម្ចាស់ផ្ទះដែលយើងស្នាក់នៅទីនោះឈ្មោះ តាស្រី អាយុប្រមាណ៦០ឆ្នាំ ។ កាលជំនាន់បារាំង គាត់ធ្វើជាទាហានជើងខ្មៅ ។ ពុកខ្ញុំស្គាល់ តាស្រី ច្បាស់ណាស់ព្រោះធ្លាប់ធ្វើទាហានជាមួយគ្នា ដោយព្រោះហេតុដូច្នេះហើយបានជា តាស្រី បានប្រាប់ឪពុកខ្ញុំថា សូមកុំឲ្យធ្វើជាស្គាល់គ្នាឲ្យសោះ ។ នៅទីនេះ ពុំត្រូវការអ្នកណាដែលធ្លាប់ធ្វើទាហាន ប៉ូលិស ជំទប់ មេឃុំ ស្មៀននោះទេ ។ សូម្បីតែកូនចៅអ្នកនោះពុំរាប់រកដែរ កម្មាភិបាលភាគច្រើនសុទ្ធតែជាកសិករសុទ្ធសាធ ជាអ្នកក្រ ហើយមិនបានរៀនសូត្រ ។ រីឯអ្នកដែលធ្លាប់រៀនសូត្រឬជាអតីតអ្នករាជការត្រូវចាត់ទុកគឺជាវណ្ណៈអធន ឬវណ្ណៈប្រឆាំងនឹងការមិនជិះជាន់ តាស្រី បានប្រាប់ពុកឲ្យប្រយ័ត្នចំពោះការនិយាយស្តីព្រោះថា នៅពេលយប់តែងតែមានឈ្លបដើរលបស្តាប់ក្រែងយើងនិយាយស្តីប្រឆាំងបដិវត្តន៍ ។

ស្អែកឡើងយើងត្រូវបានហៅឲ្យទៅប្រជុំនៅទីស្នាក់ការសហករណ៍ គឺជាកន្លែងដែលយើងជួបជុំម្តងហើយនៅថ្ងៃដំបូងពេលទើបមកដល់ ។ ប្រហែលម៉ោងប្រាំបីព្រឹក យើងបានជួបជុំគ្នាឯក្មេងៗត្រូវនៅចាំផ្ទះជាមួយនិងចាស់ៗដែលជរា និងមានជំងឺ ។ អង្គប្រជុំបានចាប់ផ្តើមដោយមិត្ត សឿន ជាគណៈចាត់តាំងអង្គប្រជុំ ។ គាត់បានបង្ហាញខ្លួនជាមួយមនុស្សបីនាក់ទៀតឲ្យយើងស្គាល់ ។ ពីឆ្វេងទៅស្តាំ មិត្ត សឿន ប្រធានគណៈសហករណ៍ មិត្ត សំ សមាជិក មិត្ត សៅ សមាជិក ។ មិត្តសឿន បានធ្វើបទឧទ្ទេសនាម

ដើម្បីបើកអង្គប្រជុំ ។ ពាក្យដែលប្រើក្នុងការនិយាយពេលនោះ មានភាពខុសប្លែកពីទម្លាប់និយាយស្ដីធម្មតាឆ្ងាយណាស់ ។ កម្មាភិបាលទាំងនោះ មិនធ្លាប់បានចូលរៀននៅមហាវិទ្យាល័យ ប៉ុន្តែមានចេះដឹងខ្ពង់ខ្ពស់អ្វីទេ ក៏ប៉ុន្តែជាមនុស្សក្លាហាន វាងវៃ និងស្វាហាប់ ។ ទឹកមុខមានភាពអង់អាចហើយនិយាយដោយឥតគក់ស្ទុត ហាក់បីដូចជាបណ្ឌិតអក្សរសាស្ត្រឬជាប្រមុខទ័ពដ៏អស្ចារ្យ ។ អ្នកទាំងនោះ ទន់ភ្លន់ តែរឹងប៉ឹងពោរពេញទៅដោយមោទកភាព ។

មិត្ត សឿន ចាប់ផ្ដើមអង្គប្រជុំ ។ ជាបឋមខ្ញុំសូមគោរពពុកម៉ែ! បងប្អូនប្រុសស្រីជាទីគោរព! ខ្ញុំបាទសូមបើកអង្គប្រជុំ ។ មុនបើកអង្គប្រជុំ ខ្ញុំបាទសូមប្រកាសកម្មវិធីនៃអង្គប្រជុំមានតដូចទៅៈ

- ខទ្វេសនាម
- សម្រុកខ្លាំងក្លាការពារកម្មសិទ្ធិផលបដិវត្តន៍
- ពង្រីកគោលជំហរប្រយុទ្ធតស៊ូវណ្ណៈ
- ផែនការរបស់អង្គការថ្នាក់លើ
- បិទអង្គប្រជុំ

នេះជាគំរូនៃការប្រជុំដែលប្រើជាទូទៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលខ្ញុំបានជួបប្រទះរយៈពេលជិតបួនឆ្នាំ ។ ខ្ញុំជឿថា អនុស្សាវរីយ៍នេះនឹងបាត់បង់យ៉ាងឆាប់រហ័សក្នុងយុគសម័យថ្មីនេះ សកលសភាវូបនីយកម្ម និងទំនើបកម្មដែលយើងដឹងថាខ្មែរគួររក្សាទុកឲ្យជំនាន់ក្រោយបានដឹង ។

បទខទ្វេសនាមរបស់មិត្តសឿន មានរយៈពេលប្រហែលពីរម៉ោង ។ គាត់បានរៀបរាប់ពីការតស៊ូនៃទ័ពរណសិរ្សរំដោះជាតិកម្ពុជា ចាប់ពីបាតដៃទទេរហូតដល់មហាជោគជ័យ នៅថ្ងៃទី១៧ មេសា ១៩៧៥ ។

នេះគឺជាការដឹកនាំដ៏ភ្លឺស្វាងរបស់អង្គការដ៏មហាភ្លឺស្វាង មហាលោតផ្លោះ មហាអស្ចារ្យ គាត់ក៏បានលើកឡើងពីទំនាស់របស់អង្គធាតុពីរគឺពួកអ្នកជិះជាន់គេ ដែលនៅក្នុងនោះ ការប្រយុទ្ធដ៏អស្ចារ្យរបស់កម្មករ កសិករ ក្រីក្រប្រឆាំងនឹងរបបផ្ដាច់ការ សក្តិភូមិ ខ្ញុំសង្កេតឃើញថា អ្នកទាំងនេះនិយាយដដែលអំពីរឿងនេះ តែពុំបាននិយាយទាល់តែសោះ អំពីព្រះនាមរបស់សម្ដេចឪ ។

ក្នុងចំណោមអ្នកមកស្ដាប់សេចក្ដីថ្លែងការណ៍នេះ មានមនុស្សតិចតួចណាស់ដែលចាប់អារម្មណ៍ ព្រោះភាគច្រើនជាគ្រូបង្រៀន សាស្ត្រចារ្យ អ្នកជំនួញ ហើយកំពុងតែអស់កម្លាំង និងស្រេកឃ្លាន នៅទីបញ្ចប់ យើងភ្ញាក់ព្រើត និងការខទ្វេសនាមរបស់មិត្ត ឡាន ។ មិត្ត ឡាន ជាកម្មាភិបាលអាយុប្រហែលជាងសាមសិបឆ្នាំ រាងទាបកន្ទាល់ សក់រួញ ភ្នែកលឺប១ មានសំឡេងដូចជាមាន់គក ។ ពុកម៉ែ បងប្អូនទាំងអស់ នេះជាបញ្ជារបស់អង្គការថ្នាក់លើសម្រាប់បងប្អូន អនុវត្តមានតដូចទៅៈ

◆ ទីមួយ ៈ បងប្អូនពុកម៉ែ ជាស្ត្រី ត្រូវកាត់សក់ឲ្យខ្លីទាំងអស់គ្នា ហាមដាច់ខាត មិនឲ្យចងបូរ ដាក់ដង្កាបនៅលើសក់ទេ ។

◆ ទីពីរ ៈ ហាមពាក់អាវពណ៌ ឬអាវផ្កាត្រូវយកទៅជ្រលក់ខ្មៅទាំងអស់គ្នា ។ បដិវត្តន៍កសិករក្រ មិនត្រូវលម្អខ្លួនដោយគ្រឿងមាសពេជ្រ ដែលជាកាកសំណល់នៃរបបសក្តិភូមិផ្តាច់ការដែលត្រូវបំបាត់ ចោលជាដាច់ខាត ។

◆ ទីបីៈ មិនត្រូវប្រើពាក្យ ញុំាគេងទៀតទេ ត្រូវប្រើពាក្យហូប និងដេក ។ មិនត្រូវហៅ ប៉ា ម៉ាក់ ជាដាច់ខាត ព្រោះពាក្យនេះសម្រាប់តែវណ្ណៈសក្តិភូមិប្រតិកិរិយាតែប៉ុណ្ណោះ ត្រូវហៅថា ពុកម៉ែ ។

◆ ទីបួន ៈ កុំរម្លឹកអំពីរបបចាស់ កុំនិយាយពីការធ្លាប់ហូបឆ្ងាញ់ ទីនេះគឺជាតំបន់បដិវត្តន៍ទាំងអស់គ្នាជាឧបករណ៍ផ្ដាច់ការរបស់អង្គការ ត្រូវនិយាយអំពីការបង្កបង្កើនផលពីភាពស្មើគ្នា ពីវណ្ណៈកម្មករកសិករក្រថ្នាក់ក្រោម ។

◆ ទីប្រាំ ៈ កុំនិយាយពាក្យថា លោក ត្រូវហៅថា មិត្ត មិត្តបង មិត្តប្អូន ។ សមមិត្តចំពោះថ្នាក់ជា "កម្មាភិបាល" ពេលជួបគ្នាមិនត្រូវចេះសំពះឬជម្រាបសួរឡើយ ព្រោះនេះជាកម្ទេលនៃរបបសក្តិភូមិផ្តាច់ការ ។ មិនត្រូវចាប់ដៃ "បង់សួរ" ជាដាច់ខាត ព្រោះជាទម្លាប់របស់អាណានិគមបារាំងតែប៉ុណ្ណោះ ។

◆ ទីប្រាំមួយ ៈ សុំកុំគិតថានឹងបានត្រឡប់ទៅផ្ទះវិញឲ្យសោះ នេះជាផ្ទះរបស់បងប្អូនហើយ ។ ទីណាក៏ជាលំនៅដ្ឋានបង្អែកបដិវត្តន៍ដែរ ។ អំណឹះតទៅនឹងគ្មានអ្នកមាន អ្នកក្រទៀតទេ ។ យើងអាចធ្វើការបានគ្រប់ទីកន្លែង ស្នាក់នៅទីណាក៏បាន អង្គការជាអ្នកដឹកនាំដ៏ភ្លឺស្វាង មហារុងរឿង មហាលោតផ្លោះ មហាអស្ចារ្យ ទីណាក៏ជារបស់យើងដែរ ។ អង្គការទុកឲ្យបងប្អូនពីរថ្ងៃ ដើម្បីសង់ខ្ទមសម្រាប់ស្នាក់នៅ ។ សូមកុំប្រើពាក្យថា "ផ្ទះ" ឲ្យសោះ ត្រូវប្រើពាក្យថា "ខ្ទម" ព្រោះថានោះពុំមែនជាកម្មសិទ្ធិឯកជនរបស់បងប្អូនទេ យើងអាច

ចាកចេញពីទីនេះទៅកាន់ទីណាក៏បានគ្រប់ពេលវេលា ។ សូមកុំសង់ខ្ទមឲ្យធំដូចជារបស់អភិជនឡើយ ព្រោះយើងទាំងអស់គ្នាជាវណ្ណៈកសិករក្រ ។

◆ ទីប្រាំពីរៈ ត្រូវពង្រឹងជីវភាពវណ្ណៈគស្ម៊ូ មុតចំពោះការងារ ។ ត្រូវមកធ្វើការឲ្យទាន់ពេលវេលា បើព្យួរជួងហើយ ត្រូវសម្រុកចូលធ្វើការងារ ។ គ្រប់បញ្ហានេះមិត្ត ឡាន បានបញ្ជាក់មួយៗច្បាស់ៗ ពោរពេញទៅដោយអំណាច និងភាពម៉ឹងម៉ាត់ ។ មិត្តឡាន មិនចេះអក្សរទេ តែគាត់មានស្មារតីចងចាំយ៉ាងល្អ ។ យើងបានស្តាប់យ៉ាងស្ងាត់ស្ងៀម បន្ទាប់មក មិត្តឡាន បានសង្កត់ពាក្យយ៉ាងធ្ងន់ៗថា ពុកម៉ែ បងប្អូនទាំងអស់ ទីនេះជាមូលដ្ឋានបង្អែកបដិវត្តន៍ ទាំងអស់គ្នាជាជនបដិវត្តន៍ បងប្អូនត្រូវពង្រឹងគោលជំហរគស្ម៊ូវណ្ណៈ បំពេញភារកិច្ចដើម្បីបដិវត្តន៍ ។ បច្ចុប្បន្ននេះ សង្គ្រាមមួយទៀត ជាមួយចក្រពត្តិអាមេរិកកាំងបានចប់ហើយ ក៏ប៉ុន្តែយើងនៅមានសង្គ្រាមមួយទៀត គឺសង្គ្រាមប្រឆាំងសតិអារម្មណ៍សេរី សូមបងប្អូនតាំងស្មារតី ព្រោះចលនាបដិវត្តន៍ប្រៀបបាននឹងចរន្តទឹកដែលហូរប្រៀបដូចជាកង់ប្រវត្តិសាស្ត្រប្រយ័ត្នឲ្យមែនទែន កង់ប្រវត្តិសាស្ត្រវិលជាន់ ។ នេះជាពាក្យថ្មីមួយទៀតដែលខ្ញុំបានស្គាល់គឺកង់ប្រវត្តិសាស្ត្រ ។

## ១៧) រគាំងនិងចន្ទុះ

យើងត្រូវសង់ "ខ្ទម" សម្រាប់ស្នាក់នៅសម្រាប់យើងទាំងដប់ប្រាំមួយនាក់ មានតែខ្ញុំម្នាក់គត់ ដែលធំហើយចេះគិតគូរជាងគេ ។ ចំណែកឯក្មួយប្រុសពីរនាក់វាជាកូនវរសេនីយ៍នៃទាហាន លន់ នល់ ជាក្មេងទំយើ ហើយខ្ជិលធ្វើការ ។ ចំពោះពុកខ្ញុំដែលជាអតីតទាហានបារាំងក៏ជរាដែរ ។ ខ្ញុំត្រូវកាប់ដើមឈើយកមកធ្វើសសរ និងបង្គង់ ឯបងស្រី ប៊ុនណយ និងបងថ្លៃ ដានី និង ស៊ីថា ដើរបេះស្លឹកខ្ទិងយកមកដេរភ្ជាប់គ្នាសម្រាប់ប្រក់ ។ ទីនេះយើងគ្មានផ្សារដើម្បីទិញដែកគោល ឬខ្សែលួសទេ ។ ខ្ទមរបស់យើងត្រូវចងដោយវល្លិថ្នឹង ឬវល្លិប្រេង ។ យើងមានពេលតិចណាស់សម្រាប់សង់ខ្ទម ព្រោះអង្គការទុករយៈពេលឲ្យយើងតែពីរថ្ងៃប៉ុណ្ណោះ ។

នេះជាផ្ទះនៃជីវិតរបស់ខ្ញុំមិនដូចជាគណិតវិទ្យា ភាសាបារាំងនោះទេ តែខ្ញុំត្រូវរៀនសូត្រពីអ្នកស្រុកទាំងនោះដើម្បីសង់វាដោយមិនប្រើដែកគោលនោះឡើយ ។ អស្ចារ្យណាស់រយៈពេលពីរថ្ងៃ យើងបានកូនខ្ទមមួយសម្រាប់ដប់ប្រាំមួយដាក់ជ្រកនៅ ។ វាមិនគត់នឹងទឹកភ្លៀងប៉ុន្មានទេ ព្រោះខ្ញុំមិនមានពិសោធន៍ក្នុងការប្រកដំបូល ឯបងៗស្រីៗរបស់ខ្ញុំក៏គ្មានជំនាញក្នុងការដេរស្លឹកខ្ទិងដែរ ។ ពេលវេលាធ្វើការបានមកដល់ហើយ ។ នៅទីនោះ រគាំងចាប់បន្លឺសំឡេងនៅម៉ោងប្រាំព្រឹក ពេលដែលរគាំងសហករណ៍យើងចាប់បន្លឺឡើងព្រមគ្នាជាមួយនឹងរគាំងសហករណ៍ជិតខាងពន្លឺឡើងដែរ ។ នៅក្បែរនេះ ខាងលិចមានសហករណ៍តានប់ថ្មី ខាងកើតមានសហករណ៍តាំងយួង និងឆ្ងាយពីនេះខាងលិចឈៀងខាងត្បូងគឺសហករណ៍ស្រែរបង ។ ការវាយលើកទីមួយនេះគឺជាដាស់យើងឲ្យក្រោកឡើងត្រៀមខ្លួនចេញទៅធ្វើការ ។ រគាំងវាយជាលើកទីពីរនៅម៉ោងប្រាំមួយ យើងត្រូវដើរសំដៅកន្លែងធ្វើការ ។ រគាំងវាយលើកទីបីនៅម៉ោងប្រាំពីរព្រឹកជាម៉ោងដែលយើងត្រូវធ្វើការងារតាមមុខសញ្ញាផ្សេងៗ ។ ធម្មតា រគាំងទាំងនេះច្រើនធ្វើអំពីដែកកំណល់រទេះភ្លើង ឬកន្លែងខ្លះជាថាសកង់ឡាន វាព្យួរគួរឲ្យរន្ធត់ និងសង្វែកខ្លាំងណាស់ ។

រគាំងនេះគឺជាថាសរថយន្តជីអ៊ឹមសេ ហើយត្រូវបានចងព្យួរដោយច្រវ៉ាក់ទាក់នឹងមែកឈើក្បែរស្នាក់ការសហករណ៍កោះកណ្តាល ។ វាព្យួខ្លាំងណាស់អាចបានចម្ងាយដល់តាំងព្រេច ស្រែរបង និងតានប់ថ្មីប្រហែលប្រាំគីឡូម៉ែត្រ ។ អ្នកវាយរគាំងភាគច្រើនជាឈ្លប ឬនីរសារភូមិដែលមានអាយុប្រហែល១៣-១៧ឆ្នាំ អ្នកទាំងនោះជាកម្លាំងដ៏រឹងមាំរបស់អង្គការមានជំហរដាច់ខាតចំពោះមាគ៌ាបដិវត្តន៍ ។ ក្នុងរយៈពេលនេះ ខ្ញុំក៏ត្រូវចូលព្រៃរកកាប់សម្បកឈើយកមកដំ និងខ្ទះពូថៅហើយយកទៅត្រាំក្នុងទឹក ហើយយកខោអាវទាំងអស់មកជ្រលក់រួចហាលថ្ងៃឲ្យស្ងួត ។

ពេលដែលខោអាវដែលជ្រលក់សម្រកឈើនោះស្ងួតហើយ ទើបយើងដើរសំដៅទឹកត្រពាំងណាដែលមានភក់ពណ៌ខ្មៅ យើងយកខោអាវនោះទៅជាន់ក្នុងភក់នោះ វានឹងឡើងពណ៌ខ្មៅក្រឹបខោអាវយើងមានពណ៌ខ្មៅមែន តែវាមិនមានភាពសង្ហាដូចខោអាវរបស់សមមិត្តទាំងនោះទេ ។ ខ្ញុំបានរក្សាទុកខោអាវល្អៗខ្លះៗសម្រាប់ទុកជាអនុស្សាវរីយ៍ កាលនៅជានិស្សិតសាកលវិទ្យាល័យគឺជ្រលក់ល្មមតែប្រើប្រាស់ពេលធ្វើការតែប៉ុណ្ណោះ ។

**(នៅមានត)**

**ឆាយ ស៊ីណាត្រ**

# តើពុកម៉ែនិងប្អូននៅឯណា?

ខ្ញុំមានអាយុត្រឹមតែប្រាំឆ្នាំប៉ុណ្ណោះពេលខ្ញុំបែកពីឪពុកម្តាយរបស់ខ្ញុំ ។ ខ្ញុំមិនសូវចំណាំមុខគាត់ច្បាស់ដោយភ្នែករបស់ខ្ញុំផ្ទាល់ទេ ។ ខ្ញុំគ្រាន់តែចាំតិចតួចថា ឪពុករបស់ខ្ញុំឈ្មោះ ហៀង ជួនកាលអ្នកខ្លះហៅគាត់ ថៃ ។ ចំណែកម្តាយរបស់ខ្ញុំវិញឈ្មោះ ណៃ ហើយខ្ញុំមានប្អូនប្រុសម្នាក់ទៀតឈ្មោះ គឹម ។ ដោយសារពេលដែលខ្ញុំបែកពីឪពុកម្តាយរបស់ខ្ញុំ ខ្ញុំនៅក្មេងពេក ដូច្នេះខ្ញុំមិនចាំត្រកូលរបស់ខ្ញុំទេ ។ ខ្ញុំគ្រាន់តែដឹងថា ខ្ញុំឈ្មោះ លិក នុំ ។ ខ្ញុំឮអ្នកជិតខាងថា ឪពុកម្តាយ ខ្ញុំតែងហៅខ្ញុំថា កាញីក ពេលដែលខ្ញុំនៅក្មេង ។

ខ្ញុំកើតនៅខេត្តបាត់ដំបង ចំណែកស្រុកកំណើតរបស់ម្តាយខ្ញុំនៅខេត្តសៀមរាប ។ ខ្ញុំបានបែកពីឪពុកម្តាយតាំងពីឆ្នាំ១៩៧៥មក ពេលដែលយោធាខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ។ ក្នុងរបបខ្មែរក្រហម ខ្ញុំរស់នៅភូមិ ព្រែកគ្រប់ ខេត្តបាត់ដំបង ។ ខ្ញុំចាំបានថា ពេលមួយមានទឹកជំនន់លិចភូមិ ហើយកម្មាភិបាលខ្មែរក្រហមក៏បានដាក់ខ្ញុំក្នុងទូកមួយជាមួយក្មេងៗជាច្រើនទៀត ហើយយកខ្ញុំទៅដាក់មណ្ឌលកុមារនៅក្នុងភូមិដីប៉ាង ឃុំត្រែង ស្រុកស្តៅ (បច្ចុប្បន្ន ស្រុកសំឡូត) បាត់ដំបង ដោយនៅទីនោះខ្ញុំធ្វើការនៅកន្លងដាំដើមកប្បាស់ ។

ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ កម្មាភិបាលខ្មែរក្រហមបានរត់គេចខ្លួនអស់ ដោយទុកឲ្យក្រុមកុមារយើងខ្ញុំទៅរកឪពុកម្តាយ និងបងប្អូនដោយខ្លួនឯង ។ ដោយកាលនោះ ខ្ញុំមិនសូវដឹងទីតាំងភូមិសាស្ត្រច្រើន ខ្ញុំក៏វង្វេងនៅក្នុងចម្ការកប្បាស់រកផ្លូវទៅណាមិនរួច ។ ជាភ័ព្វសំណាង មានសប្បុរសជនម្នាក់បានរើសខ្ញុំមកចិញ្ចឹម ហើយបីបាច់ថែរក្សាខ្ញុំរហូតដល់សព្វថ្ងៃនេះ ។ ខ្ញុំតែងចាត់ទុកគាត់ថាជាឪពុកចិញ្ចឹមរបស់ខ្ញុំ ។ **លិក នុំ ហៅ កាញីក**



លិក នុំ ថតនៅជំរំជនភៀសខ្លួនប្រទេសថៃក្នុងទសវត្សរ៍៨០



លិក នុំ ថតនៅសហរដ្ឋអាមេរិក ឆ្នាំ២០១៣

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម




មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។




***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។




ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ


ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល សហរដ្ឋអាមេរិក

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.

A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 162, June 2013 ◆ Funded by USA.

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.